**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economicques**

**Royal University of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ចៅក្រមស៊ើបសួរនៅកម្ពុជាបច្ចុប្បន្ន

ស្រាវជ្រាវ ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


| | | | |
|---|---|---|---|
| ស្រាវជ្រាវដោយ | | ណែនាំដោយ | |
| និស្សិតឈ្មោះ: | លោក **ស៊ីម ហុងស៊ឺ** | លោក: **ហៀង សាង** | |
| | លោក **ពៅ ប្រសិទ្ធ** | | |
| ថ្នាក់បរិញ្ញាប័ត្រ | **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា | ២០២០ |
| ជំនាន់ទី | ២៤ | ឆ្នាំសរសេរសារណា | ២០២៤ |

# លិខិតថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ស៊ីម ហុងស៊ី** និង **ពៅ ប្រសិទ្ធ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី ៤ ជំនាន់ទី ២៤ លេខកូតថ្នាក់ L4A6 នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖**

មាតាបិតា ទាំងទ្វេ ដែលលោកបានផ្តល់កំណើតដល់រូបកូន ព្រមទាំងប្រឹងប្រែងគ្រប់បែបយ៉ាង ក្នុងការចិញ្ចឹមបីបាច់ថែរក្សាការពារ អប់រំទូន្មាន ប្រៀនប្រដៅរូបកូន ប្រកបដោយទឹកចិត្តព្រហ្មវិហារធម៌ ទាំងបួន។ ជាងនេះទៅទៀតលោកអ្នកដ៏មានគុណទាំងទ្វេ បានខិតខំរកថវិកា មិនខ្លាចនឿយហត់ ទាំងថ្ងៃ ទាំងយប់ ពុះពារប្រឈមមុខរាល់ទុកលំបាកគ្រប់បែបយ៉ាង ធ្វើយ៉ាងណាជម្រុញឱ្យរូបកូនទទួល បានការសិក្សារៀនសូត្រ រហូតដល់បានបញ្ចប់ថ្នាក់ឧត្តមសិក្សា ដោយទទួលបាននូវលទ្ធផលគួរជាទី មោទនៈបំផុត។

**សូមគោរពនឹងថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅជូន ៖**

- **ឯកឧត្តម សាកលវិទ្យាធិការ** សាកលវិទ្យាធិការង ព្រមទាំងលោក លោកស្រី សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចូលរួមរៀបចំ ឱ្យសាកលវិទ្យាល័យ មានដំណើរការប្រកបដោយជោគជ័យ។ ជាពិសេស លោក លោកស្រី សាស្ត្រាចារ្យ ដែលបានយកចិត្តទុកដាក់ក្នុងការបង្រៀន ដោយមិនខ្លាចនឿយហត់ និងជំរុញផ្នែកស្មារតី ឱ្យ យើងខ្ញុំខិតខំរៀនសូត ក្រេបជញ្ជក់យកចំណេះវិជ្ជា។

- ជាពិសេសជាងនេះទៅទៀត សូមធ្វើក្តីគោរពយ៉ាងជំពេង និងស្មោះអស់ពីដួងចិត្តបំផុតជូន ចំពោះលោកសាស្ត្រាចារ្យ **ហៀង សាង** ដែលទទួលបន្ទុកក្នុងការដឹកនាំសារណា ដែលលោកសាស្ត្រាចារ្យបានខិតខំអស់ពីកម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី និងពេលវេលាដ៏មានតម្លៃ និងមមាញឹកផ្តល់ជាគំនិត ផ្តួចផ្តើមយ៉ាងច្រើនសន្ធឹកសន្ធាប់ ក្នុងការជម្រុញណែនាំ លើកទឹកចិត្ត និងបានត្រួតពិនិត្យ កែលំអជា ច្រើនលើក ច្រើនសារដល់រូបយើងខ្ញុំ ក្នុងការសិក្សាស្រាវជ្រាវ ចងក្រង សរសេរនូវអត្ថបទសារណានេះ ឡើងរហូតដល់បានបញ្ចប់ជាស្ថាពរ និងប្រកបដោយលទ្ធផលវិជ្ជមាន។

ជាកិច្ចបញ្ចប់នេះ យើងខ្ញុំសូមឱនកាយលើកដៃប្រណមបួងសួងជូនដល់ មាតាបិតា ញាតិមិត្ត ព្រមទាំងថ្នាក់ដឹកនាំសាកលវិទ្យាល័យ លោក លោកស្រីសាស្ត្រាចារ្យ លោកសាស្ត្រាចារ្យដឹកនាំ សូម ជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ដោយឆ្លងតាមការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច បានជម្រុញ ក៏ដូចជាផ្តល់ឱកាសឱ្យយើងខ្ញុំ សម្រេចចិត្តធ្វើការ សិក្សាស្រាវជ្រាវ និង សរសេរចងក្រង នូវអត្ថបទសារណា ដែលមានចំណងជើងថា " **ចៅក្រមស៊ើបសួរនៅកម្ពុជា បច្ចុប្បន្ន** " នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ នេះឡើង ដើម្បីជាស្នាដៃ ជូន ដល់សាកលវិទ្យាល័យ និង ដើម្បីទុកសម្រាប់តម្កល់នៃការបញ្ចប់ការសិក្សារបស់យើងខ្ញុំផងដែរ ។ តាមរយៈស្នាដៃនេះក៏ជាឯកសារជំនួយដល់មិត្តនិស្សិត អ្នកសិក្សាស្រាវជ្រាវ និង សាធារណៈជនគ្រប់មជ្ឈដ្ឋាន នៅក្នុងព្រះរាជាណាចក្រកម្ពុជាទុកជាផ្នែកមួយនៃការស្រាវជ្រាវ។

កិច្ចស្រាវជ្រាវនេះ ចងក្រងឡើងក្នុងបំណង ដើម្បីបង្ហាញអំពីខ្លឹមសារសំខាន់ៗនៅដំណាក់ កាលនីមួយៗ ក្នុងការអនុវត្តនាពេលបច្ចុប្បន្ននេះ ក្នុងផ្នែកនីតិវិធីព្រហ្មទណ្ឌដែលផ្តោតជាសំខាន់ លើដំណាក់កាល នៃនីតិវិធីរបស់ចៅក្រមស៊ើបសួរ ។ លើសពីនេះក្នុងអត្ថន័យខ្លឹមសារក៏មាន ពន្យល់យ៉ាងស៊ីជម្រៅទៅលើ នីតិវិធីនីមួយៗ ដោយចង្អុលបង្ហាញ នូវមាត្រានៃច្បាប់នានា ដែលពាក់ព័ន្ធនឹងការបើក បិទស៊ើបសួរ និង វិធានការនិរន្តរាយ យ៉ាងលំអិត ព្រមទាំងមានភ្ជាប់នូវ ឧទាហរណ៍មួយចំនួន ដែលធ្វើការបកស្រាយទៅលើទ្រឹស្តីសំខាន់ៗក្នុងនីតិ វិធី។ ទន្ទឹមគ្នានេះផងដែរ ក្នុងការបកស្រាយទៅលើប្រធានបទនេះ ក៏មានការលើកយក បញ្ហាមួយចំនួនដែល រាំងស្ទះដល់ការបកស្រាយ និង ការអនុវត្តនីតិវិធី ជាក់ស្តែង ព្រមទាំង សិក្សាទៅលើ ស្ថានភាព យន្តការយុទ្ធនាការ និងចក្ខុវិស័យ របស់តុលការ នាពេលបច្ចុប្បន្ន និង នាពេលអនាគត ដើម្បីកែលំអរប្រព័ន្ធតុលាការ ឱ្យកាន់តែមានភាពសុក្រឹត យុត្តិធម៌បន្ថែមទៀត ជាពិសេសគឺ ចៅក្រមស៊ើបសួរនេះតែម្តង ដែលជាបុគ្គលមានតួនាទីសំខាន់ក្នុងការស្វែងរកការពិតជូនជនរងគ្រោះ ។

យើងខ្ញុំសង្ឃឹមថា ស្នាដៃមួយនេះ នឹងផ្តល់នូវអត្ថប្រយោជន៍ ដល់អ្នកអានក្នុងកំរិតណា មួយមិនខាន ហើយជាពិសេសសូមអភ័យទោសទុកជាមុន នូវរាល់កំហុសខុសឆ្គាំឆ្គងដោយ អចេតនាដោយប្រការណាមួយ លើសពីនេះទៅទៀត យើងខ្ញុំរង់ចាំស្វាគមន៍ ក្នុងការរិះគុណតិះ ទៀនក្នុងន័យស្ថាបនា ដើម្បីកែលំអនូវរាល់កំហុសឆ្គង ពីសំណាក់មិត្តអ្នកអាន ដោយក្តីសោមនស្សរីករាយ ដើម្បីឱ្យសារណានេះកាន់តែមានភាពសុក្រឹត និងប្រសើរឡើង។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម**............................................................................................................................១

## ជំពូកទី ១
## រំលឹកទ្រឹស្តីទូទៅ

**ផ្នែកទី១៖ វាក្យសព្ទ**.......................................................................................................................៦

**ផ្នែកទី២៖ ច្បាប់ និងបទដ្ឋានគតិយុត្ត**............................................................................................៩

២.១. ច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ........................................................................... ១០

២.២ ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា.............................................................. ១២

២.៣. ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម.............................. ១៤

## ជំពូកទី២
## ស្ថានភាពទូទៅក្នុងវិស័យយុត្តិធម៌នៅកម្ពុជា

**ផ្នែកទី១៖ សាវតារនៃតុលាការកម្ពុជា**........................................................................................ ១៨

**ផ្នែកទី២៖ តុលាការនៅកម្ពុជាបច្ចុប្បន្ន**......................................................................................... ១៩

២.១. សាលាដំបូង និងអយ្យការអមសាលាដំបូង........................................................................ ២០

២.២. សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍........................................................ ២១

២.៣. តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល.......................................................២៣

## ជំពូកទី ៣
## តួនាទីរបស់ចៅក្រមស៊ើបសួរនៅកម្ពុជាបច្ចុប្បន្ន

**ផ្នែកទី១៖ ការស៊ើបសួរ**.............................................................................................................. ២៦

១.១.ការសម្ងាត់នៃការស៊ើបសួរ ........................................................................................... ២៦

១.២. សមត្ថកិច្ចដែនដី........................................................................................................... ២៦

១.៣. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញា....................................................... ២៧

**ផ្នែកទី២៖ វិធានការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ**...................................................................... ២៧

២.១. អំណាចស្រាវជ្រាវ ........................................................................................ ២៧
២.២. អំណាចផ្ទេរ ................................................................................................ ៣០
**ផ្នែកទី៣៖ វិធានការនិរន្តរាយ**............................................................................ ៣១
៣.១. ដីកា .......................................................................................................... ៣១
៣.១.១. ដីកាបង្គាប់ឱ្យចូលខ្លួន............................................................................... ៣១
៣.១.២. ដីកាបង្គាប់ឱ្យនាំខ្លួន................................................................................ ៣២
៣.១.៣. ដីកាបង្គាប់ឱ្យចាប់ខ្លួន ............................................................................. ៣២
៣.១.៤. ដីកាបង្គាប់ឱ្យឃុំខ្លួន ............................................................................... ៣៣
៣.២. សិទ្ធិអំណាច ត្រួតពិនិត្យថែរក្សាជនត្រូវចោទ ..................................................... ៣៣
៣.២.១. ការឃុំខ្លួនបណ្តោះអាសន្ន ........................................................................ ៣៤
៣.៣. ការត្រួតពិនិត្យតាមផ្លូវតុលាការ ...................................................................... ៣៧
**ផ្នែកទី៤៖ ការបិទការស៊ើបសួរ**............................................................................ ៣៩
៤.១. ការជូនដំណឹងពីការបិទការស៊ើបសួរ ............................................................... ៣៩
៤.២.ការបិទការស៊ើបសួរតាមបណ្តឹងសុំរបស់ភាគី....................................................... ៤០
**ផ្នែកទី៤៖ ដីកាដំណោះស្រាយ** ............................................................................ ៤០
៤.១. ការលើកលែងការចោទប្រកាន់........................................................................ ៤២
៤.២. ការបញ្ជូនទៅជំនុំជម្រះ ................................................................................ ៤៣

**ជំពូកទី៤**

**បញ្ហាប្រឈមបច្ចុប្បន្ន និងយុទ្ធនាការ**

**សេចក្តីសន្និដ្ឋាន**........................................................................................ ៥៤
**អនុសាសន៍**................................................................................................ ៥៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅតាមសង្គមនីមួយៗតែងតែមានច្បាប់សម្រាប់ឱ្យប្រជាជនរបស់ខ្លួនអនុវត្តដើម្បីធានាឱ្យបាននូវការទទួលបានសិទ្ធិរបស់ពលរដ្ឋគ្រប់ៗរូប ដែលច្បាប់ទាំងនោះបានបែងចែកជាច្រើនបែប ច្រើនសណ្ឋានទៅតាមប្រទេសនីមួយៗផងដែរ។ បើយើងងាកទៅមើលប្រព័ន្ធច្បាប់ធំៗនៅលើសាកលលោកវិញ គឺគេបានបែងចែកជាបួនប្រព័ន្ធ ធំៗ រួមមាន ប្រព័ន្ធច្បាប់ Common Law , ប្រព័ន្ធច្បាប់ស៊ីវិល (Civil Law), ប្រព័ន្ធច្បាប់សង្គមនិយម និងប្រព័ន្ធច្បាប់សាសនា។ ចំពោះព្រះរាជាណាចក្រកម្ពុជារបស់យើង ជាប្រទេសមួយដែលបានសម្រេចចិត្តជ្រើសរើសនូវប្រព័ន្ធច្បាប់ស៊ីវិល (Civil Law) ហើយក៏ជាប្រទេសមួយដែលកំពុងមានការអភិវឌ្ឍព្រមទាំងមានកំណើនសេដ្ឋកិច្ច ក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលគួរឱ្យកត់សម្គាល់ផងដែរ។ ប៉ុន្តែទាំងអស់នេះក៏ជាកត្តាមួយធ្វើឱ្យមានការប្រកួតប្រជែងដើម្បីដណ្តើមផលប្រយោជន៍គ្នាក្នុងគោលដៅបំពេញនូវសេចក្តីតម្រូវការដែនកំណត់របស់ខ្លួនដែលបានបង្កឱ្យមាននូវ ភាពអនាធិបតេយ្យ ភាពគ្មានសណ្តាប់ធ្នាប់ និងបាត់បង់នូវតម្លៃសីលធម៌សង្គម ហើយបានបង្កឱ្យមានអំពើអសកម្មនានា ដែលនាំឱ្យមានផលវិបាកនៅក្នុងសង្គមជាតិ។ ទន្ទឹមនឹងនេះដើម្បីការទំនាក់ទំនងក៏ដូចជាការរស់នៅក្នុងសង្គមនីមួយៗមានសុវត្ថិភាព របៀបរៀបរយល្អ ថ្នាក់ដឹកនាំតែងតែខិតខំរិះរកនូវមធ្យោបាយ គោលនយោបាយ វិធីសាស្ត្រជាច្រើន ដើម្បីថែរក្សា បង្ការ ការពារ និងទប់ស្កាត់នូវ អំពើអវិជ្ជមាន ដែលបង្កឱ្យកើតមាននូវការប៉ះពាល់ដល់ការរស់នៅទំនាក់ទំនង និងរបៀបរៀបរយនៃសង្គមជាតិរបស់យើង។ ក្នុងនោះវិធានច្បាប់ដែលមានអនុភាពអនុវត្តទៅលើជីវភាពរស់នៅទូទៅគឺ វិធានច្បាប់ព្រហ្មទណ្ឌដែលមានចែងនៅប្រភេទបទល្មើសជាច្រើននៅក្នុងនោះ។ រឿងក្តីព្រហ្មទណ្ឌ គឺជាប្រតិកម្មតាមផ្លូវតុលាការរបស់សង្គមបានន័យថាចាប់ពីពេលដែលបទល្មើសមួយត្រូវបានប្រព្រឹត្តរហូតទៅដល់ការដាក់ទណ្ឌកម្ម និងមាននីតិវិធីមួយត្រូវបានដំណើរការហៅថា រឿងក្តីព្រហ្មទណ្ឌ បានន័យថាវាកើតឡើងនៅពេលដែលបានប្រព្រឹត្តរហូតដល់មានការប្រកាសទណ្ឌកម្ម និងអនុវត្តទណ្ឌកម្ម ឬទោស។ ចំពោះវិធានដែលទាក់ទងនឹងការរៀបចំការប្រព្រឹត្តទៅនឹងការវិនិច្ឆ័យនៃរឿងក្តីព្រហ្មទណ្ឌនេះគឺបង្កើតបានជាសំណុំវិធានមួយហៅថានីតិវិធីព្រហ្មទណ្ឌនេះឯង។[1] ដូច្នេះនីតិវិធីព្រហ្មទណ្ឌ គឺជាសំណុំវិធានដែលគ្រប់គ្រងទៅលើការរៀបចំការប្រព្រឹត្ត ទៅនឹងការវិនិច្ឆ័យនៃរឿងក្តីព្រហ្មទណ្ឌ ដើម្បីធានានូវប្រសិទ្ធភាពនៃដំណើរការរបស់តុលាការ ក៏ដូចជាស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ។

[1] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា នស/រកម/០៧០៨/០២៤, ២៤ កក្កដា ២០០៧

ក្រមនីតិវិធីព្រហ្មទណ្ឌបានចងក្រងឡើងក្នុងគោលដៅសំខាន់ទាក់ទងទៅនឹងដំណាក់កាលនៃការវិនិច្ឆ័យបទល្មើសដើម្បីជាភាពងាយស្រួលក្នុងការអនុវត្តនីតិវិធីនៅពេលមានបទល្មើសណាមួយកើតឡើងគឺត្រូវអនុវត្តតាមដំណាក់កាលដែលបានបែងចែកទៅតាមនីតិវិធីសំខាន់ៗចំនួន ៤ រួមមាន ៖

- ទីមួយៈ  ការស៊ើបអង្កេត ដែលធ្វើឡើងដោយនគរបាលយុត្តិធម៌
- ទីពីរៈ ការចោទប្រកាន់ ដែលធ្វើឡើងដោយព្រះរាជអាជ្ញា
- ទីបីៈ ការស៊ើបសួរ ដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ
- ទីបួនៈ ការជំនុំជម្រះ ដែលធ្វើឡើងដោយចៅក្រមជំនុំជម្រះ

ទោះបីជានៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌមានដំណាក់កាលជាច្រើនក៏ដោយ ដំណាក់កាលស៊ើបសួររបស់យុត្តាធិការស៊ើបសួរ ជានីតិវិធីស្វែងរកការពិតមួយដ៏មានសារៈសំខាន់ ដោយហេតុថាដំណាក់កាលនេះបង្ហាញអំពីស្មារតីនៃគោលការណ៍បែងចែកអំណាចក្នុងស្ថាប័នតុលាការក្នុងការស្វែងរក និងធានាយុត្តិធម៌ជូនប្រជាពលរដ្ឋឱ្យស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិច្បាប់នានា។ តាមរយៈនៃកិច្ចស៊ើបអង្កេតនេះ ក្រៅពីមន្ត្រីនគរបាលយុត្តិធម៌ គេឃើញថាចៅក្រមស៊ើបសួរ ក៏មានតួនាទីយ៉ាងចម្បងក្នុងការស៊ើបសួរស្វែងរកការពិតផង ទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុកផង។

អាស្រ័យហេតុនេះ ចៅក្រមស៊ើបសួរពិតជាមានតួនាទីយ៉ាងសំខាន់ណាស់ ក្នុងដំណាក់កាលនីតិវិធីព្រហ្មទណ្ឌតាមរយៈតួនាទីស៊ើបសួររបស់គាត់ ពីព្រោះថា ដំណាក់កាលនេះ គឺជាដំណាក់កាលមួយដែលបញ្ជាក់បានថាជនរូបណាបានប្រព្រឹត្តបទល្មើស ឬមិនបានប្រព្រឹត្តបទល្មើស។

## ២.ចំណោទនៃការស្រាវជ្រាវ

នៅក្នុងដំណាក់ការស៊ើបសួរ តើចៅក្រមស៊ើបសួរគឺជាអ្នកណា?

រយៈពេលកន្លងមកនេះយើង សង្កេតឃើញថាមានមន្ត្រីមួយចំនួនតូច ព្រមទាំងសិស្សានុសិស្សផ្នែកច្បាប់ មិនទាន់ជ្រាបច្បាស់ឱ្យបានជ្រាលជ្រៅអំពីប្រធានបទនេះនៅឡើយ ដែលជាហេតុនាំឱ្យការអនុវត្តច្បាប់នៅក្នុងដែនដីព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃទទួលរស់នៅផលប៉ះពាល់ដល់សិទ្ធិ សេរីភាពរបស់បុគ្គល។ ជាការពិតណាស់នៅក្នុងប្រព័ន្ធយុត្តាធិការ នៃព្រះរាជាណាចក្រកម្ពុជាចំពោះរឿងព្រហ្មទណ្ឌបានបែងចែកចៅក្រមជាពីរដែលមានដូចជាទីមួយ ចៅក្រមអយ្យការ ឬអាចហៅបានថាព្រះរាជអាជ្ញា និងទីពីរចៅក្រមអាសនៈដែលក្នុងនោះមានជាចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះ។

ដើម្បីស្រាយចម្ងល់ខាងលើឱ្យកាន់តែស៊ីជម្រៅ និងមានអត្ថន័យកាន់តែច្បាស់បន្ថែមទៀតយើងបាន លើកយកសំណួរមួយចំនួនមកចោទចោទសួរដូចជា តើតួនាទីរបស់ចៅក្រមស៊ើបសួរមានអ្វីខ្លះ ? តើដំណាក់កាលស៊ើបសួររបស់ចៅក្រមស៊ើបសួរប្រព្រឹត្តទៅយ៉ាងដូចម្តេចខ្លះ ? តើច្បាប់បានកំណត់សិទ្ធិ និងអំណាចអ្វីខ្លះ ដល់ចៅក្រមស៊ើបសួរនៅក្នុងដំណាក់កាលស៊ើបសួរ ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះហេតុផលក្នុងការតាក់តែងអត្ថបទមួយនេះឡើង គឺក្នុងគោលបំណងបង្កើនចំណេះដឹងជាមួយនឹង បទពិសោធន៍ខ្លះ ៗដើម្បីចងក្រងជាឯកសារសម្រាប់ជំនួយស្មារតីដល់អ្នកសិក្សាស្រាវជ្រាវស្វែងយល់ឱ្យបាន កាន់តែច្បាស់អំពី នីតិវិធីនិងតួនាទីនៃការស៊ើបសួរដែលត្រូវបានធ្វើឡើងដោយចៅក្រមស៊ើបសួរ ដូចដែលក្រម នីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិយ៉ាងច្បាស់លាស់។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទស្រាវជ្រាវនេះគឺមានវិសាលភាពគ្របដណ្តប់ទៅលើទ្រឹស្តី និងទិដ្ឋភាពជាក់ស្តែងនៃតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរក្នុងដំណាក់កាលស៊ើបសួរដែលបានបញ្ញត្តិនៅក្នុងក្រមនីតិវិធី ព្រហ្មទណ្ឌឆ្នាំ ២០០៧។ សូមបញ្ជាក់ថា ការស្រាវជ្រាវធ្វើឡើងចាប់ផ្តើមត្រឹមពីការបើកការស៊ើបសួររបស់ចៅក្រម ស៊ើបសួរ និងបញ្ចប់ទៅវិញ ត្រឹមការបិទការស៊ើបសួរដោយការចេញនូវដីកាដំណោះស្រាយរបស់ចៅក្រមស៊ើប សួរ។ បន្ថែមពីលើនេះ យើងនឹងមានការបកស្រាយលើច្បាប់ និងបទដ្ឋានគតិយុត្ត យុទ្ធនាការនិងយន្តការផ្សេងៗ របស់ថ្នាក់ដឹកនាំ ព្រមទាំងសាវតារ និងតុលាការនានា ឱ្យមិត្តអ្នកស្តាប់ អ្នកអានទទួលបានចំណេះដឹងឱ្យបាន ច្រើនពីទិដ្ឋភាពជាក់ស្តែងនាពេលបច្ចុប្បន្ន ក្នុងសង្គមរបស់យើង។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវប្រធានបទស្តីអំពី ចៅក្រមស៊ើបសួរនៅកម្ពុជាបច្ចុប្បន្ន ជាបានផ្តល់អត្ថប្រយោជន៍ជា ច្រើនទាក់ទងនឹង ៖

- បង្កើនចំណេះដឹងផ្នែកច្បាប់ឱ្យកាន់តែល្អប្រសើរ
- ការយល់ដឹងកាន់តែច្បាស់នូវតួនាទីនិងអំណាចរបស់ចៅក្រមស៊ើបសួរក្នុងដំណាក់កាលស៊ើបសួរ ពោលគឺទទួលបានចំណេះដឹងទាក់ទងនឹងការបើក ការបិទ និងវិធានការស្រាវជ្រាវរបស់ចៅក្រមស៊ើប ដែលធ្វើនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលមានដូចជាការសួរចម្លើយ ការស្តាប់ចម្លើយ ការចេញដីកានិង

ការប្រើប្រាស់វិធានការនិន្នាការផ្សេងៗ របស់ចៅក្រមស៊ើបសួរ ដើម្បីធ្វើឱ្យការប្រព្រឹត្តទៅនៃកិច្ចរបស់ខ្លួនដំណើរការទៅដោយរលូន

- ស្វែងយល់កាន់តែច្បាស់អំពីដែនកំណត់ និងវិសាលភាពនៃកាតព្វកិច្ចរបស់ចៅក្រមស៊ើបសួរ។
- បង្កើនភាពជិតស្និទ្ធជាមួយសាស្ត្រាចារ្យណែនាំ
- ទទួលបានការយល់ដឹងអំពីផលវិបាកនិង ចំណុចខ្វះខាតមួយចំនួនទាក់ទងនឹងការអនុវត្តនីតិវិធីរបស់ចៅក្រមស៊ើបសួរក្នុងដំណាក់កាលស៊ើបសួរ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងតាមរយៈការប្រមូលនូវបទដ្ឋានគតិយុត្ត និងឯកសារនានា ដែលទាក់ទងទៅនឹងប្រធានបទ ជាពិសេសគឺផ្តោតសំខាន់ទៅលើក្រមនីតិវិធីព្រហ្មទណ្ឌ ដែលមានចែងអំពីដំណាក់កាលស៊ើបសួរនៃរឿងក្តីព្រហ្មទណ្ឌ។ រាល់ខ្លឹមសារ ក៏ដូចជាការពន្យល់នៅក្នុងអត្ថបទស្រាវជ្រាវ គឺត្រូវប្រាកដថាពិតប្រាកដ ព្រមទាំងមានប្រភពច្បាស់លាស់ ក៏ដូចជាអនុលោមទៅតាមមាត្រាដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ដើម្បីបកស្រាយទៅលើប្រធានបទ "ចៅក្រមស៊ើបសួរនៅកម្ពុជាបច្ចុប្បន្ន" នៃសារណានេះឱ្យកាន់តែស៊ីជម្រៅ និងច្បាស់លាស់ថែមទៀតនោះ យើងនឹងធ្វើការបកស្រាយទៅលើចំណុចសំខាន់ៗដោយបែងចែកជាចំណុចធំៗ និងតូចៗទៅតាមរចនាសម្ព័ន្ធនៃការស្រាវជ្រាវរបស់ពួកយើងនៅចំណុចខាងក្រោមនេះ។

## ៧. រចនាសម្ព័ន្ធ នៃការស្រាវជ្រាវ

ដើម្បីយល់ឱ្យបានច្បាស់ យើងខ្ញុំទាំងពីរនាក់សូមធ្វើការតាក់តែងសារណានេះដោយយោងតាមរចនាសម្ព័ន្ធ ដូចជា អារម្មណ៍កថា សេចក្តីថ្លែងអំណរគុណសេចក្តីផ្តើម និងខ្លឹមសារដែលបានបែងចែកជា បួន ជំពូកដូចជា ជំពូកទី១ ការរំលឹកទ្រឹស្តីទូទៅ ដោយមានការពន្យល់ទៅលើវាក្យសព្ទ ពាក្យគន្លឹះច្បាប់មួយចំនួនដែលចាំបាច់និងសំខាន់ ព្រមទាំងបកស្រាយទៅលើច្បាប់ បទដ្ឋានគតិយុត្តនានាដែលបង្កើតឱ្យមាន ឬជាប់ទាក់ទងនឹងតួនាទី ភារកិច្ច របស់ចៅក្រមស៊ើបសួរផងដែរ។ ម្យ៉ាងវិញទៀត ក្នុងជំពូកទី២ យើងមានលើកយកស្ថានភាពទូទៅក្នុងវិស័យយុត្តិធម៌នៅកម្ពុជា ពាក់ព័ន្ធសាវតានៃតុលាការកម្ពុជា រួមទាំងតុលាការនៅកម្ពុជាបច្ចុប្បន្ន។ ចំណែកជំពូកទី៣ យើងនឹងចូលឱ្យកាន់តែស៊ីជម្រៅជាមួយនឹងខ្លឹមសារប្រធានបទនៃសារណាមួយនេះ ក្នុងការបកស្រាយលើតួនាទីចៅក្រមស៊ើបសួរ។ លើកពីនេះទៅទៀត ចំណុចចុងក្រោយដែលជាជំពូកទី៤ ការលើកយកពីបញ្ហាដែលជាក្តីបារម្ភរបស់តុលាការកម្ពុជា ក៏ដូចជាចៅក្រមស៊ើបសួរ ដែលចាំបាច់តម្រូវឱ្យរកនូវដំណោះស្រាយផងដែរ។

ផ្នែកបញ្ចប់នៃសារណានេះយើងខ្ញុំបានរៀបចំដោយរួមមាន សេចក្តីសន្និដ្ឋាន និងអនុសាសន៍និង រួមបញ្ចូលជាមួយឧបសម្ព័ន្ធផងដែរ។

# ជំពូកទី ១

# រំលឹកទ្រឹស្តីទូទៅ

# ជំពូកទី ១

# រំលឹកទ្រឹស្តី

ដូចយើងបានដឹងហើយថា នៅក្នុងរឿងព្រហ្មទណ្ឌចៅក្រមស៊ើបសួរមានតួនាទីយ៉ាងសំខាន់ ក្នុងការស៊ើបសួរដោយចៅក្រមស៊ើបសួរ ធ្វើការស៊ើបសួរទាំងដាក់បន្ទុកផង និងដោះបន្ទុកផង។ តែមុននឹងសិក្សាកាន់តែស៊ីជម្រៅនូវតួនាទីចៅក្រមស៊ើបសួរ យើងគប្បីសិក្សាជាមុនសិននូវដំណើរដើមទងថា ហេតុអ្វីបានបណ្តាលឱ្យមានចៅក្រមស៊ើបសួរ ? តើច្បាប់និងបទដ្ឋានគតិយុត្តអ្វី ខ្លះដែលចែងអំពីតួនាទី និងកំណត់ពីវិសាលភាពរបស់ចៅក្រមស៊ើបសួរ ព្រមទាំងទ្រឹស្តីមួយចំនួនទៀត ដែលជាដើមចមបណ្តាលឱ្យមានការបង្កើតចៅក្រមស៊ើបសួរនៅក្នុងតុលាការរបស់យើងបច្ចុប្បន្ននេះ។ ជាការពិតណាស់កាលណាមានផល តែងតែមានហេតុដែលជាអ្នកបង្កើត ផលនោះឡើង ដូច្នេះចៅក្រមស៊ើបសួរក៏ដូចគ្នាដែរ ទាល់តែមានការប្រព្រឹត្តបទល្មើស និងការដាក់ទោសមានភាពលម្អៀង មិនមានយុត្តិធម៌ចំពោះទើបមានការបង្កើតឱ្យមានចៅក្រមស៊ើបសួរនេះឡើង ក្នុងគោលបំណងស្វែងរកភស្តុតាង និងស្វែងរកភាពការពិត ភាពយុត្តិធម៌ជូនជនត្រូវចោទ និងជនរងគ្រោះ។

## ផ្នែកទី១៖ វាក្យសព្ទ

វាក្យសព្ទបច្ចេកទេសគួរឱ្យកត់សម្គាល់ ដែលប្រើនៅក្នុងអត្ថបទនេះ មានន័យដូចខាងក្រោម៖

១. ព្រះរាជក្រឹត្យ៖ សេចក្តីសម្រេចដែលធ្វើឡើងដោយព្រះមហាក្សត្រ ឬប្រមុខរដ្ឋ ដើម្បីអនុវត្តន៍ច្បាប់។[2]

២. អនុក្រឹត្យ៖ សេចក្តីប្រកាស ឬបញ្ជាដែលនាយករដ្ឋមន្ត្រីជាអ្នកចុះហត្ថលេខា ដែលមានផលផ្នែកច្បាប់ដូចជាច្បាប់ដែរ។[3]

៣. ប្រព័ន្ធតុលាការ ៖ គឺជាអំណាចមួយក្នុងចំណោមអំណាចទាំងបី ៉រួមទាំងអង្គនីតិប្រតិបត្តិ ( រដ្ឋាភិបាល) និងអង្គនីតិប្បញ្ញត្តិ (រដ្ឋសភា និងព្រឹទ្ធសភា)៉ ដែលអាចបង្កើតដោយរដ្ឋ។ ស្ថាប័ននេះមានតួនាទីតាមដានការអនុវត្តច្បាប់ និងការដាក់ទណ្ឌកម្មចំពោះការរំលោភច្បាប់។[4] អំណាចនេះត្រូវបានប្រគល់ឱ្យចៅក្រម និងរាជអាជ្ញា (ពេលខ្លះនៅក្នុងកម្រិតទាបជាងមុននៅក្នុងគណៈវិនិច្ឆ័យ) ដែលពឹងផ្អែកលើអត្ថបទច្បាប់ (ដែលត្រូវបានរៀបចំឡើងដោយស្ថាប័ននីតិប្បញ្ញត្តិ) ដើម្បីធ្វើការសម្រេចចិត្ត។

---

[2] វចនានុក្រមច្បាប់ ASIA FOUNDATION នៃអង្គការមូលនិធិអាស៊ី

[3] វចនានុក្រមច្បាប់ ASIA FOUNDATION នៃអង្គការមូលនិធិអាស៊ី

[4] Montesquieu, ៉វិញ្ញាណនៃច្បាប់៉ ឆ្នាំ១៧៧៧។

៤.អំណាចតុលាការៈ ថ្លឹង ការស្ទង់ មិនឱ្យលម្អៀង ឬអ្នកស្ទង់តម្រង់សេចក្តី ឬជាក្រសួងជម្រះក្តី ឬចៅក្រមអ្នកវិនិច្ឆ័យក្តី។[5] អំណាចតុលាការ អំណាចឯករាជ្យ រក្សាអានាគតិនិងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផង។[6]

៥.ដីកាៈ បញ្ជាជាលាយលក្ខណ៍អក្សរចេញពីអាជ្ញាធរមានសមត្ថកិច្ច ដែលបង្គាប់ឲ្យចាត់ការនូវអំពើណាមួយ៉ាងជាពិសេស បញ្ជា ដែលបង្គាប់ឲឱ្យចាប់ខ្លួនជនណាម្នាក់ ឬច្រើននាក់ ដែល ចេញដោយតុលាការ, អង្គការ ឬមន្ត្រីផ្លូវការណាម្នាក់ ។[7]

៦. ចៅក្រមៈ មន្ត្រីតុលាការ មន្ត្រីអ្នកជម្រះក្តី ឬជាមន្ត្រីកីឡាដែលទទួលភារកិច្ចប្រកួត និងកំណត់ជ័យលាភី។ សំដៅដល់ចៅក្រមអាសនៈរួមមាន ចៅក្រមជំនុំជម្រះក្តី និងចៅក្រមស៊ើបសួរ។[8]

៧. អង្គចៅក្រម សំដៅដល់ចៅក្រមនិងព្រះរាជអាជ្ញា។[9]

៨. ព្រះរាជអាជ្ញាៈ សំដៅដល់ព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង អគ្គព្រះរាជអាជ្ញា។[10]

៩. ចៅក្រមស៊ើបសួរៈ ចៅក្រមជាសមាជិកអយ្យការដែលទទួលស៊ើបក្តី ហើយបញ្ជូនសំណុំរឿងនោះទៅតុលាការ។ (សម័យដើម គេហៅចៅក្រមស៊ើបសួរ ថា សុភាចារបុរស)។[11]

១០. ឋានន្តរសក្តិៈ អំណាចតាមមុខងារ បណ្តាស័ក្តិធំតូចតាមមុខងារ។[12]

១១. ឆន្ទានុសិទ្ធិ៖ សំដៅដល់ អំណាចដែលច្បាប់ប្រគល់ដល់ចៅក្រមឱ្យរើសយកមធ្យោបាយណាមួយតាមការវាយតម្លៃរបស់ខ្លួនមកដោះស្រាយបញ្ហាណាមួយ ឬអំណាចរបស់ចៅក្រមក្នុងការធ្វើសកម្មភាពក្នុងនីតិវិធីនៃបណ្តឹង ដោយមិនបាច់មានពាក្យសុំរបស់ភាគី។[13]

---

[5] វចនានុក្រមខ្មែរ ឆ្នាំ២០២២

[6] "រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា" ឆ្នាំ២០១៨, មាត្រា ១២៨ ថ្មី ( មាត្រា ១០៩ ចាស់)

[7] វចនានុក្រមច្បាប់ ASIA FOUNDATION នៃអង្គការមូលនិធិអាស៊ី

[8] ច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, មាត្រា ៣

[9] ច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, មាត្រា ៣

[10] ច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, មាត្រា ៣

[11] វចនានុក្រមខ្មែរ ឆ្នាំ២០២២

[12] វចនានុក្រមខ្មែរ ឆ្នាំ២០២២

[13] ដកស្រង់ចេញពី "សន្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែកនីតិវិធីរដ្ឋប្បវេណី" ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅឆ្នាំ២០០៧

១២. ដែនសមត្ថកិច្ច៖ គឺជាតំបន់ ជាមុខងារ និងជាភារកិច្ច ដែលស្ថិតនៅក្រោម សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា។[14]

១៣. ក្រឡាបញ្ជី៖ សំដៅទៅលើអ្នកជំនួយការរបស់សហព្រះរាជអាជ្ញា សហចៅក្រម ស៊ើបអង្កេត និងអង្គជំនុំជម្រះ និង ជាអ្នកទទួលខុសត្រូវ ជាពិសេសក្នុងការ រក្សាទុកនូវរាល់ឯកសារផ្លូវការ នៃការជំនុំជម្រះទទួលយកនូវឯកសារច្បាប់ ដើមពីភាគីទាំងអស់ និងធានាដល់ការជូនដំណឹងរាល់សេចក្ដីសម្រេច។[15]

១៤. វិសាលភាពអនុវត្ត៖ ទំហំនៃការអនុវត្ត ឬសមត្ថកិច្ចនៃការអនុវត្ត។[16]

១៥. ដែនសមត្ថកិច្ច៖ គឺជាតំបន់ ជាមុខងារ និងជាភារកិច្ច ដែលស្ថិតនៅក្រោម សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា។[17]

១៦. អង្គហេតុ៖ រឿងហេតុ ដែលកើតឡើងនាំឱ្យមានបច្ច័យគតិយុត្តជា កំណត់។[18]

១៧.បទល្មើស៖ អំពើប្រឆាំងនឹងរដ្ឋ អំពើដែលនាំឱ្យមានគ្រោះថ្នាក់ដល់សង្គម អំពើប្រឆាំងនឹងច្បាប់ព្រហ្មទណ្ឌជាធរមាន នឹងត្រូវផ្ដន្ទាទោសក្នុងបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។[19]

១៨. ដើមបណ្ដឹងរដ្ឋប្បវេណី៖ សម្ដៅដល់ អ្នកប្ដឹងទាមទារសំណង ឬទាមទារការជួសជុលព្យសនកម្ម ដែល បណ្ដាលមកពីបទល្មើសព្រហ្មទណ្ឌ ឬអ្នកផ្ដួចផ្ដើមដាក់ពាក្យប្ដឹងទៅអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការដើម្បីទាមទារសំណង ឬសុំឲ្យធ្វើការជួសជុលព្យសនកម្ម ដែលបណ្ដាលមកពីបទល្មើសព្រហ្មទណ្ឌ។[20]

---

14 ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្តក្រុង ស្រុកខណ្ឌ និងច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់នេះ

15 សទ្ទានុក្រមនៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(វិសោធនកម្មលើកទី៩) នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥

16 ដកស្រង់ចេញពី «សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែក ព្រហ្មទណ្ឌ» ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួល បន្ទុកអនុម័តពាក្យច្បាប់ និងបោះផ្សាយដោយទីស្ដីការគណៈរដ្ឋមន្ត្រី នៅ ឆ្នាំ២០១១

17 ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្តក្រុង ស្រុកខណ្ឌ និងច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់នេះ

18 ដកស្រង់ចេញពី «សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែក រដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី» ដែលត្រូវបានរៀបចំដោយគណៈ កម្មការបណ្ឌិត្យសភាទទួល បន្ទុកអនុម័តពាក្យច្បាប់ និងបោះផ្សាយដោយ ទីស្ដីការគណៈរដ្ឋមន្ត្រី នៅឆ្នាំ២០០៧

19 ដកស្រង់ចេញពី «សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែក ព្រហ្មទណ្ឌ» ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួល បន្ទុកអនុម័តពាក្យច្បាប់ និងបោះផ្សាយដោយទីស្ដីការគណៈរដ្ឋមន្ត្រី នៅ ឆ្នាំ២០១១

20 ដកស្រង់ចេញពី «សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែក ព្រហ្មទណ្ឌ» ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួល បន្ទុកអនុម័តពាក្យច្បាប់ និងបោះផ្សាយដោយទីស្ដីការគណៈរដ្ឋមន្ត្រី នៅ ឆ្នាំ២០១១

១៩. ជនត្រូវចោទ៖ សំដៅទៅលើបុគ្គលណាម្នាក់ ដែលត្រូវចោទប្រកាន់ចំពោះរឿងក្តីណាមួយ ក្នុងចន្លោះពេលពីមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ រហូតដល់ដីកាបញ្ជូន រឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងចោទប្រកាន់។[21]

២០. ជនជាប់ចោទ៖ សំដៅទៅលើបុគ្គលណាម្នាក់ ដែលត្រូវចោទប្រកាន់ ចំពោះរឿងក្តីណាមួយក្នុងចន្លោះពេលពី មានដីកា សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ រហូតដល់ដីកាបញ្ជូន រឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងចោទប្រកាន់។[22]

២១. ជនរងគ្រោះ៖ តាមន័យក្រមព្រហ្មទណ្ឌ ជនទទួលរង ដោយផ្ទាល់នូវ ព្យសនកម្មដែលបណ្តាលមកពីបទល្មើសព្រហ្មទណ្ឌ។ តាមន័យទូទៅ ជនទទួលរងការឈឺចាប់ ដោយ អំពើខុសច្បាប់ដែលនាំឱ្យខូចសេចក្តី ថ្លៃថ្នូរ កិត្តិយស បញ្ញាស្មារតី រូបរាងកាយ ឬទ្រព្យសម្បត្តិរបស់ខ្លួន ។[23]

## ផ្នែកទី២៖ ច្បាប់ និងបទដ្ឋានគតិយុត្ត

មុននឹងឈានទៅដល់ការបកស្រាយនូវទាក់ទិននឹងចៅក្រមស៊ើបសួរ ត្រូវធ្វើការយល់ច្បាស់ ពីច្បាប់ឬបទដ្ឋានគតិយុត្តមួយចំនួន ដែលបង្កើតឱ្យមានតំណែងមួយនៅក្រុមជួរអំណាចតុលាការដែលមានឈ្មោះថាចៅក្រមអាសនៈ ឬហៅថាចៅក្រមស៊ើបសួរនេះឯង ព្រមទាំងបានកំណត់អំពីភារកិច្ច និងសិទ្ធិអំណាចមួយចំនួនរបស់ចៅក្រមស៊ើបសួរបច្ចុប្បន្ននៅកម្ពុជាអាចធ្វើទៅបាន។ យើងនឹងលើកយកច្បាប់ចំនួន ៣ ហៅថាច្បាប់ខួបទាំងបី ដែលជាច្បាប់ បង្កើតឱ្យមានអង្គការតុលាការ និងធ្វើឱ្យអង្គការតុលាការ មានដំណើរការប្រព្រឹត្តទៅបានរលូន ក្នុងនោះរួមមានការកំណត់ពីលក្ខន្តិកៈរបស់ចៅក្រម និងព្រះរាជអាជ្ញា រួមបញ្ចូលជាមួយនឹងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមផងដែរ។ ច្បាប់ខួបទាំងបីនោះរួមមាន ច្បាប់ស្តីពីការរៀបចំអង្គការតុលាការច្បាប់ស្តីពីលក្ខន្តិកៈ ចៅក្រមនិងព្រះរាជអាជ្ញា និងច្បាប់រៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺជាប្រភេទច្បាប់រៀបចំអង្គការ ដ៏មានសារៈសំខាន់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សំដៅពង្រឹងឯករាជ្យនៃអំណាចតុលាការ និងធានាឱ្យអង្គការតុលាការមានកិច្ចដំណើរការប្រព្រឹត្តទៅបានល្អប្រសើរ ក្នុងការលើកកម្ពស់ការបម្រើជូនប្រជាពលរដ្ឋស្របតាមគោលការណ៍នៃនីតិរដ្ឋ។[24] ច្បាប់ខួបទាំងបីនេះបានប្រសូតដោយក្រសួងធម៌ ដោយឆ្លងកាត់ការប្រជុំជាច្រើនលើកច្រើនសា ជាពិសេសការពិគ្រោះយោបល់ជាមួយឧត្តមក្រុម

---

[21] សទ្ធានុក្រមនៃវិធានផ្នែកក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(វិសោធនកម្មលើកទី៩) នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥

[22] សទ្ធានុក្រមនៃវិធានផ្នែកក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជា(វិសោធនកម្មលើកទី៩) នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥

[23] ដកស្រង់ចេញពី "សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែកនីតិវិធីរដ្ឋប្បវេណី" ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅឆ្នាំ២០១១

[24] ចំណាប់អារម្មណ៍របស់ ឯកឧត្តម អង្គ វង្សវឌ្ឍនា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ប្រឹក្សានៃអង្គចៅក្រម និងការផ្តល់យោបល់របស់ក្រសួង ស្ថាប័ននានា បានធ្វើសេចក្តីព្រាងច្បាប់ខួបទាំងបីនេះឡើង បានផ្តល់នូវសារៈសំខាន់និងការយកចិត្តទុកដាក់ជាអាទិភាពដល់ការរៀបចំសេចក្តីព្រាងច្បាប់គោលទាំងបីនេះឱ្យបានឆាប់រហ័សដោយត្រូវគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយអំពីគោលការណ៍គ្រឹះទាំងឡាយ ដើម្បីធានានូវឯករាជ្យនៃអំណាចតុលាការស្របតាមបទដ្ឋានអន្តរជាតិ ព្រមទាំងមានការប្រសើរឡើងនូវដំណើរការការងាររបស់តុលាការក្នុងការយុត្តិធម៌សម្រាប់សាធារណៈជន។[25]

## ២.១. ច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ

ច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ និងរដ្ឋសភាបានអនុម័ត ពីថ្ងៃទី ២២ ខែឧសភាឆ្នាំ ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើ ទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របតាម នឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៤៩/០០៣/២០១៤ កបធ.ច ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤។ [26]

➢ **ច្បាប់នេះមានគោលបំណង៖**[27]

- ធានាឯករាជ្យនៃអំណាចតុលាការ
- ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ - ធានាឱ្យមានកិច្ចដំណើរការល្អរបស់អង្គការតុលាការ និងអង្គការអយ្យការ លើកកម្ពស់សេវាសាធារណៈឱ្យមានប្រសិទ្ធភាព និងឆាប់រហ័ស
- ធានាក្នុងការផ្តល់យុត្តិធម៌លើរឿងក្តីគ្រប់ប្រភេទ ដើម្បីបង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋ និង រួមចំណែកពង្រឹងសុវត្ថិភាពសង្គម ។

➢ **ច្បាប់នេះមានគោលដៅ៖**[28]

- កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការតុលាការគ្រប់ផ្នែកនិងគ្រប់ជាន់ថ្នាក់ដែលជាសាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា
- កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ ថ្នាក់នៃព្រះរាជាណាចក្រកម្ពុជា

[25] ចំណាប់អារម្មណ៍របស់ ឯកឧត្តម អង្គ វង្សវឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
[26] ឆ្នាំទី១៤ លេខ៤៥ សប្តាហ៍ទី៤ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៤ រាជកិច្ចទំព័រ៦៦០០
[27] មាត្រា១ នៃច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ
[28] មាត្រា២ នៃច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ

- កំណត់អំពីសមត្ថកិច្ចរបស់តុលាការគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ទៅតាមជំនាញ រៀបចំការងារគ្រប់គ្រងការងាររដ្ឋបាល និងដំណើរការប្រព្រឹត្តទៅរបស់តុលាការ ។

ចំពោះសាលាជម្រះក្ដីនៅកម្ពុជានៃព្រះរាជាណាចក្រកម្ពុជាមានចែងក្នុងច្បាប់នេះ រួមមាន[29]

- សាលាដំបូង
- សាលាឧទ្ធរណ៍
- តុលាការកំពូល។

សាលាដំបូង ជាសាលាជម្រះក្ដីជាន់ទាប សាលាឧទ្ធរណ៍និងតុលាការកំពូល ជាសាលាជម្រះក្ដីជាន់ខ្ពស់។

សាលាជម្រះក្ដីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់អនុវត្តអំណាចតុលាការដែលគ្របដណ្ដប់លើរឿងក្ដីទាំងអស់ រួមទាំងរឿងក្ដីរដ្ឋបាលផង។[30] ចំពោះការបើកសវនាការត្រូវធ្វើឡើងជាសាធារណៈ លើកលែងតែសាធារណភាពនេះអាចបង្កឱ្យមានគ្រោះថ្នាក់ដល់សណ្ដាប់ធ្នាប់សាធារណៈ ឬដល់ទំនៀមទម្លាប់ ឬមានបទប្បញ្ញត្តិពិសេសក្នុងច្បាប់ចែងផ្សេងពីនេះ។ ហើយនៅគ្រប់ករណីទាំងអស់ សាលក្រម និងសាលដីកាតុលាការត្រូវប្រកាសនៅក្នុងសាលសវនាការ ដែលបើកជាសាធារណៈផងដែរ។ ប៉ុន្តែការពិភាក្សាសម្រេចសេចក្ដីរបស់អង្គជំនុំជម្រះ ត្រូវធ្វើជាសម្ងាត់។ ចំណែកការប្រកាសសាលក្រម លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះ ការប្រកាសសាលក្រមសាលដីការបស់តុលាការ ត្រូវធ្វើដោយប្រធានអង្គជំនុំជម្រះ ឬចៅក្រមមួយរូបក្នុងចំណោមចៅក្រមដែលជាសមាសភាពនៃអង្គជំនុំជម្រះ។ គ្រប់សាលក្រមនិងសាលដីកាតុលាការត្រូវមានសម្អាងហេតុ។ ម្យ៉ាងវិញទៀតសាលក្រមនិង សាលដីកា ត្រូវចុះហត្ថលេខាដោយប្រធានអង្គជំនុំជម្រះ និងចុះហត្ថលេខាអមដោយក្រឡាបញ្ជីនៃសវនាការលើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះបានកំណត់។ បន្ថែមពីនេះ នៅគ្រប់តុលាការនីមួយៗទាំងថ្នាក់ទាប និងថ្នាក់ខ្ពស់ត្រូវមានអង្គការអយ្យការអមតុលាការនោះ។ នៅអមសាលាដំបូង ត្រូវមានអង្គការអយ្យការមួយ ហៅថា អយ្យការអមសាលាដំបូង។ ចំពោះសាលាឧទ្ធរណ៍ និងតុលាការកំពូល ក៏ត្រូវមានអង្គការអយ្យការអមសាលាឧទ្ធរណ៍ និងតុលាការកំពូលដែរ ហៅថា មហាអយ្យការអមសាលាឧទ្ធរណ៍ និងមហា

[29] មាត្រា៣ នៃច្បាប់ ស្ដីពីការរៀបចំអង្គការតុលាការ

[30] មាត្រា៤ នៃច្បាប់ ស្ដីពីការរៀបចំអង្គការតុលាការ

អយ្យការអមតុលាការកំពូល។ ចំពោះ តំណាងអង្គការអយ្យការ ត្រូវមានវត្តមាននៅគ្រប់សវនាការទាំងអស់នៃរឿងក្តីព្រហ្មទណ្ឌនិងរឿងក្តីផ្សេងៗទៀត ដែលច្បាប់បានកំណត់។[31]

ក្រៅពីនេះច្បាប់ស្តីពីការរៀបចំអង្គការតុលាការនេះមាន ៨ ជំពូកនិង ៩១ មាត្រា រួមមាន ជំពូកទី១៖ បទប្បញ្ញត្តិទូទៅ ជំពូកទី២៖ សាលាដំបូង និងអយ្យការអមសាលាដំបូង ជំពូកទី៣៖ សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ជំពូកទី៤៖ តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល ជំពូកទី៥៖ វិសមិតភាព ជំពូកទី៦៖ ថវិកាសាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តី ជំពូកទី៧៖ អន្តរប្បញ្ញត្តិ និងជំពូកទី៨៖ អវសានប្បញ្ញត្តិ។ [32]

## ២.២ ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា

ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញាត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស / រកម /០៧១៤ /០១៦ និងរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៥ ហើយ ដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី ៥ នីតិកាលទី ៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របតាមនឹងរដ្ឋធម្មនុញ្ញក្នុងសេចក្តីសម្រេចលេខ ១៩៧/001/២០១៤ កបធ.ច ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤។[33]

- **ច្បាប់នេះមានគោលបំណង៖**[34]

ច្បាប់នេះកំណត់ពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញាព្រមទាំងគោលការណ៍ផ្សេងៗទៀតទាក់ទងនឹងចៅក្រមនិងព្រះរាជអាជ្ញាក្នុងគោលបំណងធានាឯករាជ្យនៃអំណាចតុលាការស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

- **ច្បាប់នេះមានវិសាលភាព៖**[35]

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះចៅក្រមនិងព្រះរាជអាជ្ញាទូទាំងព្រះរាជាណាចក្រកម្ពុជាលើកលែងតែមានច្បាប់ដោយឡែកកំណត់ផ្សេងពីនេះ។ មួយវិញទៀតចៅក្រមនិងព្រះរាជអាជ្ញាមិនទទួលមិនត្រូវ

[31] មាត្រា៥ នៃច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ
[32] សរុបជំពូកទាំងអស់នៃច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ
[33] ប្រកាសឱ្យប្រើនៃច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រមនិងព្រះរាជអាជ្ញា
[34] មាត្រា១ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
[35] មាត្រា២ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា

ទទួលខុសត្រូវខាងបទព្រហ្មទណ្ឌឬបទរដ្ឋប្បវេណីណាមួយចំពោះការសម្រេចដែលបានធ្វើក្នុងក្របខណ្ឌសមត្ថកិច្ច និងមុខងាររបស់ខ្លួនជាចៅក្រមព្រះរាជអាជ្ញាឡើយ។ ប៉ុន្តែគោលការណ៍នេះមិនត្រូវយកមកអនុវត្តឡើយ ក្នុងករណីដែលចៅក្រម ឬព្រះរាជអាជ្ញាប្រើប្រាស់ការសម្រេចនោះដោយរំលោភបំពានធ្ងន់ធ្ងរ ក្នុងចេតនាទុច្ចរិតលើសមត្ថកិច្ចនិងមុខងារដែលច្បាប់ប្រគល់ឱ្យ។[36] ចំណែកក្របខ័ណ្ឌចៅក្រមវិញរូបមានបី ៣ ឋានន្តរស័ក្តិ គឺ ឧត្តមចៅក្រម វរចៅក្រម និងអនុចៅក្រម។ ថ្នាក់សម្រាប់ឋានន្តរស័ក្តិឧត្តមចៅក្រម ឋានន្តរស័ក្តិវរចៅក្រម និងឋានន្តរស័ក្តិអនុចៅក្រម ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។[37] ចំពោះក្របខ័ណ្ឌរបស់ព្រះរាជអាជ្ញាក៏មាន ៣ ឋានន្តរស័ក្តិដូចគ្នា គឺ ឧត្តមព្រះរាជអាជ្ញា វរៈព្រះរាជអាជ្ញា និងអនុព្រះរាជអាជ្ញា។[38] ចៅក្រម និងព្រះរាជអាជ្ញាទាំងអស់ស្ថិតនៅក្នុងរដ្ឋបាលកណ្តាលរបស់យុត្តិធម៌ និងអាចចាត់ឱ្យបំពេញការងារនៅក្រសួងយុត្តិធម៌បាន។ ករណីត្រូវបំពេញការងារនៅក្រសួងយុត្តិធម៌ ចៅក្រមត្រូវស្នើសុំការយល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ នៅក្នុងអាជីពរបស់ខ្លួន ចៅក្រមអាចត្រូវបានតែងតាំងជាព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាក៏អាចត្រូវបានតែងតាំងជាចៅក្រមវិញបានដែរ។

ចំពោះចៅក្រមត្រូវបានអនុញ្ញាតឱ្យប្រឡងជ្រើសរើសជាសិស្សចៅក្រមចំពោះបេក្ខជនដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោមៈ[39]

១- ត្រូវមានសញ្ជាតិខ្មែរកំណើត

២- មានអាយុ ៣៥ (សាមសិបប្រាំ) ឆ្នាំ យ៉ាងច្រើនចំពោះបេក្ខជនជានិស្សិត និងមានអាយុ ៤០ (សែសិប) ឆ្នាំយ៉ាងច្រើនចំពោះបេក្ខជនជាមន្ត្រីរាជត្រូវមានសញ្ញាបត្រចាប់ការគិតមកដល់ត្រឹមថ្ងៃប្រឡង

៣- ត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ

៤- មិនដែលមានទោសពីបទមជ្ឈិមឬបទឧក្រិដ្ឋ

៥- ត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន។

---

[36] មាត្រា៦ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា

[37] មាត្រា១០,១១ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា

[38] មាត្រា៧៨ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា

[39] មាត្រា១៩ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា

ការជ្រើសរើសបញ្ចូលក្នុងក្របខណ្ឌចៅក្រមអាចធ្វើឡើងតាមរយៈការប្រកួតប្រជែងផ្ទៃក្នុងពីក្នុងចំណោមមន្ត្រីរាជការ និងក្រឡាបញ្ជី ដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ និងមានបទពិសោធន៍ក្នុងវិស័យច្បាប់ ឬយុត្តិធម៌យ៉ាងតិច ៥ ឆ្នាំ ហើយដែលមានអាយុមិនលើសពី ៤៥ (សែសិបប្រាំ) ឆ្នាំ គិតមកដល់ត្រឹមថ្ងៃប្រឡង។ មេធាវីដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ និងបានបំពេញវិជ្ជាជីវៈរបស់ខ្លួនយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ អាចចុះឈ្មោះចូលរួមប្រឡងប្រជែង តាមប្បញ្ញត្តិនៃវាក្យខណ្ឌទី១ ខាងលើនេះបាន ប្រសិនបើមេធាវីនោះ មានអាយុមិនលើសពី៤៥ (សែសិបប្រាំ) ឆ្នាំ គិតមកដល់ត្រឹមថ្ងៃប្រឡង។[40]

ចំពោះការជ្រើសរើសព្រះរាជអាជ្ញា តម្រូវជ្រើសរើសនិងបណ្តុះបណ្តាលព្រះរាជអាជ្ញា ត្រូវអនុវត្តរួមគ្នាជាមួយនឹងការជ្រើសរើសនិងបណ្តុះបណ្តាលចៅក្រមដែរ។ ព្រះរាជអាជ្ញាដែលបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈដោយជោគជ័យត្រូវតែងតាំងដោយព្រះរាជក្រឹត្យជាព្រះរាជអាជ្ញាកម្មសិក្សាឋានន្តរស័ក្តិ ជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ។ ព្រះរាជអាជ្ញាកម្មសិក្សាត្រូវធ្វើការសិក្សារយៈពេល១ (មួយ) ឆ្នាំគិតចាប់ពីការបរិច្ឆេទនៃការតែងតាំង។ ការធ្វើកម្មសិក្សារបស់ព្រះរាជអាជ្ញាកម្មសិក្សាត្រូវកំណត់ដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពីគ្រោះយោបល់ជាមួយសមាជិកទាំងអស់ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។[41]

ក្រៅពីនេះ ច្បាប់ស្តីពីលក្ខន្តិកៈ នៃចៅក្រម និងព្រះរាជអាជ្ញានេះមាន ៦ ជំពូកនិង ១១១ មាត្រា រួមមានជំពូកទី១៖ បទប្បញ្ញត្តិរួម ជំពូកទី២៖ ចៅក្រម ជំពូកទី៣៖ ព្រះរាជអាជ្ញា ជំពូកទី៤៖ វិសមិតភាព ជំពូកទី៥៖ អន្តរប្បញ្ញត្តិ និងជំពូកទី៦៖ អវសានប្បញ្ញត្តិ។[42]

### ២.៣. ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស /រកម /០៧១៤ /០១៧ និងរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៥ ហើយ ដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី ៥ នីតិកាលទី ៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របតាមនឹងរដ្ឋធម្មនុញ្ញក្នុងសេចក្តីសម្រេចលេខ ១៤៨/00២/២០១៤ កបធ.ច ចុះថ្ងៃទី0២ ខែកក្កដា ឆ្នាំ២០១៤។[43]

[40] មាត្រា២៣ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា

[41] មាត្រា៨២ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា

[42] សរុបជំពូកទាំងអស់នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា

[43] ប្រកាសឱ្យប្រើនៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

- **ច្បាប់នេះមានគោលដៅ៖**[44]

ច្បាប់នេះ មានគោលដៅបង្កើត និងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ក្នុងគោលបំណងជួយព្រះមហាក្សត្រ ដើម្បីធានាឯករាជ្យនៃអំណាច តុលាការស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

- **ច្បាប់នេះមានវិសាលភាព៖**[45]

ច្បាប់នេះ មានវិសាលភាពអនុវត្តទៅលើចៅក្រម និងព្រះរាជអាជ្ញា ទូទាំងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានច្បាប់ដោយឡែកកំណត់ផ្សេងពីនេះ ។

សមាជិកជ្រើសតាំងនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានអាណត្តិ ៥ (ប្រាំ) ឆ្នាំ ហើយបញ្ចប់នៅពេលសមាជិកជ្រើសតាំងថ្មី ត្រូវបានតែងតាំង។ សមាជិកជ្រើសតាំងនៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រមអាចឈរឈ្មោះជាថ្មីសម្រាប់អាណត្តិបន្តបន្ទាប់ទៀតបាន។ ការបោះឆ្នោតជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចាប់ផ្ដើមរៀបចំរយៈពេល ៩០ (កៅសិប) ថ្ងៃមុនបញ្ចប់អាណត្តិនីមួយៗ។ ម្យ៉ាងវិញទៀតឧត្តមក្រុមនៃអង្គចៅក្រមអាចសម្រេចដកតំណែងសមាជិកជ្រើសតាំងណាម្នាក់របស់ខ្លួនបាន ដោយមូលហេតុនៃការរំលោភបំពានធ្ងន់ធ្ងរលើ បទបញ្ញារបស់ខ្លួន ឬការធ្វើសកម្មភាពនានាដែលនាំឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់កិត្តិយស និងសេចក្ដីថ្លៃថ្នូរឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ការសម្រេចដកសមាជិកជ្រើសតាំងរបស់ក្រុមប្រឹក្សានៃអង្គចៅក្រមណាមួយ តម្រូវឱ្យមានការយល់ព្រមពីសមាជិកចំនួនយ៉ាងតិច ៨ (ប្រាំបី) រូបនៃចំនួនសមាជិកទាំងមូល។ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលត្រូវបានតុលាការផ្ដន្ទាទោសដាក់ពន្ធនាគារ ឬគ្មានការព្យួរទោសពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិមដែលប្រព្រឹត្តដោយចេតនា ត្រូវដកចេញពីមុខតំណែងដោយស្វ័យប្រវត្តិ។ សមាជិកថ្មីដែលត្រូវចូលកាន់តំណែងជំនួស ត្រូវអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ។[46] បន្ថែមពីនេះព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមគឺព្រះមហាក្សត្រ ទ្រង់អាចចាត់តាំងព្រះរាជតំណាងម្នាក់របស់ព្រះអង្គឱ្យធ្វើជាអធិបតី នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបាន។ ព្រះរាជតំណាងដែលទទួលបានការចាត់តាំង ដឹកនាំ និងចាត់ចែងការងាររបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវរាយការណ៍ឱ្យបានទៀងទាត់ អំពីសកម្មភាពរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ថ្វាយព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ព្រះរាជតំណាងមិនអាចចូលរួមក្នុងការធ្វើសេចក្ដីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឡើយ។ ប៉ុន្តែ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬប្រធានតុលាការកំពូល

[44] មាត្រា១ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

[45] មាត្រា២ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

[46] មាត្រា៥ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ត្រូវបានចាត់តាំងជាព្រះរាជតំណាង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬប្រធានតុលាការកំពូលមានសិទ្ធិចូលរួមធ្វើសេចក្ដីសម្រេច របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដូចសមាជិកដទៃទៀតដែរ។[47]

- **សមាសភាពឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម**[48]

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ និងរួមមានសមាសភាពដូចខាងក្រោម ៖

១- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាសមាជិក

២- ប្រធានតុលាការកំពូល ជាសមាជិក

៣- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ជាសមាជិក

៤- សមាជិក ១ (មួយ) រូប ជ្រើសតាំងដោយព្រឹទ្ធសភា តាមមតិភាគច្រើនដាច់ខាតនៃ សមាជិកព្រឹទ្ធសភាទាំងមូល ក្នុងចំណោមឥស្សរជនជាអតីតចៅក្រម ឬអតីតព្រះរាជអាជ្ញា ឬឥស្សរជន ដែលមានបទពិសោធន៍ការងារ យ៉ាងតិច ១៥ ឆ្នាំ ឡើងទៅ ក្នុងវិស័យច្បាប់ ឬតុលាការ

៥- សមាជិក ១ (មួយ) រូប ជ្រើសតាំងដោយរដ្ឋសភា តាមមតិភាគច្រើនដាច់ខាតនៃ សមាជិករដ្ឋសភាទាំងមូល ក្នុងចំណោមឥស្សរជនជាអតីតចៅក្រម ឬអតីតព្រះរាជអាជ្ញា ឬឥស្សរជន ដែលមានបទពិសោធន៍ការងារ យ៉ាងតិច ១៥ ឆ្នាំ ឡើងទៅ ក្នុងវិស័យច្បាប់ ឬតុលាការ

៦- សមាជិក ១ (មួយ) រូប ជ្រើសតាំងដោយក្រុមប្រឹក្សាធម្មនុញ្ញ តាមមតិភាគច្រើនដាច់ ខាតនៃសមាជិកទាំងមូល ក្នុងចំណោមឥស្សរជនជាអតីតចៅក្រម ឬអតីតព្រះរាជអាជ្ញា ឬឥស្សរជន ដែលមានបទពិសោធន៍ការងារ យ៉ាងតិច ១៥ ឆ្នាំ ឡើងទៅ ក្នុងវិស័យច្បាប់ ឬតុលាការ

៧- សមាជិក ១ (មួយ) រូប ជ្រើសតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងចំណោម ព្រះរាជអាជ្ញាពេញសិទ្ធិទាំងអស់

៨- សមាជិក ១ (មួយ) រូប ជាចៅក្រមនៃសាលាជម្រះក្ដីជាន់ខ្ពស់ ជ្រើសតាំងតាមការ បោះឆ្នោតដោយចៅក្រមនៃសាលាជម្រះក្ដីជាន់ខ្ពស់

[47] មាត្រា៧ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

[48] មាត្រា៤ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

៩- សមាជិក១ (មួយ) រូប ជាព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាជម្រះក្តីជាន់ ខ្ពស់ ឬព្រះរាជអាជ្ញាបម្រើការងារនៅក្រសួងយុត្តិធម៌ ជ្រើសតាំងតាមការបោះឆ្នោតដោយព្រះរាជអាជ្ញា បម្រើការងារនៅមហាអយ្យការអមសាលាជម្រះក្តីជាន់ខ្ពស់ និងនៅក្រសួងយុត្តិធម៌

១០ -សមាជិក ១ (មួយ) រូប ជាចៅក្រមពេញសិទ្ធិនៃសាលាដំបូង ជ្រើសតាំងតាមការ បោះឆ្នោតដោយចៅក្រមពេញសិទ្ធិនៃសាលាដំបូងទូទាំងប្រទេស។

១១- សមាជិក ១(មួយ) រូប ជាព្រះរាជអាជ្ញាពេញសិទ្ធិនៃអយ្យការអមសាលាដំបូង ជ្រើសតាំងតាមការបោះឆ្នោតដោយព្រះរាជអាជ្ញាពេញសិទ្ធិ នៃអយ្យការអមសាលាដំបូងទូទាំងប្រទេស ។

សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទាំងអស់ខាងលើ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រចំពោះកិច្ចការនេះ ។

បែបបទ និងនីតិវិធីនៃការបោះឆ្នោតជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដូច មានក្នុងចំណុចទី ៨ ដល់ចំណុចទី ១១ នៃមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង យុត្តិធម៌ បន្ទាប់ពីទទួលបានការឯកភាពពីសមាជិកភាគច្រើននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ក្រៅពីនេះ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នេះមាន ៦ ជំពូក និង ៣០ មាត្រា រួមមាន ជំពូកទី១៖ បទប្បញ្ញត្តិទូទៅ ជំពូកទី២៖ ការរៀបចំឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ជំពូកទី៣៖ កិច្ចដំណើរការនៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ជំពូកទី៤៖ សមត្ថកិច្ចរបស់ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ជំពូកទី៥៖ អន្តរប្បញ្ញត្តិ និងជំពូកទី៦៖ អវសានប្បញ្ញត្តិ។[49]

[49] សរុបជំពូកទាំងអស់នៃមាត្រា៤ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

# ជំពូកទី២

# ស្ថានភាពទូទៅក្នុងវិស័យយុត្តិធម៌នៅកម្ពុជា

# ជំពូកទី២

# ស្ថានភាពទូទៅក្នុងវិស័យយុត្តិធម៌ នៅកម្ពុជា

## ផ្នែកទី១៖ សាវតារនៃតុលាការកម្ពុជា[50]

ប្រទេសកម្ពុជាត្រូវបានធ្លាក់ចូលក្នុងគ្រោះមហន្តរាយដ៏ធំធេងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី១៧ ខែមេសាឆ្នាំ១៩៧៥ ដល់ថ្ងៃ៦ខែមករាឆ្នាំ១៩៧៩ ដែលប្រជាជនកម្ពុជាស្គាល់ជាទូទៅថា"របបប៉ុលពត" ដែលក្នុងរយៈពេល៣ឆ្នាំនៃរបបនេះអ្វីៗត្រូវបានបំផ្លិចបំផ្លាញទាំងស្រុងក្នុងនោះប្រព័ន្ធតុលាការក៏ត្រូវបានលុបបំបាត់ចោលទាំងស្រុងដែរ។ ក្រោយរំដោះថ្ងៃទី៧ខែមករាឆ្នាំ១៩៧៩ កម្ពុជាបានចាប់ផ្តើមកសាងប្រទេសរបស់ខ្លួនពីបាតដៃទទេហើយនៅអំឡុងឆ្នាំ១៩៨២ ដែលប្រទេសកម្ពុជានាពេលនោះមានឈ្មោះថា សាធារណរដ្ឋប្រជាមានិតកម្ពុជាបានសំរេចបង្កើតតុលាការប្រជាជនខេត្ត-ក្រុង ដែលជាតុលាការមានតែមួយថ្នាក់ប៉ុណ្ណោះ។ ចំពោះតុលាការកំពូលនិងមហាអយ្យការអមតុលាការកំពូលទើបតែត្រូវបានបង្កើតឡើងតាមច្បាប់ស្តីពីការបង្កើតតុលាការប្រជាជនកំពូលនិងមហាអយ្យការអមតុលាការប្រជាជនកំពូលដែលត្រូវបានប្រកាសឲ្យប្រើតាមក្រឹត្យលេខ២៨ក្រចុះថ្ងៃទី៣១ខែកក្កដាឆ្នាំ១៩៨៥។ បន្ទាប់មកនៅឆ្នាំ១៩៨៧ មានច្បាប់មួយទៀតពាក់ព័ន្ធនឹងតុលាការកំពូលនេះ[51] ដែលនិយាយពីការចាត់តាំងនិងសកម្មភាពរបស់តុលាការប្រជាជនកំពូលនិងមហាអយ្យការអមតុលាការប្រជាជនកំពូល។

ចំពោះច្បាប់ទាំង៣[52]ខាងលើដែលពាក់ព័ន្ធនឹងតុលាការកំពូលនិងមហាអយ្យការអមតុលាការកំពូលនេះមានមាត្រាមួយចំនួនធំត្រូវបាននិរាករណ៍ដោយច្បាប់ក្រោយៗផង និងដោយច្បាប់ផ្សេងៗផង ជាពិសេសគឺមាត្រាទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហានីតិវិធីដោយសារមានក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ និងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦មកជំនួស រីឯរចនាសម្ព័ន្ធការងារគឺរក្សាដដែល។ នៅក្នុងឆ្នាំ២០១៤ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម,និងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញាត្រូវបានអនុម័តដែលជាកំណែទម្រង់ស៊ីជម្រៅមួយនៃប្រព័ន្ធយុត្តិធម៌ក្នុងការពង្រឹងនីតិរដ្ឋ , ប្រជាធិបតេយ្យ , ការការពារសិទ្ធិមនុស្ស , ពង្រឹងឯករាជ្យភាព និងអព្យាក្រឹតភាពក្នុងប្រព័ន្ធតុលាការនិងរៀបចំបង្កើតឲ្យមានតុលាការជំនាញស្ថិតក្នុងសាលាដំបូងនីមួយៗ និងសភាជំនាញនៅតាមសាលាឧទ្ធរណ៍ និងតុលាការកំពូលសម្រាប់រឿងក្តីតាមជំនាញនីមួយៗ, និងរៀបចំបង្កើតអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការសម្រាប់សាលាឧទ្ធរណ៍និងតុលាការកំពូលនិងលេខាធិការដ្ឋានរដ្ឋបាលតុលាការសម្រាប់សាលាដំបូងនីមួយៗ។

---

[50] ប្រវត្តិសង្ខេបនៃការបង្កើតតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល ចេញដោយតុលាការកំពូលនិងមហាអយ្យការ

[51] ក្រឹត្យ-ច្បាប់លេខ ៣៤ក្រ.ចស្តីពីការចាត់តាំងនិងសកម្មភាពរបស់តុលាការប្រជាជនកំពូលនិងមហាអយ្យការអមតុលាការប្រជាជនកំពូល

[52] ច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សាអង្គចៅក្រម, ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា

## ផ្នែកទី២៖ តុលាការនៅកម្ពុជាបច្ចុប្បន្ន

- សាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា រួមមាន[53]៖
  - សាលាដំបូង
  - សាលាឧទ្ធរណ៍
  - តុលាការកំពូល ។

  អំណាចតុលាការត្រូវបានអនុវត្តតាមរយៈសាលាជម្រះក្តី ដែលត្រូវបានបែងចែកជាពីរជាន់ គឺ សាលាជម្រះក្តីជាន់ទាប មានសាលាដំបូង និងសាលាជម្រះក្តីជាន់ខ្ពស់ មានសាលាឧទ្ធរណ៍ និង តុលាការកំពូល។
- ព្រះរាជាណាចក្រកម្ពុជាមានសាលាដំបូងចំនួន២៣ រាជធានី-ខេត្ត គឺ រួមមាន៖
  1. សាលាដំបូងរាជធានីភ្នំពេញ
  2. សាលាដំបូងខេត្តកណ្តាល
  3. សាលាដំបូងខេត្តកំពង់ធំ
  4. សាលាដំបូងខេត្តកោះកុង
  5. សាលាដំបូងខេត្តកំពង់ចាម
  6. សាលាដំបូងខេត្តកំពង់ឆ្នាំង
  7. សាលាដំបូងខេត្តក្រចេះ
  8. សាលាដំបូងខេត្តតាកែវ
  9. សាលាដំបូងខេត្តបន្ទាយមានជ័យ
  10. សាលាដំបូងខេត្តកំពង់ស្ពឺ
  11. សាលាដំបូងខេត្តបាត់ដំបង
  12. សាលាដំបូងខេត្តកំពត-កែប
  13. សាលាដំបូងខេត្តប៉ៃលិន
  14. សាលាដំបូងខេត្តពោធិ៍សាត់
  15. សាលាដំបូងខេត្តព្រៃវែង
  16. សាលាដំបូងខេត្តព្រះវិហារ
  17. សាលាដំបូងខេត្តព្រះសីហនុ
  18. សាលាដំបូងខេត្តមណ្ឌលគិរី
  19. សាលាដំបូងខេត្តរតនគិរី
  20. សាលាដំបូងខេត្តសៀមរាប
  21. សាលាដំបូងខេត្តស្ទឹងត្រែង
  22. សាលាដំបូងខេត្តស្វាយរៀង

[53] មាត្រា៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

23. សាលាដំបូងខេត្តឧត្តរមានជ័យ។

## ២.១. សាលាដំបូង និងអយ្យការអមសាលាដំបូង

### ២.១.១.សាលាដំបូង

សាលាដំបូងគឺជាសាលាជម្រះក្តីជាន់ទាប ជាសាលាជម្រះក្តីថ្នាក់ទីមួយ ដែលត្រូវបានបង្កើតឱ្យមាននៅរាជធានីភ្នំពេញ និងនៅគ្រប់ខេត្តនៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែករណីខេត្តកំពត និងខេត្តកែប គឺមានសាលាជម្រះក្តីតែមួយរួមគ្នា គឺសាលាដំបូងខេត្តកំពត។ សាលាដំបូង គឺជាសាលាជម្រះក្តីទូទៅដែលមានសមត្ថកិច្ចជំនុំជម្រះទៅលើរឿងក្តីទាំងអស់ លើកលែងតែរឿងក្តីដែលស្ថិតនៅក្រោម សមត្ថកិច្ចនៃសាលាជម្រះក្តីពិសេស ឬសាលាជម្រះក្តីវិសាមញ្ញដែលបង្កើតឡើង ដោយច្បាប់ដោយឡែក ។[54]

- សមាសភាពសាលាដំបូង រួមមាន[55]៖
  - ប្រធាន
  - អនុប្រធាន
  - ចៅក្រម
  - ក្រឡាបញ្ជី
  - មន្ត្រីរដ្ឋបាល និងអាចជាមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅសាលាដំបូង ។
- សាលាដំបូងនីមួយៗបែងចែកជាតុលាការជំនាញ ដូចខាងក្រោម[56]៖
  - តុលាការរដ្ឋប្បវេណី
  - តុលាការព្រហ្មទណ្ឌ
  - តុលាការពាណិជ្ជកម្ម
  - តុលាការការងារ ។

  តុលាការជំនាញនីមួយៗរបស់សាលាដំបូង ចេញសេចក្តីសម្រេចរបស់ខ្លួនប្រកបដោយស្វ័យភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងនាមសាលាដំបូងដែលតុលាការជំនាញនោះស្ថិតនៅ ។
- សមាសភាពរបស់តុលាការជំនាញនីមួយៗ រួមមាន[57]៖
  - ប្រធានតុលាការ
  - ចៅក្រម
  - ក្រឡាបញ្ជី ។

ប្រធានតុលាការជំនាញនីមួយៗរួមទាំងចៅក្រម និងក្រឡាបញ្ជី ត្រូវចាត់តាំងដោយប្រធានតុលាការសាលាដំបូង ។ ដំណើរការរបស់តុលាការជំនាញទាំងនេះ ត្រូវកំណត់ដោយប្រធានតុលាការសាលាដំបូងដោយអនុលោមទៅតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

[54] មាត្រា១២ នៃច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ

[55] មាត្រា១៣ នៃច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ

[56] មាត្រា១៤ នៃច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ

[57] មាត្រា១៥ នៃច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ

សាលាដំបូងមានសមត្ថកិច្ចជំនុំជម្រះរឿងក្ដី ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែរឿងក្ដីទាំងឡាយដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឱ្យសាលាជម្រះក្ដីផ្សេងទៀត ។ ក្នុងករណីចាំបាច់ ដើម្បីធានាប្រយោជន៍សាធារណៈ សុវត្ថិភាព សន្តិសុខសង្គម និងដំណើរការល្អនៃយុត្តិធម៌តុលាការ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចសម្រេចផ្ទេរសមត្ថកិច្ចក្នុងការចាត់ការរឿងក្ដីពីសាលាដំបូងមួយទៅសាលាដំបូងមួយទៀតបាន ។[58]

**២.១.២. អយ្យការអមសាលាដំបូង**

សមាសភាពអយ្យការអមសាលាដំបូង រួមមាន[59]៖

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅអយ្យការអមសាលាដំបូង ។ អង្គការអយ្យការជាអង្គអវិភាគ ហើយអយ្យការមានមុខងារធ្វើបណ្ដឹងអាជ្ញា និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ព្រមទាំងអនុវត្តមុខងារផ្សេងទៀតតាមការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង គឺជាតំណាងអយ្យការអមសាលាដំបូងដែលខ្លួនបំពេញការងារ ។ ព្រះរាជអាជ្ញារង ចូលរួមអនុវត្តមុខងាររបស់អយ្យការក្រោមការដឹកនាំ និងទទួលខុសត្រូវរបស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ។

ក្នុងករណីមានធុរៈ ឬមានជំងឺ ឬអវត្តមាន ព្រះរាជអាជ្ញាត្រូវចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ ដើម្បីជំនួសបាន ។ ក្នុងករណីដែលព្រះរាជអាជ្ញាស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬក្នុងករណីតំណែងព្រះរាជអាជ្ញាស្ថិតក្នុងស្ថានភាពទំនេរ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ឱ្យធ្វើជាព្រះរាជអាជ្ញាជំនួសបាន ដើម្បីធានាដំណើរតាមរបស់អយ្យការអមសាលាដំបូង រហូតដល់មានការតែងតាំងព្រះរាជអាជ្ញាជាផ្លូវការ ។[60]

**២.២. សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍**

**២.២.១.សាលាឧទ្ធរណ៍**

សាលាឧទ្ធរណ៍គឺជាសាលាជម្រះក្ដីថ្នាក់ទីពីរ ។ សាលាឧទ្ធរណ៍រួមមានសាលាឧទ្ធរណ៍ភ្នំពេញ និងសាលាឧទ្ធរណ៍តំបន់ ។[61] កាលពីកំឡុងឆ្នាំ២០២០ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបង្កើត និងដាក់ឱ្យដំណើរការនូវសាលាឧទ្ធរណ៍តំបន់ចំនួន ៣បន្ថែមបន្ទាប់ពីសាលាឧទ្ធរណ៍ភ្នំពេញ។ ការបង្កើតសាលាឧទ្ធរណ៍តំបន់នេះគឺជាប្រវត្តិសាស្ត្រក្នុងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ហើយស្របតាមទិសដៅកម្មវិធីកំណែទម្រង់ច្បាប់ និងវិស័យ

[58] មាត្រា១៩ នៃច្បាប់ ស្ដីពីការរៀបចំអង្គការតុលាការ

[59] មាត្រា២៩ នៃច្បាប់ ស្ដីពីការរៀបចំអង្គការតុលាការ

[60] មាត្រា៣០ នៃច្បាប់ ស្ដីពីការរៀបចំអង្គការតុលាការ

[61] មាត្រា៣៥ នៃច្បាប់ ស្ដីពីការរៀបចំអង្គការតុលាការ

យុត្តិធម៌ដើម្បីបង្កិតសេវាយុត្តិធម៌ជិតប្រជាពលរដ្ឋ និងដើម្បីជួយកាត់បន្ថយការកកស្ទះសំណុំរឿងនៅសាលាឧទ្ធរណ៍ភ្នំពេញ។ សាលាឧទ្ធរណ៍ប្រចាំតំបន់ទាំង ៤ នេះ មានកាតព្វកិច្ច និងការទទួលខុសត្រូវដូចជា៖

*១. សាលាឧទ្ធរណ៍ភ្នំពេញ*[62]

សាលាឧទ្ធរណ៍ភ្នំពេញគឺមានទីតាំងនៅរាជធានីភ្នំពេញដែលទទួលដោះស្រាយលើបណ្តឹងឧទ្ធរណ៍របស់ប្រជាពលរដ្ឋសម្រាប់តែរាជធានីភ្នំពេញ និងខេត្តកណ្តាលប៉ុណ្ណោះ។ សាលាឧទ្ធរណ៍ភ្នំពេញមានលោក សេង ស៊ីវុត្ថា ជាប្រធាន និងលោក អ៊ុក សាវុធ ជាអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

*២. សាលាឧទ្ធរណ៍តំបន់បាត់ដំបង*[63]

សាលាឧទ្ធរណ៍តំបន់បាត់ដំបងមានទីតាំងនៅខេត្តបាត់ដំបង ដែលគ្របដណ្តប់ទៅលើការដោះស្រាយបណ្តឹងឧទ្ធរណ៍របស់ប្រជាពលរដ្ឋសម្រាប់នៅខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តសៀមរាប។ ប្រធានសាលាឧទ្ធរណ៍តំបន់បាត់ដំបងគឺលោក សម ប៊ុនថុន និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់បាត់ដំបងគឺលោក លោក នួន សាន។

*៣. សាលាឧទ្ធរណ៍តំបន់ព្រះសីហនុ*[64]

សាលាឧទ្ធរណ៍តំបន់ព្រះសីហនុមានទីតាំងនៅខេត្តព្រះសីហនុដែលបានគ្របដណ្តប់ទៅលើការដោះស្រាយបណ្តឹងឧទ្ធរណ៍របស់ប្រជាពលរដ្ឋសម្រាប់នៅខេត្តតាកែវ កំពង់ស្ពឺ ព្រះសីហនុ កំពត កោះកុង និងខេត្តកែប។ លោក សុខ កល្យាណ ត្រូវបានប្រកាសឱ្យកាន់តំណែងជាប្រធានសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ ខណៈលោក សរ យសថារ៉ះ ជាអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ។

*៤. សាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ*[65]

សាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ មានទីតាំងនៅខេត្តត្បូងឃ្មុំ ដែលគ្របដណ្តប់ទៅលើការដោះស្រាយបណ្តឹងឧទ្ធរណ៍របស់ប្រជាពលរដ្ឋសម្រាប់ខេត្តកំពង់ចាម កំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ព្រៃវែង ស្វាយរៀង និងខេត្តត្បូងឃ្មុំ។ សាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំមានលោក ម៉ុង មុនីចរិយា ជាប្រធាន និងលោក ហួត វុទ្ធី ជាអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ ។

### ២.២.២. មហាអយ្យការអមសាលាឧទ្ធរណ៍

- នៅអមសាលាឧទ្ធរណ៍មានមហាអយ្យការដែលមានសមាសភាពដូចខាងក្រោម៖[66]
  - អគ្គព្រះរាជអាជ្ញា

[62] ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៩/១៣០០ ស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ

[63] ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៩/១៣០២ ស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់បាត់ដំបង

[64] ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៩/១៣០៣ ស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ

[65] ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៩/១៣០១ ស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ

[66] មាត្រា៤៩ នៃច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ

- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅមហាអយ្យការអមសាលាឧទ្ធរណ៍ ។

មុខងាររបស់មហាអយ្យការអមសាលាឧទ្ធរណ៍ ត្រូវបានប្រគល់ឱ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចូលរួមអនុវត្តមុខងារនេះ ក្រោមការដឹកនាំ និងការទទួលខុសត្រូវរួម របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

ក្នុងករណីមានធុរៈ ឬមានជំងឺ ឬអវត្តមាន អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវចាត់តាំងអគ្គព្រះរាជអាជ្ញារងមួយរូប ឬបើគ្មានអគ្គព្រះរាជអាជ្ញារងទេ អាចចាត់តាំងព្រះរាជអាជ្ញាណាម្នាក់ជំនួសខ្លួនបាន ។

ក្នុងករណីដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារ បាន ឬក្នុងករណីតំណែងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ស្ថិតក្នុងស្ថានភាពទំនេររដ្ឋមន្ត្រីក្រសួង យុត្តិធម៌ត្រូវចាត់តាំងអគ្គព្រះរាជអាជ្ញារងណាម្នាក់ ឱ្យធ្វើជាអគ្គព្រះរាជអាជ្ញាស្ដីទីជំនួសបាន ដើម្បីធានាដំណើរការរបស់មហាអយ្យការអមសាលាឧទ្ធរណ៍ រហូតដល់មានការតែងតាំងអគ្គព្រះរាជអាជ្ញាជាផ្លូវការ ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានអំណាចគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជ អាជ្ញាអមសាលាឧទ្ធរណ៍ ។[67]

## ២.៣. តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល

### ២.៣.១. តុលាការកំពូល

តុលាការកំពូលមានតែមួយគត់ ដែលមានទីតាំងនៅរាជធានីភ្នំពេញ។

- សមាសភាពតុលាការកំពូលរួមមាន៖[68]
  - ប្រធាន
  - អនុប្រធាន
  - ចៅក្រម
  - ក្រឡាបញ្ជី
  - មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅតុលាការកំពូល ។
- តុលាការកំពូលមានសភាជំនាញ ដូចខាងក្រោម៖[69]
  - សភាព្រហ្មទណ្ឌ
  - សភារដ្ឋប្បវេណី
  - សភាពាណិជ្ជកម្ម
  - សភាការងារ ។

[67] មាត្រា៥០ នៃច្បាប់ ស្ដីពីការរៀបចំអង្គការតុលាការ
[68] មាត្រា៥៦ នៃច្បាប់ ស្ដីពីការរៀបចំអង្គការតុលាការ
[69] មាត្រា៥៧ នៃច្បាប់ ស្ដីពីការរៀបចំអង្គការតុលាការ

- សមាសភាពរបស់សភានីមួយៗរួមមាន៖[70]
  - ប្រធានសភា
  - ចៅក្រម និង
  - ក្រឡាបញ្ជី ។

  ប្រធានសភានីមួយៗត្រូវបានចាត់តាំងដោយប្រធានតុលាការកំពូល ។ ចំនួនចៅក្រម ក្រឡាបញ្ជី និងដំណើរការរបស់សភាទាំងនេះ ត្រូវកំណត់ដោយប្រធានតុលាការកំពូល ។
- ប្រធានតុលាការកំពូលត្រូវចេញដីកាសម្រេចដើម្បី៖ [71]
  - ចាត់តាំងអនុប្រធានតុលាការកំពូលណាម្នាក់ ឱ្យចាត់ចែងការងារជំនួសខ្លួនបានក្នុងករណី ចាំបាច់
  - ចាត់តាំងអនុប្រធានតុលាការកំពូល ឱ្យទទួលបន្ទុកធ្វើជាប្រធានសភានីមួយៗ ទៅតាមជំនាញ និងបទពិសោធន៍ការងារ ។ ក្នុងករណីខ្វះអនុប្រធាន ប្រធានតុលាការកំពូលអាចចាត់តាំងចៅក្រមណាម្នាក់ឱ្យធ្វើជាប្រធានសភាបាន ។

### ២.៣.២. មហាអយ្យការអមតុលាការកំពូល

- មហាអយ្យការអមតុលាការកំពូលមានសមាសភាពដូចខាងក្រោម៖
  - អគ្គព្រះរាជអាជ្ញា
  - អគ្គព្រះរាជអាជ្ញារង
  - ព្រះរាជអាជ្ញា
  - ក្រឡាបញ្ជី និង
  - មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅមហា អយ្យការអមតុលាការកំពូល ។

មុខងាររបស់មហាអយ្យការអមតុលាការកំពូល ត្រូវបានប្រគល់ឱ្យអគ្គព្រះរាជអាជ្ញាអមតុលាការ កំពូល ។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ចូលរួមអនុវត្តមុខងារនេះ ក្រោមការ ដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។ ក្នុងករណីមានធុរៈ ឬមានជំងឺ ឬអវត្តមាន អគ្គព្រះរាជអាជ្ញាអមតុលាការ ត្រូវចាត់តាំង អគ្គព្រះរាជអាជ្ញារងមួយរូប ឬបើគ្មានអគ្គព្រះរាជអាជ្ញារងទេ អាចចាត់តាំងព្រះរាជអាជ្ញាណាម្នាក់ដើម្បី ជំនួសខ្លួនបាន ។ ក្នុងករណីដែលអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារ បាន ឬក្នុងករណីតំណែងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលស្ថិតក្នុងស្ថានភាពទំនេររដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់តាំងអគ្គព្រះរាជអាជ្ញារងណាម្នាក់ ឱ្យធ្វើជាអគ្គព្រះរាជអាជ្ញាស្ដីទីជំនួសបាន ដើម្បីធានាដំណើរការរបស់មហាអយ្យការអមតុលាការកំពូល រហូតដល់មានការតែងតាំងអគ្គព្រះរាជអាជ្ញាជាផ្លូវការ ។[72]

---

[70] មាត្រា៥៨ នៃច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ

[71] មាត្រា៦០ នៃច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ

[72] មាត្រា៦៩ នៃច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ

# ជំពូកទី ៣

# តួនាទីរបស់ចៅក្រមស៊ើបសួរនៅកម្ពុជាបច្ចុប្បន្ន

# ជំពូកទី ៣

# តួនាទីរបស់ចៅក្រមស៊ើបសួរនៅកម្ពុជាបច្ចុប្បន្ន

ចៅក្រមស៊ើបសួរមានតួនាទីយ៉ាងសំខាន់ក្នុងការស្វែងរកភស្តុតាងទាំងដោះបន្ទុក និងដាក់បន្ទុកជូនគូភាគីក្នុងរឿងក្តី និយាយជារួម គឺចៅក្រមរូបនេះធ្វើការជួយ ក៏ដូចជាស្វែងរកការពិតជូនគូរភាគីដោយអនុលោមតាមច្បាប់។[73] ចៅក្រមស៊ើបសួរមានតួនាទីស្រាវជ្រាវសំណុំរឿង ដែលបានប្តឹងមកខ្លួនតាមរយៈព្រះរាជអាជ្ញាដោយដីកា បញ្ជូនរឿងឱ្យស៊ើបសួរ ពោលគឺ វាជាដំណាក់កាលទី៣ នៃដំណើរការនីតិវិធីក្នុងរឿងព្រហ្មទណ្ឌ ដែលយើងសុទ្ធតែដឹងថា ដំណើរនៅក្នុងនីតិវិធីព្រហ្មទណ្ឌបានបែងចែកជា ៤ដំណាក់កាលគឺ[74]៖

- ដំណាក់កាលទី១ គឺដំណាក់កាលនគរបាលយុត្តិធម៌ ក្រោមការទទួលខុសត្រូវនឹងគ្រប់គ្រងរបស់ព្រះរាជអាជ្ញា។
- ដំណាក់កាលទី២ គឺដំណាក់កាលនៃការចោទប្រកាន់ (ដំណាក់កាលព្រះរាជអាជ្ញា)។
- ដំណាក់កាលទី៣ គឺដំណាក់កាលនៃការស៊ើបសួរ (ដំណាក់កាលចៅក្រមស៊ើបសួរ។
- ដំណាក់កាលទី៤ គឺដំណាក់កាលជំនុំជម្រះ។

ដំណាក់កាលនៃចៅក្រមស៊ើបសួរនេះគឺកកើតឡើងមកបាន លុះត្រាមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ពីសំណាក់ព្រះរាជអាជ្ញា ពោលគឺជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញាបានបែងចែកជា៣ គឺ[75]
៖

- ការបើកការស៊ើបសួរ (ឆ្លងកាត់ដំណាក់កាលចៅក្រមស៊ើបសួរ)
- ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ (មិនឆ្លងកាត់ដំណាក់កាលចៅក្រមស៊ើបសួរ)
- តាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម (មិនឆ្លងកាត់ដំណាក់កាលចៅក្រមស៊ើបសួរ)

ជាទូទៅការស៊ើបសួរត្រូវតែ ធ្វើជាដាច់ខាតនៅពេលមាន បទឧក្រិដ្ឋបានកើតឡើង[76]។ ចំណែកឯក្នុងបទ មជ្ឈិមវិញ ការស៊ើបសួរអាចធ្វើក៏បាន មិនធ្វើក៏បាន នេះគឺវាស្ថិតទៅលើជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ថាតើគាត់ជ្រើសរើសក្នុងការចោទប្រកាន់មួយណា។ ចំពោះយុត្តាធិការស៊ើបសួរ គឺជាដំណាក់កាលមួយនៃវិធានការស្រាវជ្រាវរបស់ចៅក្រមដែលមានតួនាទីក្នុងការ ស្វែងរកនូវភស្តុតាងដាក់បន្ទុក និងដោះបន្ទុក ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់អំណាច និងសិទ្ធិឱ្យទៅ ចៅក្រមស៊ើបសួរនូវអំណាចជាច្រើន ហើយការ

[73] មាត្រា១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[74] គន្ថីទី២,៣,៤,៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[75] មាត្រា៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[76] មាត្រា១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ស៊ើបសួរនេះផងដែរ ចៅក្រមស៊ើបសួរត្រូវមានក្រឡាបញ្ជីម្នាក់អមជានិច្ច។ ប៉ុន្តែ ក្នុងករណីណាក៏ដោយ ក្រឡាបញ្ជីមិនអាចបំពេញកិច្ចដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរបានទេ[77]។

## ផ្នែកទី១៖ ការស៊ើបសួរ

បើយោងទៅតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាយើង នៅក្នុងដំណាក់កាលស៊ើបសួរ ចៅក្រមស៊ើបសួរធ្វើការស៊ើបសួរទៅតាមគោលការណ៍ដែលបានកំណត់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ព្រមទាំងមានតួនាទីជាបន្តបន្ទាប់ទៀតត្រូវបំពេញ ដែលកិច្ចទាំងនោះមានដូចជាការ ឆែកឆេរ ចាប់យកវត្ថុតាង និង ការធ្វើកោសលវិច័យ។ល។ ដែលជាកិច្ចរបស់ចៅក្រមស៊ើបសួរ ត្រូវបំពេញនា ដំណាក់កាលនៃការស៊ើបសួរ។

### ១.១.ការសម្ងាត់នៃការស៊ើបសួរ

ការស៊ើបសួរត្រូវតែជាការសម្ងាត់[78]។ បុគ្គលទាំងឡាយដែលចូលរួមក្នុងការស៊ើបសួរ ជាពិសេស ចៅក្រម មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ច[79] ត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ។ ផ្ទុយមកវិញ ការបំពានលើការសម្ងាត់នៃការស៊ើបសួរ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

ប៉ុន្តែ ការគោរពផ្លូវការសម្ងាត់វិជ្ជាជីវៈ មិនអាចជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនឡើយ។ ម្យ៉ាងទៀតព្រះរាជអាជ្ញាអាចធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ កាលណាខ្លួនយល់ឃើញ ថា ព័ត៌មានដែលផ្សព្វផ្សាយពីរឿងណាមួយនោះ ជាព័ត៌មានមិនពិត ។

### ១.២. សមត្ថកិច្ចដែនដី

នៅតាមបណ្តារាជធានី-ខេត្ត សុទ្ធតែមានសាលាដំបូងរៀងៗខ្លួន ដោយសាលាដំបូងនីមួយៗ ទទួលភារកិច្ចក្នុងការដោះស្រាយនូវសំណុំរឿង ក៏ដូចជាបទល្មើសព្រហ្មទណ្ឌនានាដែលកើតមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ចៅក្រមដែលបំពេញការងារនៅតាមបណ្តាសាលាដំបូងរាជធានី-ខេត្ត ក៏ត្រូវបានកំណត់នូវដែនសមត្ថកិច្ចរបស់ខ្លួនផងដែរ។ សមត្ថកិច្ចដែនដី របស់ចៅក្រមរួមមាន[80]៖

- ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស
- ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស ។

[77] មាត្រា១២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[78] មាត្រា ១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[79] មាត្រា ៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[80] មាត្រា ១២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ក្នុងករណីដែលមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូបទៅសាលាដំបូងខុសៗគ្នា ហើយទទួលបណ្តឹងទាំងអស់គ្នា អំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នា ទំនាស់នេះត្រូវបញ្ជូនទៅប្រធាន សភាស៊ើបសួរដើម្បីសម្រេច អំពីសមត្ថកិច្ចដែនដី។ វិវាទសមត្ថកិច្ចដែនដី រវាងសភាស៊ើបសួរច្រើនត្រូវសម្រេចដោយប្រធានតុលាការកំពូល ។ ចំពោះការសម្រេចរបស់តុលាការកំពូលទាក់ទងទៅនឹងវិវាទនេះ ជាការបិទផ្លូវតវ៉ា ។

### ១.៣. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញា

នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ដែលចេញឱ្យចៅក្រមស៊ើបសួរ ដើម្បីបើកការស៊ើបសួរនោះ គឺអាចបើកប្រឆាំង និងបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលបង្ហាញ ប្រាប់ឈ្មោះ នៅក្នុងដីកា ប្រសិនបើកំណត់អត្តសញ្ញាណជននោះបាន ប្រឆាំងនឹងអញ្ញាតជន ប្រសិនបើមិនស្គាល់អត្តសញ្ញាណ[81]។ ម្យ៉ាងវិញទៀត ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយដោយគ្មានវត្តមានដីកាបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាបានឡើយ ពោលគឺបើមិនមានដីកានេះទេគឺចៅក្រមស៊ើបសួរមិនមានសិទ្ធបើកការស៊ើបសួរដោយឯកឯងបានឡើយ ។[82]

ក្នុងករណីមួយទៀត កាលណាបើចៅក្រមស៊ើបសួរ ទទួលពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណីនោះ ចៅក្រមស៊ើបសួររូបនោះ ត្រូវតម្រូវឱ្យដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់ ប្រាក់តម្កល់ទុកជាមុនសិន[83]។ ក្រោយពីបានទទួលពាក្យបណ្តឹងសាមញ្ញនេះរួចចៅក្រមស៊ើបសួរក៏ពុំអាចទាន់បើក ការស៊ើបសួរបានដែរ គឺចៅក្រមស៊ើបសួររូបនោះត្រូវបញ្ជូនពាក្យបណ្តឹងសាមញ្ញនោះ ឱ្យទៅព្រះរាជអាជ្ញាដើម្បីសុំឱ្យព្រះរាជអាជ្ញារូបនោះចេញដីកាបញ្ជូនរឿងឱ្យស៊ើបសួរដើម្បីបើកការស៊ើបសួរបានផងដែរ។

## ផ្នែកទី២៖ វិធានការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

វិធានការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ ត្រូវបានបែងចែកជាពីរ គឺអំណាចស្រាវជ្រាវ ដែលនិយាយពីការស្រាវជ្រាវផ្ទាល់របស់ចៅក្រមស៊ើបសួរ និងអំណាចផ្ទេរ ដែលនិយាយពីការផ្ទេរអំណាចស្រាវជ្រាវទៅឱ្យអ្នកជំនាញ ឬចាត់ឱ្យស៊ើបសួរជំនួស។

### ២.១. អំណាចស្រាវជ្រាវ

អំណាចស្រាវជ្រាវ គឺជាអំណាចមួយដែលចៅក្រមស៊ើបសួរធ្វើការស៊ើបសួរដោយមានវត្តមានផ្ទាល់ ក្នុងនោះរួមមាន ការសួរចម្លើយទាំងជនត្រូវចោទ ការស្តាប់ចម្លើយជនរងគ្រោះនិងសាក្សី ព្រមទាំងមានការធ្វើកោសល្យវិច័យ ការឆែកឆេរនិងការចាប់យកវត្ថុតាង រួមទាំងការស្តាប់ទូរស័ព្ទថែមទៀតផងដែរ។

[81] មាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[82] មាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[83] មាត្រា ១៣៩, ១៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ២.១.១. ការសួរចម្លើយជនត្រូវចោទ

ជាធម្មតាជនត្រូវចោទគឺត្រូវបានសួរចម្លើយដោយចៅក្រមស៊ើបសួរនាដំណាក់កាលស៊ើបសួរ និងទទួលយកចម្លើយនោះមកធ្វើជាកម្មវត្ថុនៃការថ្លឹងថ្លែងកិច្ចប្រតិបត្តិការណ៍នៃការស៊ើបសួរក្នុងការភស្តុតាងដាក់បន្ទុក និងដោះបន្ទុកជូនភាគីក្តីទាំងសងខាង។ ក្នុងករណីចាំបាច់ចៅក្រមស៊ើបសួរអាចស្វែងរកអ្នកបកប្រែ[84]។ ម៉្យាងវិញទៀតកាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរ ត្រូវកោះហៅមេធាវីនោះយ៉ាងតិចបំផុត ៥ថ្ងៃមុនការសួរចម្លើយ។ ហេតុផលនៃការទុករយៈពេលនេះ ក្នុងគោលបំណងចង់ទុកថេរវេលានេះជូនដល់មេធាវីក្នុងការពិនិត្យមើលសំណុំរឿងឱ្យបានគ្រប់ជ្រុងជ្រោយ មុននឹងចៅក្រមស៊ើបសួរសួរចម្លើយកូនក្តីរបស់ខ្លួន។ មួយវិញទៀត ជនត្រូវចោទអាចត្រូវសួរចម្លើយបានតែនៅតែចំពោះមុខមេធាវីរបស់ខ្លួនតែប៉ុណ្ណោះ។ ប៉ុន្តែ ក្នុងករណីបើមេធាវីដែលគេបានកោះហៅយ៉ាងត្រឹមត្រូវហើយ មិនបានចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរ អាចសួរសំណួរជនត្រូវចោទដោយគ្មានវត្តមានរបស់មេធាវីនោះបាន។

ចំពោះករណីពិសេសណាមួយ ចៅក្រមស៊ើបសួរ អាចសួរសំណួរជនត្រូវចោទ ដោយមិនចាំបាច់កោះហៅមេធាវីក៏បាន ដែរប្រសិនបើជនត្រូវចោទបានបោះបង់សិទ្ធិយ៉ាងជាក់លាក់នូវវត្តមានរបស់មេធាវីខ្លួន។ ផ្ទុយមកវិញក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចធ្វើការសួរចម្លើយជនត្រូវចោទដោយមិនមានវត្តមានរបស់មេធាវីក៏បានដែរ ដែលភាពបន្ទាន់នេះត្រូវតែបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្តាលមកពីការភ័យ ខ្លាចបាត់បង់តម្រុយនៃភ័ស្តុតាង។[85]

លើសពីនេះទៅទៀត មេធាវីរបស់ជនត្រូវចោទដែលកំពុងជាប់ឃុំ អាចប្រាស្រ័យទាក់ទងដោយសេរីជាមួយកូនក្តីរបស់ខ្លួនបានគ្រប់ពេល មិនថានៅក្រៅ ឬក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួនក្តី ដែលការសន្ទនានេះមិនអាចត្រូវគេស្តាប់ ឬថតបានឡើយ គឺមេធាវីមិនអាចឱ្យលិខិតថតចម្លងនៃសំណុំរឿងដល់កូនក្តីរបស់ខ្លួនបានឡើយ[86]។

### ២.១.២. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី

ដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីក្នុងរឿងព្រហ្មទណ្ឌដូចជាជនត្រូវចោទដែរ ហើយគាត់ក៏មានសិទ្ធិក្នុងការរកមេធាវីដើម្បីជួយការពារក្តីឱ្យខ្លួនបានដូចជាជនត្រូវចោទដែរ។ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិពិសេសមួយត្រង់ថានៅក្នុងដំណាក់កាលនៃការស៊ើបសួរចៅក្រមស៊ើបសួរមានសិទ្ធិត្រឹមតែស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ[87]គឺខុសពីជនត្រូវចោទដែលចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទបាន។ ចំពោះសាក្សីវិញ គឺជាបុគ្គលដែលនៅក្រៅអង្គហេតុនិងអាចផ្តល់ព័ត៌មានដែលមានប្រយោជន៍ ដើម្បីបង្ហាញការពិតទៅ

[84] មាត្រា ១៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[85] មាត្រា ១៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[86] មាត្រា ១៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[87] មាត្រា ១៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ចៅក្រមស៊ើបសួរ មួយវិញទៀតនៅក្នុងដំណាក់កាលនៃការស៊ើបសួរ ចៅក្រមស៊ើបសួរ អាចកោះហៅជនទាំងឡាយដែលបានដឹងអំពីអង្គហេតុដែលបានកើតឡើង ក្នុងឋានៈជាសាក្សីដើម្បីធ្វើការស្តាប់ចម្លើយ ដូចដែលធ្វើចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែរ[88]។

### ២.១.៣. កោសលវិច័យ

នៅក្នុងករណីដែលមានបញ្ហាបច្ចេកទេសចោទឡើងចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យធ្វើកោសលវិច័យ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានដោយឯកឯង ឬ តាមពាក្យសុំរបស់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី[89] ហើយកាលណាចៅក្រមស៊ើបសួរបដិសេធមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យទេ ត្រូវមានសំអាងហេតុ។ តាមការស្នើសុំនេះផងដែរចៅក្រមស៊ើបសួរ និងចេញដីកាសម្រេច ក្នុងរយៈពេល ៥ ថ្ងៃ ប្រសិនបើពាក្យសុំនោះធ្វើដោយព្រះរាជអាជ្ញា និងក្នុងរយៈពេល ១ ខែ ប្រសិនបើពាក្យសុំនោះធ្វើដោយជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ដែលដីកាសម្រេចនេះត្រូវជូនដំណឹងឱ្យដល់អ្នកប្តឹងសុំជាបន្ទាន់។ ចំពោះអ្នកជំនាញត្រូវបានចាត់តាំងដោយចៅក្រមស៊ើបសួរដែលអាចមាន ១ រូប ឬ ច្រើនរូប ស្ថិតនៅក្រោមការត្រួតពិនិត្យដោយចៅក្រមស៊ើបសួរនិងអ្នកជំនាញត្រូវធ្វើរបាយការណ៍អំពីការធ្វើកោសលវិច័យជូនចៅក្រមស៊ើបសួរ។ សម្រាប់សោហ៊ុយដែលបានចំណាយចំពោះការធ្វើកោសលវិច័យនោះគឺក្រមនីតិវិធីព្រហ្មទណ្ឌបានធ្វើការបែងចែកចំពោះការចំណាយលើកោសលវិច័យដូចជា បើកោសលវិច័យកើតចេញពីការសុំរបស់ជនត្រូវចោទ ដើម បណ្តឹងរដ្ឋប្បវេណី ជាសោហ៊ុយរបស់អ្នកស្នើសុំ។ ប្រសិនកោសលវិច័យកើតចេញពីចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា នគរបាលយុត្តិធម៌ ជាសោហ៊ុយរបស់រដ្ឋ[90]។

### ២.១.៤. ការឆែកឆេរ និងការចាប់យកវត្ថុតាង

ផ្ទុយពីគំនិតដែលទទួលបានជារួម ការស៊ើបសួរមិនអនុញ្ញាតឱ្យធ្វើការឆែកឆេរគ្រប់កន្លែងដោយពុំមានលក្ខខណ្ឌដូចក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្តែងនោះទេ។ ក្នុងក្របខ័ណ្ឌនៃការស៊ើបសួរនេះ ការឆែកឆេរត្រូវ គោរពតាមម៉ោង ដែលមិនអាចចាប់ផ្តើមឆែកឆេរមុនម៉ោង ៦ ព្រឹក និងក្រោយម៉ោង ១៨ ល្ងាចបានទេ[91] លើកលែងតែ ក្នុងករណីឆែកឆេរកន្លែងបើកឱ្យសាធារណជនដូចជាកន្លែងលក់ និង ប្រើប្រាស់គ្រឿងញៀន។ ដូចគ្នានេះដែរ ការឆែកឆេរ ការិយាល័យមេធាវីត្រូវធ្វើឡើងដោយមានវត្តមានប្រធានគណៈមេធាវី ឬប្រតិភូរបស់គាត់។ ចំពោះអ្នកកាន់កាប់កន្លែងត្រូវមានវត្តមាន ប្រសិនបើគ្មានអ្នកកាន់កាប់ទេ ត្រូវមានសាក្សីពីរនាក់ដែលបានចាត់តាំងដោយចៅក្រមស៊ើបសួរដែលសាក្សីនោះមិនអាចជាអាវុធហត្ថ ឬ នគរបាល។ ចំណែកចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុ ដែលត្រូវមានចុះហត្ថលេខាអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែងសាក្សីនីមួយៗ និងជាយថាហេតុ អត្តសញ្ញាណរបស់ប្រធានគណៈមេធាវី ឬប្រតិភូរបស់គាត់ ព្រមទាំងត្រូវមានចុះហត្ថលេខាដោយ

[88] មាត្រា ១៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[89] មាត្រា ១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[90] មាត្រា ១៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[91] មាត្រា ១៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី។ ម៉្យាងវិញទៀត ការចាប់យកវត្ថុតាងច្បាប់អនុញ្ញាតឱ្យចៅក្រមស៊ើបសួរចាប់វត្ថុតាងនិងបិទស្លាកបោះត្រាលើវត្ថុតាង[92] ហើយក្រោយពីបានបង្ហាញវត្ថុដែលចាប់ដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីទាំងពីរនាក់រួចមក ចៅក្រមស៊ើបសួរធ្វើកំណត់ហេតុស្ដីពីការចាប់ ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់យក កំណត់ហេតុស្ដីការចាប់នេះត្រូវមានការចុះហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីរួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬ សាក្សីពីរនាក់ ព្រមទាំងត្រូវមានចុះនិទ្ទេសអំពីអត្តសញ្ញាណនៃអ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ។

### ២.១.៥. ការស្ដាប់ទូរស័ព្ទ

ចំពោះការស្ដាប់ទូរស័ព្ទ ក៏ជាកិច្ចមួយយ៉ាងពិសេសសំរាប់ចៅក្រមស៊ើបសួរអនុវត្តកិច្ចនេះដើម្បី ស្វែងរកការពិតដោយអនុលោមតាមច្បាប់។ ពីព្រោះសព្វថ្ងៃនេះបច្ចេកវិទ្យា កាន់តែទំនើបដូច្នោះការទាក់ទងគ្នា ក៏មានការឆាប់ រហ័សយ៉ាងគួរឱ្យកក់សម្គាល់ តួយ៉ាងដូចជាការទាក់ទងគ្នាតាមទូរស័ព្ទ ឬតាមបណ្ដាញសង្គម នានាជាដើមអញ្ចឹង ហើយទើបក្រមនីតិវិធីព្រហ្មទណ្ឌរបស់យើងបានដាក់បញ្ចូលការស្ដាប់ទូរស័ព្ទ[93] របស់ភាគីក្នុងរឿងដោយចៅក្រមស៊ើបសួរ និងដើម្បីធានាក្នុងការស្វែងរកឱ្យឃើញការពិតក្នុងការរកយុត្តិធម៌ជូនដល់បុគ្គលដែលស្លូតត្រង់។

### ២.២. អំណាចផ្ទេរ

ក្រៅពីអំណាចស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរក្នុងការអនុវត្តដោយផ្ទាល់ ចៅក្រមស៊ើបសួរនៅមានជម្រើសក្នុងផ្ទេរអំណាចស៊ើបសួរ ដោយការចាត់តាំងអ្នកជំនាញឱ្យស៊ើបសួរជំនួសខ្លួនបាន តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស[94] ដែលចៅក្រមស៊ើបសួរអាចប្រគល់សិទ្ធិឱ្យចៅក្រមនៃតុលាការរបស់ខ្លួន ឬតុលាការផ្សេងទៀត ឬមន្ត្រីនគរបាលយុត្តិធម៌ ឬដល់អង្គភាពនគរបាលយុត្តិធម៌ ដើម្បីបំពេញកិច្ចស៊ើបសួរ។ ប៉ុន្តែតាមដីកាដែលចៅក្រមស៊ើបសួរ ត្រូវកំណត់ថិរវេលា[95] ដែលត្រូវអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ព្រមទាំងត្រូវមានកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង មិនតែប៉ុណ្ណោះ ចៅក្រមស៊ើបសួរអាចដកហូតដីកាចាត់ឱ្យស៊ើបសួរជំនួសបានគ្រប់ពេលវេលា។ កាលណាដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវ បានចេញឱ្យដល់ចៅក្រមណាម្នាក់ ចៅក្រមរូបនោះប្រើប្រាស់ អំណាចទាំងអស់របស់ចៅក្រមស៊ើបសួរ ពោលគឺ ចៅក្រមដែលទទួលដីកាចាត់ឱ្យស៊ើបសួរជំនួសប្រើប្រាស់សិទ្ធិ ដូចចៅក្រមដើមចេញដីកាឱ្យដែរ។ លើកលែងតែការចាត់ឱ្យស៊ើបសួរជំនួស បានចេញឱ្យទៅមន្ត្រីនគរបាលយុត្តិធម៌ ពោលគឺគេបានកម្រិតសិទ្ធិខ្លះ និងព្រំដែនចំពោះគាត់មិនដូចចៅក្រមឱ្យទៅចៅក្រមឡើយ។ ចំពោះអំណាចដែលអាចផ្ទេរបានគឺ៖

[92] មាត្រា ១៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[93] មាត្រា ១៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[94] មាត្រា ១៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[95] មាត្រា ១៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

-ការស្តាប់ចម្លើយសាក្សី បើក្នុងពេលស្តាប់ចម្លើយ បានលេចចេញនូវតម្រុយនៃពិរុទ្ធភាពប្រឆាំងនឹងសាក្សី នោះការស្តាប់ចម្លើយត្រូវបញ្ចប់ ដើម្បីឱ្យមន្ត្រីនគរបាលយុត្តិធម៌ផ្តល់ដំណឹងភ្លាមទៅចៅក្រមស៊ើបសួរ។

-ការឆែកឆេរ និងការចាប់យកវត្ថុ ដោយគោរពលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១៥៩ និង មាត្រា ១៦០ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ

-ការឃាត់ខ្លួន អំណាចត្រួតពិនិត្យដែលធ្វើដោយព្រះរាជអាជ្ញាក្នុងក្របខណ្ឌនៃការស៊ើបអង្កេតតាមផ្លូវតុលាការត្រូវធ្វើដោយចៅក្រមស៊ើបសួរនៅពេលឃាត់ខ្លួនក្នុងក្របខណ្ឌនៃការចាត់ឱ្យស៊ើបសួរជំនួស។

-ការស្តាប់ និងការថតការសន្ទនាតាមទូរស័ព្ទ និងការចាត់ការឆ្លងឆ្លើយតាមមធ្យោបាយទូរគមនាគមន៍[96] ។

ជាការពិតណាស់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីអំពីគ្រប់កិច្ចដែលបំពេញដោយអនុវត្តតាម ដីកាចាត់ឱ្យស៊ើបសួរជំនួស ដែលត្រូវប្រគល់ឱ្យចៅក្រមស៊ើបសួរ ដើម្បីបញ្ចូលក្នុងសំណុំរឿងនៅពេលដែលកិច្ចត្រូវ បានបំពេញចប់។

## ផ្នែកទី៣៖ វិធានការនិរន្តរាយ

### ៣.១. ដីកា

ចៅក្រមស៊ើបសួរ មានអំណាចនៅក្នុងការចេញដីកាចំពោះបុគ្គលណាដែលរឹងទទឹងក្នុងការចូលរួមអនុវត្តនីតិវិធី ដែលនៅក្នុងនោះមានដូចជា សាក្សី ជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាព គឺចៅក្រមស៊ើបសួរអាចធ្វើការចាប់បង្ខំឱ្យជនទាំងឡាយនោះចូលខ្លួនដោយប្រើប្រាស់កម្លាំងសាធារណៈ ចំពោះដីកាដែលចៅក្រមស៊ើបសួរអាចចេញបានមានដូចជា ៖

#### ៣.១.១. ដីកាបង្គាប់ឱ្យចូលខ្លួន

ដីកាបង្គាប់ឱ្យចូលខ្លួន គឺជាការបញ្ជាដល់បុគ្គលណាម្នាក់ឱ្យចូលទៅបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ គឺបានន័យថា កោះហៅទៅលើបុគ្គលទាំងឡាយដែលមានតម្រុយពិរុទ្ធភាពនិងមានការពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានកើតឡើង ដីកានេះអាចចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាពប៉ុណ្ណោះ[97] ។ តាមរយៈដីកានេះសាមីខ្លួនបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរដោយសេរី ពោលគឺបានន័យថា ការបង្ហាញខ្លួនតាមរយៈដីកានេះ ពុំមានតម្លៃបង្ខំដោយកងកម្លាំងសាធារណៈនោះទេ។ បន្ថែមពីនេះទៅទៀត ដីកានេះ គឺជាការបញ្ជាឱ្យសាមីខ្លួនចូលបង្ហាញខ្លួនតាមផ្លូវធម្មតា ដែលជាទូទៅដីកានេះត្រូវបានប្រើប្រាស់នៅពេល ដែលសាមីខ្លួននោះមិនបានរត់គេចខ្លួន ហើយពុំឆ្លើយតបទៅនឹងការកោះហៅតាមផ្លូវរដ្ឋបាល ។

---

[96] មាត្រា ១៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[97] មាត្រា ១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ៣.១.២. ដីកាបង្គាប់ឱ្យនាំខ្លួន

ដីកាបង្គាប់ឱ្យនាំខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឱ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ[98] ។ ដីកាបង្គាប់ឱ្យនាំខ្លួនអាចចេញទៅបានតែលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពីពិរុទ្ធភាពតែប៉ុណ្ណោះ ។ ចំពោះការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួននេះដែរ ត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ដែលមានកាតព្វកិច្ចនាំខ្លួនបុគ្គលដែលពាក់ព័ន្ធទៅចំពោះមុខចៅក្រមស៊ើបសួរ ក្រោយពេលចាប់ខ្លួនបាន ។ ប៉ុន្តែក្នុងករណី ដែលចៅក្រមមិនអាចសួរចម្លើយជននោះភ្លាមៗ ឬដោយមូលហេតុនៃកាលៈទេសៈ បុគ្គលដែលពាក់ព័ន្ធមិនអាចអាចត្រូវនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរបានភ្លាមៗទេ ដីកានេះអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌នាំខ្លួនបុគ្គលដែលពាក់ព័ន្ធទៅរក្សាទុកនៅអង្គភាពក្នុងមណ្ឌលឃុំខ្លួន ឬពន្ធនាគារបានដែលមានថិរវេលាមិនអាចលើសពី១ថ្ងៃបានឡើយ ពោលគឺត្រូវតែនាំខ្លួនបុគ្គលដែលពាក់ព័ន្ធនេះទៅចំពោះមុខចៅក្រមស៊ើបសួរ ឬអ្នកជំនួស យ៉ាងយូរបំផុតនៅថ្ងៃបន្ទាប់[99] ។ ផ្ទុយពីនេះ ប្រសិនបើការបង្ហាញខ្លួនមិនបានប្រព្រឹត្តិទៅនៅថ្ងៃបន្ទាប់ទេ បុគ្គលដែលពាក់ព័ន្ធត្រូវបានដោះលែងឱ្យមានសេរីភាពវិញ ប្រការមួយទៀតដែលត្រូវជៀសវាងដាច់ខាត ដើម្បីកុំឱ្យមានការរំលោភលើសិទ្ធិបុគ្គល មន្ត្រីនគរបាលយុត្តិធម៌ ដែលអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន មិនអាចចូលទៅក្នុងលំនៅដ្ឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ព្រឹក និងក្រោយម៉ោង ១៨ បានទេ[100] ។ ក្នុងករណីមួយទៀត ប្រសិនបើបុគ្គលត្រូវនាំមកបង្ហាញខ្លួនចំពោះចៅក្រមស៊ើបសួរត្រូវបានឃុំខ្លួន នោះថិរវេលានៃការឃុំខ្លួននេះ ត្រូវរាប់បញ្ចូលទៅក្នុងថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ននោះដែរ[101] ។

### ៣.១.៣. ដីកាបង្គាប់ឱ្យចាប់ខ្លួន

បើនិយាយដល់ពាក្យចាប់ខ្លួន គឺបានន័យថាមានជនណាម្នាក់បានប្រព្រឹត្តិអំពើមួយដែលខុសឆ្គងយ៉ាងធ្ងន់ធ្ងរដែលពាក់ព័ន្ធ ទៅនឹងនីតិវិធីមានន័យថាជននោះពិតជាមានតម្រុយនៃពិរុទ្ធភាព[102]ពិតមែន ដែលទាក់ទងទៅនឹងបទល្មើសដែលបានប្រព្រឹត្តិទៅលើជនរងគ្រោះ ។ ដីកានេះ គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឱ្យស្រាវជ្រាវរកចាប់ និងឱ្យនាំខ្លួនបុគ្គលណាម្នាក់ទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន និងជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឃុំខ្លួនបុគ្គលនោះ ។ ចំពោះ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ត្រូវគោរពលក្ខខ័ណ្ឌមួយចំនួនដូចតទៅ៖

- ចេញបានទៅលើជនត្រូវចោទ និងបុគ្គលដែលមានតម្រុយពីពិរុទ្ធភាព
- បទល្មើសដែលត្រូវចោទប្រកាន់ជាបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ (ត្រង់ចំណុចនេះ ក្រមនីតិវិធីព្រហ្មទណ្ឌ ពុំបានកំណត់អំពើកម្រិតទោសដាក់ពន្ធនាគារនោះទេ ពោលគឺទោសដាក់ពន្ធនារគារជាទូទៅ) ។ ប៉ុន្តែ ចៅក្រមស៊ើបសួរពុំមានសិទ្ធិអំណាចចេញដីកាបង្គាប់ឱ្យចាប់

[98] មាត្រា ១៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[99] មាត្រា ១៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[100] មាត្រា ១៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[101] មាត្រា ១៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[102] មាត្រា ១៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ខ្លួនបុគ្គល ដែលទទួលរងការចោទប្រកាន់ពីបទល្មើសមជ្ឈិមដែលមានទោសពិន័យជាប្រាក់នោះឡើយ ។

- បុគ្គលដែលពាក់ព័ន្ធបានគេចខ្លួន មិនដឹងជាស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។
- ចៅក្រមស៊ើបសួរត្រូវសុំយោបល់ពីព្រះរាជអាជ្ញាជាមុនសិន[103] (យោបល់របស់ព្រះរាជអាជ្ញាមិនចងកាតព្វកិច្ចឱ្យចៅក្រមស៊ើបសួរត្រូវតែអនុវត្តនោះឡើយ) ។

ក្រោយពីបានទទួលយោបល់ពីព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវចេញដីកាបង្គាប់ឱ្យចាប់ខ្លួនដោយមានចែងមូលហេតុជាអាទិ៍ ៖ បានគេចខ្លួន ឬមិនដឹងជាស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ ព្រះរាជអាជ្ញាជាអ្នកផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន ។ ក្នុងករណីបន្ទាន់ ការផ្សព្វផ្សាយទៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ត្រូវធ្វើតាមគ្រប់មធ្យោបាយ ហើយបើក្នុងករណីចាំបាច់ដីកាបង្គាប់ឱ្យចាប់ខ្លួនអាចផ្សព្វផ្សាយជាលក្ខណៈអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌ដោយប្រើយន្តការនានាដែលមានប្រសិទ្ធភាព ។ ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន ត្រូវប្រគល់ឱ្យមន្ត្រីនគរនបាលយុត្តិធម៌ ដែលមានកាតព្វកិច្ចស្វែងរកចាប់ខ្លួន និងនាំបុគ្គលដែលពាក់ពន្ធទៅពន្ធនាគារ ឬមណ្ឌលឃុំ ហើយប្រធានពន្ធនាគារ ឬមណ្ឌលឃុំត្រូវតែទទួល និងឃុំខ្លួនបុគ្គលនោះ ។ បុគ្គលដែលពាក់ពន្ធ ត្រូវតែនាំទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសចៅក្រមស៊ើបសួរនៅថ្ងៃបន្ទាប់ពីការចាប់ ។ ក្នុងករណីដែលពុំអាចធ្វើដូច្នេះបាន បុគ្គលដែលពាក់ពន្ធត្រូវបានសួរចម្លើយដោយព្រះរាជអាជ្ញានៅកន្លែងឃុំខ្លួន ហើយព្រះរាជអាជ្ញាត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរនូវកំណត់ហេតុសួរចម្លើយនោះ ។ ដូចគ្នានឹងការប្រតិបត្តិដីកាបង្គាប់ឱ្យនាំខ្លួនដែរ ប្រការដែលត្រូវជៀសវាងដាច់ខាត ដើម្បីកុំឱ្យមានរំលោភលើសិទ្ធិបុគ្គល មន្ត្រីនគរបាលយុត្តិធម៌ដែលអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន មិនអាចចូលទៅក្នុងលំនៅដ្ឋានរបស់បុគ្គលដែលពាក់ពន្ធមុនម៉ោង៦ ព្រឹក និងក្រោយម៉ោង១៨ល្ងាចបានទេ[104] ។

#### ៣.១.៤. ដីកាបង្គាប់ឱ្យឃុំខ្លួន

ដីកានេះ គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនដែលត្រូវតែឱ្យទទួលនិងឃុំខ្លួនជនត្រូវចោទរហូតទាល់តែបានទទួលដំណឹងអំពីការដោះលែងឱ្យមានសេរីភាពវិញ ។ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន លុះត្រាតែមានសេចក្តីសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នជាមុនសិន ហើយអាចបង្គាប់ឱ្យឃុំខ្លួនបុគ្គលណាម្នាក់បាន លុះត្រាតែជនត្រូវចោទនោះជាកម្មវត្ថុនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នតែប៉ុណ្ណោះ[105] ។ ប៉ុន្តែ ចៅក្រមស៊ើបសួរមិនអាចចេញដីកាបង្គាប់ឱ្យឃុំខ្លួនបុគ្គលណាម្នាក់ ដោយមិនមានដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នឡើយ ។

### ៣.២. សិទ្ធិអំណាច ត្រួតពិនិត្យថែរក្សាជនត្រូវចោទ

ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចពេញលេញ ក្នុងការសួរចម្លើយជនត្រូវចោទ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សាក្សី ការសួរតទល់ភាគី ការចុះទៅដល់ទីកន្លែងកើតហេតុ ការឆែកឆេរ ការចាប់យកវត្ថុតាង

[103] មាត្រា ១៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[104] មាត្រា ១៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[105] មាត្រា ២១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

កោសលវិច័យ និងការស្តាប់ទូរស័ព្ទ ។ ក្រៅពីនេះ ចៅក្រមស៊ើបសួរក៏មានអំណាច ដាក់ជនត្រូវចោទរូបណាម្នាក់ ត្រួតពិនិត្យតាមផ្លូវតុលាការ ឬឃុំខ្លួនជននោះជាបណ្តោះអាសន្ន។ គោលបំណងនៃការឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្នជាការចាំបាច់[106]៖ ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី និងរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិត ក្នុងនោះ ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ និងធានារក្សាការពារសន្តិសុខឱ្យជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី ។ មួយវិញទៀត ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើសផងដែរ ។ ជាទូទៅ ចំពោះថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ដាច់ដោយឡែកពីគ្នាទៅតាមស្ថានភាពនៃជនត្រូវចោទ (នីតិជន ឬអនីតិជន) ឬលក្ខណៈនៃបទល្មើស (បទមជ្ឈិម ឬបទឧក្រិដ្ឋ)។ ក្រៅពីនីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរក៏អាចប្រើប្រាស់នីតិវិធីមួយបែបទៀតដែលហៅថា **ការដាក់ជនត្រូវចោទស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ** ភាសាសាមញ្ញហៅថា ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំបណ្តោះអាសន្ន បានន័យថា នៅពេលដែលបុគ្គលណាម្នាក់បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ នោះព្រះរាជអាជ្ញានឹងធ្វើការចោទប្រកាន់រួច បញ្ជូនជននោះទៅចៅក្រមស៊ើបសួរដើម្បីធ្វើកិច្ចស៊ើបសួរដាក់បន្ទុក ឬដោះបន្ទុក ហើយប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាអំពើដែលបានប្រព្រឹត្តជាបទឧក្រិដ្ឋ ឬបទមជ្ឈិម បានបង្កព្យសនកម្មធ្ងន់ធ្ងរដល់សង្គម នោះចៅក្រមស៊ើបសួរអាចធ្វើការឃុំខ្លួនបុគ្គលនោះដើម្បីបញ្ចប់ ឬបង្ការបទល្មើសកុំឱ្យកើតឡើងជាថ្មី និងកុំឱ្យប៉ះពាល់ដល់នីតិវិធីស៊ើបសួរ។ ប៉ុន្តែប្រសិនបើអំពើនោះបានបង្កព្យសនកម្មតិចតួចដល់សង្គមជាតិ ហើយមានមូលហេតុសមស្របតាមច្បាប់ ដែលមិនធ្វើឱ្យប៉ះពាល់ដល់នីតិវិធីស៊ើបសួរទេ នោះចៅក្រមស៊ើបសួរអាចសម្រេច ដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលាដោយស្ថិតក្នុងដំណាក់កាលស៊ើបសួរ។ ម្យ៉ាងវិញទៀត ជាផ្នែកមួយនៃវិធានការនិរន្តរាយ[107] ដើម្បីធានាសម្រួលដល់ដំណើរការនៃកិច្ចស៊ើបសួរ ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ (នៅក្រៅឃុំ) ឬសម្រេចឃុំខ្លួនបណ្តោះអាសន្ន (នៅក្នុងឃុំ)។

### ៣.២.១. ការឃុំខ្លួនបណ្តោះអាសន្ន

ពាក្យថា ឃាត់ខ្លួន[108] សំដៅលើការឃាត់ធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ក្នុងដំណាក់កាលស៊ើបអង្កេត រីឯពាក្យថា ឃុំខ្លួន ត្រូវបានប្រើប្រាស់ក្នុងដំណាក់កាលស៊ើបសួររបស់ចៅក្រមស៊ើបសួរ។ ជាគោលការណ៍ជនត្រូវចោទ ត្រូវតែមានសេរីភាព ប៉ុន្តែក្នុងករណីពិសេសជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្តោះអាសន្ននៅក្នុងលក្ខខណ្ឌដែលបានចែងនៅក្នុងច្បាប់។ ការឃុំខ្លួនបណ្តោះអាសន្ននេះ គឺធ្វើឡើងតាមស្ថានភាពជាក់ស្តែងនៃសង្គមបច្ចុប្បន្ន នៅពេលកើតមានបទល្មើសណាមួយដែលមានចរិតលក្ខណៈធ្ងន់ធ្ងរ ជនដែលបានប្រព្រឹត្តបទល្មើសអាចនឹងត្រូវបានគេឃាត់ខ្លួនភ្លាមៗ ឬអាចសម្រេចឃុំខ្លួនជាដើម ដើម្បីធានាបាននូវសណ្តាប់ធ្នាប់ ឬកើតមានផលប៉ះពាល់កាន់តែធ្ងន់ធ្ងរជាងមុនពីអំពើល្មើសនោះ ។ ប៉ុន្តែមិនមែនគ្រប់ពេលដែលមានបទល្មើសកើត

[106] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[107] មាត្រា ២២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[108] មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ឡើង ការសម្រេចឃុំត្រូវតែធ្វើឡើងនោះទេ ពោលគឺត្រូវសិក្សាទៅលើស្ថានភាពនៃបទល្មើស ក៏ដូចជាស្ថានភាពជនដែលបានប្រព្រឹត្តបទល្មើសជាមុនសិន ដើម្បីជៀសវាងថាការសម្រេចឃុំខ្លួននោះ នឹងអាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងសេរីភាពបុគ្គលរបស់ពួកគេ ។

### ៣.២.១.១. មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្ន ជានីតិវិធីមួយដែលធ្វើឡើងនៅមុនពេលជម្រះក្តី ក្នុងពេលដែលសំណុំរឿងព្រហ្មទណ្ឌស្ថិតនៅក្នុងដំណាក់កាលរបស់ចៅក្រមស៊ើបសួរ ។ ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើឡើងបានក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬមជ្ឈិម ដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ) ឆ្នាំ ឡើងទៅ[109] ។ ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួនបណ្តោះអាសន្ននេះ ជាការចាំបាច់[110] ៖

១. ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី ។

២. ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិត ។

៣. ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ ។

៤. ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី ។

៥. ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ ។

៦. ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស ។

### ៣.២.១.២. លក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន

ជាទូទៅការឃុំខ្លួនបណ្តោះអាសន្ន អាចធ្វើឡើងតាមរយៈគំនិតផ្តើមពីចៅក្រមស៊ើបសួរ ឬ តាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ដោយយោងតាមការពិចារណា ការស្វែងយល់ដោយផ្ទាល់ទៅលើបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ ឬស្ថានភាពជាក់ស្តែងនៃបទល្មើសដែលបានប្រព្រឹត្ត ។ ក្នុងករណីបើជនត្រូវចោទ មានមេធាវីអម នោះមេធាវីត្រូវរកមធ្យោបាយការពារខ្លួនជនត្រូវចោទ ចំណែកឯចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នតាមដីកាដោយមានសម្អាងហេតុ ព្រមទាំងជូនដំណឹងភ្លាមៗដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ផ្ទុយមកវិញ កាលណាចៅក្រមស៊ើបសួរដែលទទួលបណ្តឹងតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាដែលសុំឱ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ននោះ មិនព្រមធ្វើតាមការសុំឱ្យឃុំខ្លួននោះទេ ចៅក្រមស៊ើបសួរ ត្រូវចេញក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នូវដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ដោយមិន ចាំបាច់មានសម្អាងហេតុទេ។ ដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់អ្នកប្តឹងសុំ ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចនៅក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ព្រះរាជអាជ្ញា អាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរ ដែលនឹងសម្រេចជំនួសចៅក្រមស៊ើបសួរ[111] ។

---

[109] មាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[110] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[111] មាត្រា ២០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ៣.២.១.៣. ថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

នៅពេលដែលចៅក្រមស៊ើបសួរសម្រេចពីការឃុំខ្លួនបណ្ដោះអាសន្ន នោះគឺត្រូវធ្វើឡើងតាមរយៈ «ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន» ដែលត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ ។ ចំពោះថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ដាច់ដោយឡែកពីគ្នាទៅតាមស្ថានភាពនៃជនត្រូវចោទ (នីតិជន ឬអនីតិជន) ឬលក្ខណៈនៃបទល្មើស (បទមជ្ឈឹម ឬបទឧក្រិដ្ឋ)។

**១. ជនត្រូវចោទជានីតិជន ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នត្រូវកំណត់ដូចខាងក្រោម៖**

ចំពោះនីតិជនដែលត្រូវចោទបានប្រកាន់ពីបទឧក្រិដ្ឋ ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី៦ (ប្រាំមួយ) ខែ បានទេ ។ ប៉ុន្តែនៅពេលជិតផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នម្ដងបាន ៦ (ប្រាំមួយ) ខែ ហើយការសម្រេចពន្យារនេះអាចធ្វើបានតែ ២ (ពីរ) ដងគត់[112]។

ចំពោះនីតិជនដែលត្រូវចោទប្រកាន់ពីបទមជ្ឈឹម ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន)ខែបានទេ។ ប៉ុន្តែនៅពេលដែលជិតផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះ អាសន្នបានម្ដងគត់ ដោយមិនអាចលើសពី ២ (ពីរ) ខែ[113]។

**២. ជនត្រូវចោទជាអនីតិជនថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នត្រូវកំណត់ដូចខាងក្រោម៖**

២.១. ចំពោះអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំនឹងត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋដែលថិរវេលាឃុំខ្លួនបណ្ដោះអាសន្នមានដូចតទៅ[114]៖

-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ កាលណាអនីតិជននេះមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ ។

-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែ បានទេ កាលណាអនីតិជននេះមានអាយុចាប់ពី១៦ (ដប់ប្រាំមួយ) ឆ្នាំដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

២.២. បើក្នុងករណីជាបទមជ្ឈិមវិញ ការឃុំខ្លួនបណ្ដោះអាសន្នចំពោះអនីតិជនអាយុចាប់ពី១៤ (ដប់បួន) ឆ្នាំ ដល់ ក្រោម ១៨ (ដប់ប្រាំបី) ត្រូវបានកំណត់ដូចខាងក្រោម[115]៖

-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ២ (ពីរ) ខែ បានទេ កាលណាអនីតិជននេះមានអាយុតិចជាង១៦ (ដប់ប្រាំមួយ) ឆ្នាំ។

-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែបានទេកាលណាអនីតិជននេះមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នតាមចំណុចទី ២.១ និងចំណុច ២.២ ខាងលើនេះមិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ ។

---

[112] មាត្រា ២០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[113] មាត្រា ២០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[114] មាត្រា ២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[115] មាត្រា ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំវិញ មិនអាចត្រូវបានឃុំខ្លួនបណ្ដោះអាសន្នទេ[116] ។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននេះឱ្យឪពុកម្ដាយ អ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្ដោះអាសន្ន រង់ចាំសេចក្ដីសម្រេចរបស់តុលាការផងដែរ។

ក្នុងករណីអនីតិជនដែលកំពុងជាប់ឃុំត្រូវ រកឃើញថាមានអាយុក្រោម១៤ ឆ្នាំ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ និងបង្គាប់ឱ្យដោះលែងអនីតិជននោះជាបន្ទាន់ទោះបីមានបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ ។

### ៣.២.១.៤. អានុភាពនៃការឃុំខ្លួនបណ្ដោះអាសន្ន

ការឃុំខ្លួនបណ្ដោះអាសន្នមានអានុភាពដោយសារ ការចេញដីកាបង្គាប់ឱ្យឃុំខ្លួនរបស់ចៅក្រមស៊ើបសួរ[117] ហើយដីកាបង្គាប់ឱ្យឃុំខ្លួន គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឱ្យឃុំខ្លួនជនត្រូវចោទ ។ ចៅក្រមស៊ើបសួរអាចនឹងចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន លុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន។ ចំណែកឯប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនបុគ្គលដែលមានដីកាបង្គាប់ឱ្យ ឃុំខ្លួនរហូតទាល់តែបានទទួលការឱ្យដំណឹងអំពីការដោះលែងឱ្យមានសេរីភាពវិញ ។ ចំណែកប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវរក្សាទុកដើមដីកាបង្គាប់ឱ្យឃុំខ្លួន ឬចុងដីកានេះ ដែលបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម[118] ។

### ៣.៣. ការត្រួតពិនិត្យតាមផ្លូវតុលាការ

តាមក្រមនីតិវិធីព្រហ្មទណ្ឌពុំបានឱ្យនិយមន័យនៃការត្រួតពិនិត្យតាមផ្លូវតុលាការនោះទេ ប៉ុន្តែយើងអាចកំណត់បានថា វាជាវិធានការនិរន្តរាយមួយ ដូចការណ៍នៃការឃុំខ្លួនបណ្ដោះអាសន្នដែរ គ្រាន់ តែវាជាវិធានមួយដែលមានស្ថានភាពស្រាលជាង ។ ជាធម្មតា នៅពេលដែលជនត្រូវចោទ បានឈានទៅដល់ដំណាក់កាលរបស់ចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរ អាចសម្រេចថាឃុំខ្លួនជននោះ ឬ សម្រេចដាក់ជននោះឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលវិធានការណ៍ នៃការដាក់ឱ្យត្រួតពិនិត្យតាមផ្លូវតុលាការនេះដែរ គឺបានកម្រិតសិទ្ធិរបស់ជនត្រូវចោទឱ្យនៅក្រោមការបង្គាប់របស់ចៅក្រមស៊ើបសួរ ដែលការហាមប្រាមចំនួន១២ ចំណុច[119]។ ចំពោះវិធានការណ៍ នៃការត្រួតពិនិត្យតាមផ្លូវតុលាការនេះដែរ គឺមានលក្ខណៈ រាងធូរស្រាលជាង ការឃុំខ្លួនបណ្ដោះអាសន្ន ពីព្រោះថាវិធានការណ៍នេះគឺ បាន ផ្ដល់នូវសេរីភាពជូនជនត្រូវចោទ ឱ្យនៅក្រៅឃុំ ប៉ុន្តែត្រូវគោរពទៅតាម ចៅក្រមស៊ើបសួរបានកំណត់ចំពោះជន នោះ។ ប៉ុន្តែ ប្រសិនបើជនត្រូវចោទនោះមិនគោរពទៅតាមអ្វីដែលចៅក្រមស៊ើបសួរបានកំណត់នោះទេ នោះចៅក្រម ស៊ើបសួរ អាចសម្រេចឃុំខ្លួនបណ្ដោះអាសន្នចំពោះជនត្រូវចោទនោះបានដោយឆន្ទានុសិទ្ធិរបស់ខ្លួនផ្ទាល់[120]។

---

[116] មាត្រា ២១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ និង មាត្រា ៣៩ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន

[117] មាត្រា ២១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[118] មាត្រា ២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[119] មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[120] មាត្រា ២២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ៣.៣.១. ដីកាបង្គាប់ឱ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយតាមគំនិតផ្តួចផ្តើមផ្ទាល់របស់ខ្លួន ឬ តាមសេចក្តីសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា[121]។ ដោយចៅក្រមស៊ើបសួរត្រូវចេញដីកាបញ្ជាក់ នៅក្នុងដីកាបង្គាប់ឱ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលជាសេចក្តីសម្រេចរបស់ខ្លួន អំពីកាតព្វកិច្ច ដែលតម្រូវទៅលើជនត្រូវចោទ ហើយដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវជូន ដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ"។

ការត្រួតពិនិត្យតាមផ្លូវតុលាការនេះផងដែរ យើងសង្កេតឃើញថា ព្រះរាជអាជ្ញាក៏អាចធ្វើសេចក្តីសន្និដ្ឋានសុំឱ្យដាក់ខ្លួនជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានផងដែរ។ ប៉ុន្តែសេចក្តីសន្និដ្ឋានរបស់ ព្រះរាជអាជ្ញាអាចត្រូវបានចៅក្រមស៊ើបសួរ បដិសេធចំពោះពាក្យសុំនោះបាន ដោយចៅក្រមស៊ើបសួរត្រូវចេញដីកា បដិសេធការសុំនេះក្នុងរយៈពេល ៥ ថ្ងៃ។ ជាងនេះទៅទៀតយើងមើលឃើញថា ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអនុវត្ត នៅពេលបច្ចុប្បន្ននេះ មិនបានកំណត់ថា[122] រយៈពេលណាមួយច្បាស់លាស់ដែលចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងនូវសេចក្តីសម្រេចបដិសេធការស្នើសុំរបស់ព្រះរាជអាជ្ញានោះទេ ដោយគ្រាន់តែបញ្ជាក់ថា ចៅក្រម ស៊ើបសួរត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញាចំពោះដីកាសម្រេចរបស់ខ្លួន ដោយឡែកប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ ថ្ងៃ នោះទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្តឹងទៅសភាស៊ើប សួរ ដែលដែលមានសមត្ថកិច្ចសម្រេចជំនួសចៅក្រមស៊ើបសួរ។

### ៣.៣.២. កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរអាចសម្រេចដាក់ជនត្រូវចោទទាំងឡាយ ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ប្រសិនបើជននោះត្រូវបានចោទប្រកាន់ អំពីបទល្មើស ដែលត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារ។ ការត្រួតពិនិត្យតាមផ្លូវតុលាការនេះទៀតសោត គឺមានអានុភាពបង្គាប់ឱ្យជនត្រូវចោទដែល នៅក្រៅឃុំ ឱ្យគោរពទៅតាមលក្ខខណ្ឌដែលមានដូចខាងក្រោម[123]៖

១. មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីដែលចៅក្រមស៊ើបសួរបានកំណត់

២. មិនត្រូវប្តូរលំនៅដ្ឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ

៣. មិនត្រូវទៅកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ

៤.ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រម ស៊ើបសួរ

៥. ត្រូវឆ្លើយតបនឹងការ កោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ

៦. ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ

៧. មិនត្រូវបើកបររថយន្ត

៨. មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ

---

[121] មាត្រា ២២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[122] មាត្រា ២២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[123] មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

៩. ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងថិរវេលាបង់ប្រាក់នេះ ត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរ ដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ

១០. មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធនានា ហើយត្រូវប្រគល់ជូននូវអាវុធទាំងនោះដល់ការិយាល័យ ក្រឡាបញ្ជី

១១. ត្រូវប្រគល់ខ្លួនឱ្យពេទ្យពិនិត្យព្យាបាល និងស្ថិតក្រោមការព្យាបាលក្នុងមន្ទីរពេទ្យ

១២. មិនត្រូវប្រកបធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះៗ

ជាអញ្ញាត្រកម្ម អនីតិជនអាយុតិចជាង១៤ឆ្នាំមិនអាចត្រូវដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាម ផ្លូវតុលាការទេ ពីព្រោះថាមិនទាន់ដល់នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។

## ផ្នែកទី៤៖ ការបិទការស៊ើបសួរ

### ៤.១. ការជូនដំណឹងពីការបិទការស៊ើបសួរ

ចៅក្រមស៊ើបសួរ ពិនិត្យវាយតម្លៃដោយអធិបតេយ្យនូវខណៈពេលដែលត្រូវបញ្ចប់ការស៊ើបសួរជាអាទិ៍នៅពេលដែលចៅក្រមស៊ើបសួរយល់ឃើញថា ការរកភស្តុតាងមិនតម្រូវឱ្យមានកិច្ចសារស្រាវជ្រាវអ្វីមួយនោះចៅក្រមសម្រេចបិទការស៊ើបសួរដោយអធិបតេយ្យរបស់គាត់ ។ ក្រមនីតិវិធីព្រហ្មទណ្ឌពុំបានចែងពីថេរវេលានៃការស៊ើបសួរទេ ។ ប៉ុន្តែយើងអាចគិតថាវាជាសមត្ថកិច្ចរបស់សភាស៊ើបសួរក្នុងការធានារ៉ាប់រងឱ្យការស៊ើបសួរនេះ ធ្វើឡើងក្នុងថេរវេលាសមរម្យមួយ ដោយពុំទុកឱ្យសំណុំរឿងជួប និងរយៈពេលអសកម្មយូរពេក ។ តែកាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរត្រូវបានបញ្ចប់ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មាននេះ ទៅព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវី ហើយ ២ ថ្ងៃក្រោយមកចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ[124] ។ ការជូនព័ត៌មានអំពីការបិទការស៊ើបសួរនេះ គឺទុកលទ្ធភាពឱ្យភាគីមានឱកាសផ្ដល់ភស្តុតាងផ្សេងៗបន្ថែម ឬស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរណាមួយដែលភាគីយល់ថាមានប្រយោជន៍សម្រាប់រឿងក្ដីរបស់ខ្លួន និងម្យ៉ាងវិញទៀត ភាគីអាចមានសិទ្ធិក្នុងការប្ដឹងសុំមោឃភាពនូវអនិយ័តភាពកិច្ចនីតិវិធីណាមួយ ។ ដែលនៅចំណុចចុងក្រោយនេះ មានសារៈសំខាន់បំផុត និងការគោរពនូវសិទ្ធិ និងផលប្រយោជន៍របស់ភាគីផងដែរ ពីព្រោះពេលណាដែលចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយរួចហើយ ដីកានេះនឹងលុបលាងមោឃភាពនៃនីតិវិធីមុន ហើយគ្មានមោឃភាពណាមួយនៃនីតិវិធីមុនអាចត្រូវបានលើកឡើងនៅចំពោះមុខតុលាការជនុំជម្រះបានទៀតឡើយ ។

នៅពេលដែលព្រះរាជអាជ្ញាទទួលសំណុំរឿងមកពិនិត្យ ប្រសិនបើយល់ឃើញថា ចាំបាច់ធ្វើកិច្ចស៊ើបសួរថ្មីទៀតនោះ ព្រះរាជអាជ្ញាត្រូវអនុវត្តតាមវិធានការស្នើសុំឱ្យបំពេញកិច្ច[125] ពោលគឺ នៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ ។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញានោះទេ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធក្នុងរយៈពេល ១៥ ថ្ងៃ ដីកានេះត្រូវមានសម្អាងហេតុ ហើយនិងត្រូវតែជូនដំណឹងដល់ព្រះរាជអាជ្ញា

---

124 មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

125 មាត្រា ១៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ក្នុងចិរវេលាយ៉ាងឆាប់បំផុត ។ ក្នុងករណីដែលមិនបានសម្រេចក្នុងរយៈពេល១៥ ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្ដឹងដោយផ្ទាល់តាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

### ៤.២.ការបិទការស៊ើបសួរតាមបណ្ដឹងសុំរបស់ភាគី

ដូចដែលបានរៀបរាប់ពីខាងលើមកហើយថា ការសម្រេចបិទការស៊ើបសួរ ជានិច្ចកាលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ក៏ប៉ុន្តែថេរវេលានៃការបិទការស៊ើបសួរនេះ ក្រមនីតិវិធីព្រហ្មទណ្ឌពុំមានចែងកំណត់ពេលណាមួយច្បាស់លាស់នោះទេ ។ មានឃ្លាមួយបានលើកឡើងថា យុត្តិធម៌ដែលបានមកប្រកបដោយភាពយឺតយ៉ាវស្មើនឹងអយុត្តិធម៌ ដែលនេះគឺជាពាក្យស្លោកដែលអ្នកច្បាប់បានតាក់តែង និងអ្នកអនុវត្តច្បាប់យកមកពិចារណាទៅតាមស្ថានភាពក្នុងសង្គមជាក់ស្ដែង ។ កាលណាបើរឿងក្ដីមួយត្រូវបានអូសបន្លាយ រយៈពេលយូរហួសហេតុវាជាផលពិបាកដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីផងដែរ ។ ហេតុផលនេះហើយ ទើបក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិនូវបទប្បញ្ញត្តិមួយចំនួនដែលអនុញ្ញាតឱ្យភាគីបានចូលរួមធ្វើសកម្មភាពក្នុងដំណើរការកិច្ចនីតិវិធីព្រហ្មទណ្ឌ ដើម្បីបញ្ចៀសភាពអសកម្មនៃកិច្ចនីតិវិធីស៊ើបសួរ ។

ចំណែកភាគីនៃរឿងក្ដីព្រហ្មទណ្ឌ ជាអាទិ៍ ជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី មានសិទ្ធិធ្វើពាក្យស្នើសុំឱ្យចៅក្រមស៊ើបសួរបញ្ឈប់ការស៊ើបសួរបាននៅពេលផុតចិរវេលា ១ឆ្នាំ គិតពីថ្ងៃចោទប្រកាន់ ជនត្រូវចោទអាចសុំឱ្យបិទការស៊ើបសួរ ។ នៅពេលផុតចិរវេលា ១ឆ្នាំ[126] គិតពីថ្ងៃតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដើមបណ្ដឹងរដ្ឋប្បវេណីអាចស្នើសុំឱ្យបិទការស៊ើបសួរបាន ។ ក្នុងរយៈពេល១ខែ គិតពីថ្ងៃទទួលពាក្យសុំនេះ ចៅក្រមស៊ើបសួរត្រូវតែសម្រេច ប្រសិនបើចៅក្រមមិនសម្រេចនៅក្នុងរយៈពេលនោះទេ អ្នកស្នើសុំអាចប្ដឹងទៅប្រធានសភាស៊ើបសួរដែលធ្វើអធិបញ្ញាឱ្យចៅក្រមស៊ើបសួរសម្រេច ។ ពាក្យសុំឱ្យបិទការស៊ើបសួរ អាចត្រូវប្រើប្រាស់ដោយមេធាវីបាន ។

## ផ្នែកទី៤៖ ដីកាដំណោះស្រាយ

នៅក្នុងនីតិវិធីព្រហ្មទណ្ឌដីកាមានច្រើនប្រភេទណាស់។ ដីកាទាំងនោះមានមុខងារ ខុសៗគ្នាទៅតាមអត្ថន័យនៃដីកានោះ។ គោលបំណងនៃការចេញដីកាទាំងនោះគឺដើម្បីជួយសម្រួលដល់នីតិវិធីឱ្យមានដំណើរការល្អ និងជម្រុញឱ្យនីតិវិធីមានភាពឆាប់រហ័សផងដែរ។ បើមើលទៅតាមដំណាក់នីមួយៗនៃនីតិវិធីព្រហ្មទណ្ឌ គ្រប់ដំណាក់កាលទាំងអស់សុទ្ធសឹងតែមានការចេញដីកាដើម្បីបំពេញកិច្ចណាមួយក្នុងនីតិវិធី។ ជាក់ស្ដែងនៅក្នុងដំណាក់ស៊ើបសួរដើម្បីធ្វើការបញ្ចប់ការស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវចេញដីកាមួយប្រភេទ ដើម្បីបញ្ចប់ការស៊ើបសួរ ឬបិទការស៊ើបសួរ។ កាលណាបើការស៊ើបសួរត្រូវបានចប់សព្វគ្រប់នោះ នៅក្នុងពេលនោះដែរ ចៅក្រមស៊ើបសួរត្រូវចេញនូវ ដីកាមួយ ដើម្បីសម្រេចថាត្រូវបញ្ជូនជននោះទៅជំនុំជម្រះ ឬធ្វើការលើកលែងការចោទប្រកាន់[127]។ ចំពោះជនត្រូវចោទ នោះ ដែលដីកានេះដែរត្រូវបានគេឱ្យឈ្មោះថា ដីកាដំណោះស្រាយ។ ដីកាដំណោះស្រាយ គឺជាដីកាដែលចៅក្រមស៊ើបសួរចេញដើម្បីបិទការស៊ើបសួរ ហើយដីកាដំណោះស្រាយ អាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់។ ដីកាបញ្ជូន ទៅជំនុំជម្រះ ត្រូវចេញនៅពេលដែល

---

[126] មាត្រា ២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[127] មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ចៅក្រមស៊ើបសួរយល់ឃើញថា អំពើដែលជនត្រូវចោទបានប្រព្រឹត្តនោះ ជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដោយសម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ និងត្រូវរៀបរាប់ពីអំពើដែលត្រូវចោទប្រកាន់ និង ឈ្មោះបទល្មើសតាមច្បាប់កំណត់ជាធរមាន។ ដីកាលើកលែងការចោទប្រកាន់ ត្រូវចេញនៅពេលដែលចៅក្រម ស៊ើបសួរយល់ឃើញថា អំពើនោះមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ ឬជនដែលបានប្រព្រឹត្តអំពើនោះ នៅតែគេមិនស្គាល់មុខ គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ឬករណីដែលបណ្ដឹងអាជ្ញារលត់។ ជា និច្ចកាល ដីកាដំណោះស្រាយចេញដោយចៅក្រមស៊ើបសួរ ត្រូវមានសម្អាងហេតុ និងត្រូវជូនដំណឹងអំពីការបិទ ការស៊ើបសួរដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងរយៈពេលខ្លីបំផុត ដើម្បីអ្នកពាក់ព័ន្ធ បានជ្រាបព័ត៌មានអំពីដីកាដំណោះស្រាយនេះ។ ចំពោះដីកាដំណោះស្រាយ នេះទៀតសោត គឺ មានអានុភាព បញ្ចប់នូវការឃុំខ្លួនបណ្ដោះអាសន្ន និងការដាក់ត្រួតពិនិត្យតាមផ្លូវតុលាការ ទាំងឡាយ ដើម្បីដោះ លែងខ្លួនជន នោះឱ្យមានសេរីភាព ដើម្បីយកជននោះទៅជំនុំជម្រះ ឬមានសេរីភាពពេញលេញ ប្រសិនបើ ចៅក្រម ស៊ើបសួរ សម្រេចលើកលែងការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន ចំពោះជនត្រូវចោទនោះ។ ក្នុងករណី ដែលសំណុំរឿងស៊ើបសួរពាក់ព័ន្ធនឹងអង្គហេតុច្រើន ចៅក្រមស៊ើបសួរអាចចេញដីកាដំណោះស្រាយចំពោះអង្គ ហេតុដែលការស៊ើបសួរបានចប់សព្វគ្រប់ និងបន្តការស៊ើបសួរចំពោះអង្គហេតុផ្សេងទៀតបាន។ ចៅក្រមស៊ើប សួរក៏អាចចេញដីកាលើកលែងចោទប្រកាន់ ចំពោះជនត្រូវចោទដែលបានស៊ើបសួររកឃើញថា មិនមានការពាក់ ព័ន្ធនឹងការប្រព្រឹត្តបទល្មើស ឬការចូលរួមប្រព្រឹត្តបទល្មើស និងធ្វើការស៊ើបសួររកអត្តសញ្ញាណជនល្មើសបន្ត ទៀតបាន។ មិនតែ ប៉ុណ្ណោះនៅពេលចេញ ដីកាដំណោះស្រាយនេះដែរចៅក្រមស៊ើបសួរក៏ អាចសម្រេចប្រគល់ វត្ថុដែល យកមកធ្វើជាវត្ថុ តាង ទៅឱ្យម្ចាស់ដើមវិញ ប្រសិនបើគាត់យល់ឃើញថា វាគ្មានភាពស៊ីសង្វាក់ ទៅនឹង បទល្មើសដែល បានកើត ឡើង។ ដីកាដំណោះស្រាយ មានអានុភាពបញ្ចប់ការឃុំខ្លួនបណ្ដោះអាសន្ន ប៉ុន្តែ ចៅក្រមស៊ើបសួរ អាចរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំជាបណ្ដោះអាសន្ន រហូតដល់ពេលចូលបង្ហាញខ្លួននៅ ចំពោះមុខតុលាការជំនុំជម្រះ តាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ដោយសេចក្តីសម្រេចរក្សា ទុកជនត្រូវចោទក្នុងឃុំជាបណ្ដោះអាសន្នលែងមានអានុភាពក្នុងរយៈពេល ៤ ខែ ហើយប្រសិនបើជនត្រូវចោទ មិនបានបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងរយៈពេលខាងលើនេះទេ ជនត្រូវចោទត្រូវដោះលែងឱ្យនៅក្រៅឃុំ ជាបណ្ដោះអាសន្នដោយឯកឯង។ មិនតែប៉ុណ្ណោះ ដីកាដំណោះស្រាយ ក៏មានអានុភាពបញ្ចប់ការត្រួតពិនិត្យ តាមផ្លូវតុលាការផងដែរ ប៉ុន្តែតាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចរក្សា ទុកជនត្រូវចោទ ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលបង្ហាញខ្លួននៅចំពោះមុខតុលា ការ។

ក្រោយពេលដែលដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរបានចូលជាស្ថាពរហើយ ប្រសិនបើមានភស្តុតាងដាក់បន្ទុកថ្មីបានផ្ទុះឡើង[128] ការស៊ើបសួរអាចបើកឡើងវិញបាន តាមគំនិតផ្តួចផ្តើម

[128] មាត្រា ២៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

របស់ព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា មានសិទ្ធអាចប្តឹងរាល់សេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរទាំងអស់ ដែលបានសម្រេចនាដំណាក់កាលនៃការស៊ើបសួរ។ ជាងនេះទៅទៀត ដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញា និងអគ្គ ព្រះរាជអាជ្ញា អាចប្តឹងទាស់ចំពោះដីកាដំណោះស្រាយ របស់ចៅក្រមស៊ើបសួរដែលបានសម្រេចបាន។

### ៤.១. ការលើកលែងការចោទប្រកាន់

ក្នុងករណីដែលចៅក្រមស៊ើបសួរយល់ឃើញថាសំណុំរឿងដែលខ្លួនបានទទួលពីព្រះរាជអាជ្ញា តាមរយៈដីកាបញ្ជូនរឿងឱ្យស៊ើបសួរនោះ គឺជាបទល្មើស ដែលអាចជាបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ នោះចៅក្រមស៊ើបសួរត្រូវតែបញ្ជូនរឿងទៅជំនុំជម្រះ។ ប្រសិនបើចៅក្រមស៊ើបសួរបានសម្រេចចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដីកានេះត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីអំពើដែលត្រូវបានចោទប្រកាន់ ព្រមទាំងកំណត់ឈ្មោះបទល្មើសដែលច្បាប់បានកំណត់ផងដែរ។ ការសម្រេចបញ្ជូនទៅជំនុំជម្រះនេះចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅជនត្រូវចោទ ព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីក្នុងរយៈពេលខ្លីបំផុត។

ចំពោះដីកាលើកលែងការចោទប្រកាន់ចៅក្រមស៊ើបសួរអាចចេញបានលុះត្រាតែមានមូលហេតុដូចខាងក្រោយតែប៉ុណ្ណោះ រួមមាន[129]៖

#### ១. អំពើដែលត្រូវបានចោទប្រកាន់មិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ

ជាគោលការណ៍ ដើម្បីចោទប្រកាន់អំពើណាមួយជាបទល្មើសបាននោះលុះត្រាអំពើនោះត្រូវមាននៅធាតុផ្សំ៣ គឺធាតុនីត្យានុកូលភាព (ធាតុច្បាប់) ធាតុសត្យានុម័ត (ធាតុសម្ភារៈ)ធាតុអត្តនោម័ត (ធាតុចេតនា)។ ក្នុងករណីដែលចៅក្រមបានស៊ើបសួរទៅស្រាប់តែឃើញថា ជនត្រូវចោទដែលព្រះរាជអាជ្ញាបញ្ជូនមកនោះពុំបានប្រព្រឹត្តអំពើដែលជាបទល្មើសនោះចៅក្រមស៊ើបសួរមិនអាចដាក់បន្ទុកបាននោះឡើង។ គួរចាំផងដែរថា ចៅក្រមស៊ើបសួរស៊ើបសួរក្នុងគោលបំណងដើម្បីដាក់បន្ទុក និងដោះបន្ទុក ដូច្នេះការដាក់បន្ទុកនៃចៅក្រមស៊ើបគឺដើម្បីបញ្ជូនទៅជំនុំជម្រះ រីឯការស៊ើបសួរ ដោះបន្ទុក គឺដើម្បីលើកលែងការចោទប្រកាន់។ ហេតុដូច្នេះហើយទើបចៅក្រមស៊ើបសួរមានសិទ្ធិ ក្នុងការបញ្ជូនរឿងទៅជំនុំជម្រះ និងលើកលែងការចោទប្រកាន់។

#### ២. ជនដែលប្រព្រឹត្តនោះនូវតែគេមិនស្គាល់

ដោយសារតែគោលការណ៍នៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា គឺអាចចោទប្រកាន់ ចំពោះអញ្ញាតជនបាន។ ហើយការបើការបើការស៊ើបសួរក៏អាចបើប្រឆាំង នឹងអញ្ញាតជនបានដែរ ដូច្នេះបើនៅតែពុំអាចស្វែងរកអំពីអត្តសញ្ញាណរបស់ជនត្រូវចោទបាននោះទេ ចៅក្រមស៊ើបសួរត្រូវតែចេញដីកាលើកលែងការចោទប្រកាន់។

[129] មាត្រា ២៤៧ កថាខណ្ឌ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ៣. គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ

ចំណុចទី៣ នេះកើតឡើងដោយសារគោលការណ៍វិមតិសង្ស័យដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាច្បាប់កំពូល។

គោលការណ៍វិមតិសង្ស័យនេះមានចែងក្នុងមាត្រា៣៨ កថាខណ្ឌទី៦ នៃរដ្ឋធម្មនុញ្ញ។ មាត្រានេះបានចែងថា គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ជនជាប់ចោទ។

### ៤. ករណីបណ្តឹងអាជ្ញារលត់

កាលណាបណ្តឹងអាជ្ញារលត់ ការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយ។ មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅ៖

ក. មរណៈភាពនៃជនល្មើស

ខ.ផុតអាជ្ញាយុកាល

គ. ការលើកលែងទោសជាទូទៅ

ឃ. និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

ង. អាជ្ញាអស់ជំនុំ

ចៅក្រមស៊ើបសួរអាចចេញដីកាលើកលែងការចោទប្រកាន់បានលុះត្រាតែលក្ខខណ្ឌណាមួយខាងលើនេះបានបំពេញទើបចៅក្រមស៊ើបសួរអាចធ្វើទៅបាន។ ការចេញដីកាដំណោះស្រាយជាគោលការណ៍ចៅក្រមស៊ើបសួរត្រូវតែមានសម្អាងហេតុ។ លើសពីនេះទៅទៀតចៅក្រមស៊ើបសួរអាចចេញដីកាលើកលែងការចោទប្រកាន់ទៅលើអំពើខ្លះ និងបញ្ជូនទៅជំនុំជម្រះខ្លះបានតាមការយល់ឃើញរបស់ខ្លួន។ ក្នុងករណីដែលចៅក្រមស៊ើបសួរបានសម្រេចលើកលែងការចោទប្រកាន់ដោយមូលហេតុមរណៈភាពនៃជនត្រូវចោទ ឬការមិនអាចកំណត់អំពីអត្តសញ្ញាណជនរងគ្រោះ ចៅក្រមស៊ើបសួរអាចប្តឹងទៅតុលាការព្រហ្មទណ្ឌ ដើម្បីសម្រេចរឹបអូសនៅទ្រព្យសម្បត្តិរបស់ជនត្រូវចោទ ដែលកើតចេញពីបទល្មើសនោះបាន។

### ៤.២. ការបញ្ជូនទៅជំនុំជម្រះ

ការបញ្ជូនទៅជំនុំជម្រះ គឺត្រូវបានធ្វើឡើងនៅពេលដែលចៅក្រមស៊ើបសួរបានបញ្ចប់ការស៊ើបសួររបស់ខ្លួន ដោយបានស្វែងរកភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដែលបង្ហាញថាជនត្រូវចោទពិតជាបានប្រព្រឹត្តិបទល្មើសពិតប្រាកដមែន ដូចដែលអ្វីដែលតុលាការធ្វើការចោទប្រកាន់មែន ។ ការបញ្ជូនទៅជំនុំជម្រះអាចធ្វើទៅបាន បើសិនមានមូលហេតុដូចដូចជា៖ (១) **មូលហេតុដែលនាំឱ្យចេញដីកាបញ្ជូនទៅជំនុំជម្រះ** (២) **នីតិវិធីក្នុងការចេញដីកាបញ្ជូនទៅជំនុំជម្រះ** (៣) **អានុភាពនៃដីកាបញ្ជូនទៅជំនុំជម្រះ ។**

### ៤.២.១. មូលហេតុដែលនាំឱ្យចេញដីកាបញ្ជូនទៅជំនុំជម្រះ

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិអំពីមូលហេតុនៃការចេញដីកាដំណោះស្រាយដែលមានដូចជា៖

- ចៅក្រមស៊ើបសួររកឃើញពិរុទ្ធភាពគ្រប់គ្រាន់អាចធ្វើការបញ្ជូនទៅជំនុំជម្រះបាន
- បុគ្គលដែលបានប្រព្រឹត្តិនោះពិតជាបានប្រព្រឹត្តិបទល្មើសពិតមែន
- មានភស្តុតាងសមល្មមដាក់បន្ទុកទៅលើជននោះបាន
- ជនត្រូវចោទគេស្គាល់អត្តសញ្ញាណត្រឹមត្រូវ ។

### ៤.២.២. នីតិវិធីក្នុងការចេញដីកាបញ្ជូនទៅជំនុំជម្រះ

ក្រោយពីការបង្វិលដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាត្រលប់មកវិញ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយ ដែលគាត់ជ្រើសរើសការបញ្ជូនទៅជំនុំជម្រះទៅកាន់តុលាការជំនុំជម្រះ ប្រសិនបើយល់ឃើញថាអំពើនោះ ជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ។ ការបញ្ជូនទៅជំនុំជម្រះនេះទៀតសោត ត្រូវតែបញ្ជូនទៅកាន់ប្រធានតុលាការ ដើម្បីកំណត់ពេលសវនាការជំនុំជម្រះ[130]។ ជាមួយគ្នានោះដែរ ចៅក្រមស៊ើបសួរត្រូវចេញលិខិតជូនដំណឹងពីដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះដល់ព្រះរាជអាជ្ញា ដើមបណ្តឹង ជនត្រូវចោទ ឬ មេធាវី ដើម្បីឱ្យបានដឹងពីដំណើរការនៃនីតិវិធីស៊ើបសួរ ថាសំណុំរឿងត្រូវបានចៅក្រមស៊ើបសួរបញ្ជូនទៅជំនុំជម្រះហើយ។ ទន្ទឹមនឹងនេះដែរ ចៅក្រមស៊ើបសួរអាចរក្សាជនជាប់ចោទឱ្យនៅជាប់ឃុំបណ្តោះអាសន្នរហូតដល់ពេលជនជាប់ចោទចូលបង្ហាញខ្លួននៅមុខតុលាការជំនុំជម្រះផងដែរ។ ជាមួយគ្នានេះដែរ នៅក្នុងដីកាបញ្ជូនទៅជំនុំជម្រះត្រូវរៀបរាប់អំពីអំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់។ ហើយនៅពេលដែលចេញដីកា ចៅក្រមស៊ើបសួរត្រូវចេញដោយមានសម្អាងហេតុ ព្រមទាំងត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុតដល់ ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី។ ក្នុងការចេញដីកាដំណោះស្រាយចៅក្រម មានឯករាជ្យភាពពេញលេញក្នុងការចេញដីកា ដោយមិនចាំបាច់ត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាឡើយ។

### ៤.២.៣ អានុភាពនៃដីកាបញ្ជូនទៅជំនុំជម្រះ

ដីកាបញ្ជូនទៅជំនុំជម្រះមានអានុភាពបង្ហាញឱ្យឃើញថា ជនត្រូវចោទពិតជាបានប្រព្រឹត្តនូវបទល្មើសដូចដែលព្រះរាជអាជ្ញាចោទប្រកាន់ពិតមែន ដោយយោងតាមការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរក្នុងដំណាក់កាលស៊ើបសួរកន្លងមក។ ក្រោយពេលចៅក្រមស៊ើបសួរសម្រេចចេញដីកានេះរួចមក ជនត្រូវចោទនឹងក្លាយទៅជាជនជាប់ចោទ។ ហើយអ្វីដែលសំខាន់នោះគឺ ដីកាបញ្ជូនទៅជំនុំជម្រះ មានអានុភាពបញ្ជូនជនជាប់ចោទទៅកាន់តុលាការជំនុំជម្រះ ដើម្បីធ្វើការផ្តន្ទាទោសចំពោះអំពើដែលជននោះបានប្រព្រឹត្ត។

[130] មាត្រា ២៥០ កថាខណ្ឌ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

# ជំពូកទី៤

# បញ្ហាប្រឈមបច្ចុប្បន្ន និងយុទ្ធនាការ

# ជំពូកទី៤

## បញ្ហាប្រឈមបច្ចុប្បន្ន និងយុទ្ធនាការ

យោងតាមរបាយការណ៍បូកសរុបស្ដីពីលទ្ធផលរយៈពេល ៣៥៤ថ្ងៃរបស់ក្រសួងយុត្តិធម៌ ចាប់ពីថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០២០ ដល់ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ បញ្ហាចម្បងដែលតុលាការគ្រប់ជាន់ថ្នាក់ទូទាំងប្រទេសកំពុងជួបប្រទះគឺ ការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត ព្រមទាំងការដាក់ចេញនៅផែនការយុទ្ធនាការក្នុងការអនុវត្តដោះស្រាយភាពកកស្ទះទាំងនោះ។ យុទ្ធនាការនោះត្រូវអនុវត្ត ដោយផ្អែកលើមូលដ្ឋានច្បាប់ជាធរមាន និងជាដាច់ខាតមិនត្រូវឱ្យមាននូវករណី "ត្រីងៀត ឆ្អៀតពង"[131] ផងដែរ។ ក្រោយពីបានអនុវត្តយុទ្ធនាការនោះក្នុងស្មារតី និងឆន្ទៈប្រកបដោយភាពទទួលខុសត្រូវរបស់ក្រុមការងារ នៃ គ.យ.ក.ស. [132]នីមួយៗមក ទទួលបានលទ្ធផលជាផ្លែផ្កា និងសមិទ្ធផលការងារជាច្រើន ក្នុងនោះរួមមាន ភាពជោគជ័យនៃយុទ្ធនាការនៅតាមសាលាដំបូង និងអយ្យការអមសាលាដំបូងនីមួយ ធ្វើឡើងដោយឈរលើមូលដ្ឋាននៃចំណាត់ការដោះស្រាយសំណុំរឿងចាស់ៗដែលកកស្ទះ បានយ៉ាងតិចចំនួន ៩៥%រួចរាល់ និងសំណុំរឿងថ្មីៗចំនួន ៧០%បន្ថែមទៀត នៃសំណុំរឿងទាំងបី ដំណាក់កាលបញ្ចូលគ្នា ( ដំណាក់កាលអយ្យការ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ )។ ម្យ៉ាងវិញទៀត ដោយសារមានភាពញឹកញាប់នៃការកកស្ទះសំណុំរឿងតាមបណ្ដាសាលាដំបូងខេត្តនីមួយ និងការជួយសម្រួលដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានដែលស្ថិតក្នុងតំបន់ដាច់ស្រយាល មានភាពលំបាកក្នុងការធ្វើដំណើរឡើងចុះសាលាដំបូងដាក់ពាក្យបណ្ដឹងផ្សេងៗ និងភាពយឺតយ៉ាវក្នុងការរកដំណោះស្រាយ ព្រមទាំងធ្វើឱ្យមានភាពកក់ក្ដៅ និងខិតកាន់តែជិតចូលប្រជាពលរដ្ឋក្នុងការដោះស្រាយវិវាទ រដ្ឋាភិបាលបានអនុម័ត បង្កើត រៀបចំ និងកិច្ចដំណើរការនូវអង្គភាពមួយដែលបានប្រសិទ្ធនាមថា អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ហៅកាតថា " អ.ដ.ក " [133] ដើម្បីជាយន្តការបំពេញបន្ថែមឱ្យប្រព័ន្ធដោះស្រាយនៅព្រះរាជាណាចក្រកម្ពុជា សំដៅលើកកម្ពស់គុណភាព ប្រសិទ្ធិភាព និងភាពឆាប់រហ័សនៃការដោះស្រាយវិវាទ តាមរយៈការសម្រុះសម្រួល ផ្សះផ្សាក្រៅប្រព័ន្ធតុលាការ ក្នុងគោលបំណងជួយកាត់បន្ថយការកកស្ទះសំណុំរឿងនៅតាមសាលាជម្រះក្ដី បង្វិតសេវាដោះស្រាយវិវាទឱ្យកាន់តែទៅកៀកនឹងប្រជាពលរដ្ឋនៅមូលដ្ឋាន និងធានាបាននូវភាពសុខដុមរមនា និងយុត្តិធម៌ក្នុងសង្គមជាតិ ។ បេសកកម្មដោះស្រាយក្រៅប្រព័ន្ធតុលាការ ចូលរួមដោះស្រាយនូវវិវាទរដ្ឋប្បវេណី វិវាទពាណិជ្ជកម្ម និងវិវាទដទៃទៀត តាមរយៈការសម្រុះសម្រួលផ្សះផ្សាវិវាទ ដោយផ្អែកតាមការព្រមព្រៀងរបស់ភាគីវិវាទ ឬតាមការស្នើសុំរបស់ភាគីវិវាទ ឬដែលភាគីវិវាទយល់

[131] «ត្រីងៀត ឆ្អៀតពង» ពោលគឺឲ្យតែមានឱកាស ម្នាក់ៗនឹងឆ្លៀតរកផលចំណេញដាក់ហោប៉ៅជាមិនខាន ដោយគិតពីផលប្រយោជន៍ផ្ទាល់ខ្លួន

[132] រដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត (គ.យ.ក.ស.)

[133] ព្រះរាជក្រឹត្យ លេខ នស/រកត/១១២៣/២៣៨១ ស្ដីពី ការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៣

ព្រមទទួលយកយន្តការសម្រុះសម្រួលផ្សះផ្សាវិវាទនោះ លើកលែងតែវិវាទដែលមិនអាចជាកម្មវត្ថុនៃការសម្រុះសម្រួលផ្សះផ្សា តាមការកំណត់របស់ច្បាប់ ដូចជា ចំពោះបទល្មើសព្រហ្មទណ្ឌ លើកលែងតែច្បាប់អនុញ្ញាត។

ក្រៅពីបញ្ហាទាំងនោះ បញ្ហាធនធានមនុស្សនៅកម្ពុជាមិនថាជំនាញណាមួយឡើយ ជាពិសេសជំនាញផ្នែកនីតិសាស្ត្រនេះ ដែលជាកត្តាមួយជាកង្វល់របស់រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន។ ធនធានមនុស្សផ្នែកនីតិសាស្ត្រនេះពិតជាមានសារៈសំខាន់មួយក្នុងចំណោមជំនាញផ្សេងទៀត ក្នុងការជួយអភិវឌ្ឍន៍ប្រទេសជាតិ ក្នុងការសិក្សា និងមានចំណេះដឹង បទពិសោធន៍ផ្នែកច្បាប់ដើម្បីជួយកែលំអ និងធ្វើឱ្យមានភាពរលូនក្នុងការអនុវត្តច្បាប់នៅកម្ពុជាដោយមានភាពរហ័ស និងភាពយុត្តិធម៌ពេញលេញ។ សិស្សានុសិស្សដែលបានបញ្ចប់ការសិក្សានៅមិនទាន់មានបទពិសោធន៍ច្រើន និងនៅមិនទាន់មានចំណេះដឹងពេញលេញ ម្យ៉ាងទៀតសិស្សានុសិស្សមួយចំនួន ជីវភាពគ្រួសារមិនទាន់ធូរធារមិនមានលទ្ធភាពរៀននៅសកលវិទ្យាល័យ ធ្វើឱ្យបង្ខំចិត្តឈប់រៀន មិនមានចំណេះដឹងខ្ពង់ខ្ពស់ ព្រមទាំងអ្នកដែលនៅតំបន់ដាច់ស្រយាលផងដែរដែលជាកង្វល់ដ៏ធំមួយរបស់ក្រសួងអប់រំក្នុងការរកដំណោះស្រាយ។ ស្របពេលពិភពលោកបានឈានចូលដល់សេដ្ឋកិច្ចបដិវត្តន៍ឧស្សាហកម្ម៤.០ ដែលកម្ពុជាត្រូវការធនធានមនុស្ស និងការអប់រំបែបឌីជីថលដើម្បីអនុវត្តគោលដៅសេដ្ឋកិច្ចឌីជីថល រាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់ក្នុងការជំរុញឱ្យមានគោលនយោបាយសេដ្ឋកិច្ចឌីជីថល ដើម្បីជំរុញកំណើនសេដ្ឋកិច្ចជាតិឱ្យស្របទៅនឹងបម្រែបម្រួលនៃបដិវត្តន៍ឧស្សាហកម្ម ៤.០និងទាញយកផលប្រយោជន៍កាន់តែច្រើនសម្រាប់ប្រជាជននៅទូទាំងប្រទេស។ តែទោះជាយ៉ាងនេះក្តី ដើម្បីអនុវត្តគោលដៅជាវិជ្ជមានទាំងអស់នេះបានល្អប្រសើរ កម្ពុជាត្រូវការធនធានមនុស្សជាច្រើនដើម្បីអនុវត្តសកម្មភាពនៅគ្រប់ផ្នែកទាំងអស់នៃការអភិវឌ្ឍ។ ដោយសារបច្ចុប្បន្នមានរីកចម្រើនលើផ្នែកបច្ចេកវិទ្យាខ្លាំង ជាមាគ៌ាមួយសម្រាប់សិស្សានុសិស្សគ្រប់ជំនាញ ជាពិសេសផ្នែកនីតិសាស្ត្រក្នុងការងាយស្រួលស្វែងរកឯកសារសិក្សា ការស្រាវជ្រាវពីបញ្ហាសង្គមជាក់ស្តែង និងដំណោះស្រាយ ព្រមទាំងទទួលបានបទពិសោធន៍របស់អ្នកជំនាញផ្សេងៗ តាមរយៈបណ្តាញសង្គមនានា ឆ្លើយតបដល់តម្រូវសិស្សានុសិស្សក្នុងការសិក្សារៀនសូត្រ ទទួលបានទាំងចំណេះដឹង បទពិសោធន៍ និងករណីសិក្សាជាក់ស្តែងក្នុងសង្គមជាតិ ដើម្បីអភិវឌ្ឍសមត្ថភាពខ្លួនឯង។

ម្យ៉ាងវិញទៀតបញ្ហាទាក់ទងនឹងការប្រមូល និងការគ្រប់គ្រងទិន្នន័យសំណុំរឿង ទាំងសំណុំរឿងរដ្ឋប្បវេណី ទាំងសំណុំរឿងព្រហ្មទណ្ឌនៅក្នុងបញ្ហានេះដែរ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌លោកបានប្រាប់ឲ្យសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ត្រូវយកចិត្តទុកដាក់បន្ថែមទៀតលើការប្រមូល និងការគ្រប់គ្រងទិន្នន័យ ដែលនេះគឺជាបញ្ហា ព្រោះថានៅពេលដែលសាលាជម្រះក្តីនីមួយៗមិនបានយកចិត្តទុកដាក់ក្នុងការប្រមូល និងការគ្រប់គ្រងទិន្នន័យឲ្យមានត្រឹមត្រូវច្បាស់លាស់ទេធ្វើឲ្យការបែងចែកប្រភេទសំណុំរឿងនីមួយៗនៅតាមសាលាជម្រះក្តីមានភាពរញ៉េរញ៉ៃដែលនេះជាបញ្ហាដែលធ្វើឱ្យមានការកកស្ទះនូវសំណុំរឿងដែលនិងនាំឲ្យមានភាពយឺតយ៉ាងនៅក្នុងការដោះស្រាយនូវសំណុំរឿង ។ នៅក្នុងការប្រកាសដាក់ចេញនូវយុទ្ធនាការដោះស្រាយភាពមិនប្រក្រតីនៅតាម

តុលាការដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយផ្តោតសំខាន់ទៅលើបញ្ហាទាក់ទងនិងការពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីលើផ្នែកអភិបាលកិច្ច បើយើងនិយាយដល់ផ្នែកអភិបាលកិច្ចគឺបាននិយថាយើងនិយាយអំពីការគ្រប់គ្រង ការដឹកនាំការរៀបចំការងាររបស់យើងធ្វើណាឲ្យមានភាពរលូនល្អប្រសើរ យ៉ាងណាមិញនៅក្នុងវិស័យយុត្តិធម៌ទាក់ទងនិងផ្នែកអភិបាលកិច្ចគឺសំដៅទៅលើការគ្រប់គ្រងនៅក្នុងស្ថាប័នតុលាការជាពិសេសការពិនិត្យ និងការដោះស្រាយធ្វើយ៉ាងណាឲ្យមានភាពរលូនល្អប្រសើរ ព្រោះប្រសិនបើផ្នែកអភិបាលកិច្ចនៅក្នុងស្ថាប័នតុលាការមិនមានភាពរលូនល្អប្រសើរនោះទេ ក្នុងចំណុចនេះចង់សំដៅដល់ការអនុវត្តនីតិវិធីរបស់តុលាការប្រសិនបើការអនុវត្តរបស់តុលាការមិនមាន តម្លាភាព សុចរិតភាព និងប្រសិទ្ធភាពក្នុងការដោះស្រាយនោះទេធ្វើឱ្យមានភាពលំអៀងក្នុងការអនុវត្តវិវាទរបស់គូភាគី និងធ្វើឱ្យអូសបន្លាយពេលវេលាដែលជាបញ្ហានាំឲ្យកើតមាននូវការកកស្ទះរឿង ។ មួយវិញទៀត មានពាក្យស្លោកមួយនិយាយថា មិនត្រូវឲ្យមានជាដាច់ខាតនូវ ករណី "ត្រីងៀត ឆ្អៀតពង" ពាក្យស្លោកខាងលើនេះ ជាយន្តការមួយដែលបានដាក់ចេញដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ពាក្យស្លោកខាងលើនេះចង់មាននិយថា ប្រសិនបើក្នុងករណីចៅក្រម ឬព្រះរាជអាជ្ញាណាមួយ គាត់ដោះស្រាយវិវាទជូនគូភាគីដោយមានការយកថវិការពីភាគីណាម្នាក់ ឬដោយមានការសូកជាថវិកាពីភាគីណាម្នាក់ធ្វើឲ្យវិវាទនៃគូភាគីទាំងសងខាងជាមួយការដោះស្រាយដោយមិនមានភាពយុត្តិធម៌ ករណីខាងលើនេះសបញ្ជាក់មិនភាពមិនស្អាតស្អំរបស់អ្នកអនុវត្តច្បាប់ ដែលនេះជាទង្វើមួយមិនល្អក្នុងប្រព័ន្ធយុត្តិធម៌ ហេតុដូច្នេះហើយបានជា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានដាក់នូវពាក្យស្លោកខាងលើនេះ ដើម្បីឲ្យប្រព័ន្ធយុត្តិធម៌នៅកម្ពុជាអនុវត្តប្រកបដោយតម្លាភាព សុចរិតភាព និងប្រសិទ្ធភាពជូនប្រជាពលរដ្ឋ ។ បញ្ហាការកកស្ទះនូវសំណុំរឿង សាលក្រមដែលទទួលបានដោយភាពយឺតយ៉ាងគឺស្មើនឹងអយុត្តិធម៌ ដូច្នេះសាលាជម្រះក្តីនៅទូទាំងប្រទេសត្រូវជម្រុញការដោះស្រាយសំណុំរឿងឲ្យបានឆាប់រហ័ស និងស្មារតីទទួលខុសត្រូវ ដើម្បីចៀសវាងកុំឲ្យស្ថានភាពនៃការកកស្ទះសំណុំរឿងនេះកើតឡើងជាថ្មី ។

មិនត្រឹមតែប៉ុណ្ណោះ ឯកឧត្តមរដ្ឋមន្ត្រី បានគូសបញ្ជាក់យ៉ាងច្បាស់ថា ក្នុងការបន្តអនុវត្តកម្មវិធីកំណែទម្រង់វិស័យយុត្តិធម៌ «ក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នឹងបន្តពង្រឹងវិធានការវិន័យ ក្រមសីលធម៌ និងភាពស្អាតស្អំរបស់អង្គចៅក្រម ដើម្បីលើកកម្ពស់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់អង្គចៅក្រមបន្ថែមទៀត»។ ក្នុងស្មារតីនេះ ឯកឧត្តមរដ្ឋមន្ត្រី បានធ្វើការណែនាំដល់ដូចខាងក្រោម[134]៖

ទី១. ចៅក្រម ព្រះរាជអាជ្ញា ក៏ដូចជាមន្ត្រីតុលាការទាំងអស់ ត្រូវប្រកាន់ខ្ជាប់នូវអភិក្រមដ៏ថ្លៃថ្លាទាំង៥ របស់សម្តេចតេជោនាយករដ្ឋមន្ត្រី គឺ «ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់» ដើម្បីធ្វើជាគោលការណ៍ក្នុងការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន ក៏ដូចជាក្នុងការដឹកនាំអង្គភាពសាលាជម្រះក្តី ។

[134] អនុសាសន៍ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងពិធីប្រកាសតែងតាំង និងចូលកាន់មុខតំណែងរបស់ប្រធានសាលាដំបូងខេត្តព្រៃវែងថ្ងៃទី៤ ខែសីហា ឆ្នាំ២០២០

ទី២. ចៅក្រម ព្រះរាជអាជ្ញា ក៏ដូចជាមន្ត្រីតុលាការទាំងអស់ ត្រូវប្រកាន់ខ្ជាប់នូវភាពម៉ឺងម៉ាត់របស់ខ្លួនក្នុងការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ ដើម្បីផ្ដល់ការកាត់ក្តីមួយប្រកបដោយអនាគតិ ក្នុងការធានាឱ្យបាននូវភាពយុត្តិធម៌ ត្រឹមត្រូវជូនប្រជាពលរដ្ឋ ជាពិសេសគឺការវៀរចាកនូវអគតិធម៌ទាំង ៤ គឺ ឆន្ទាគតិ ទោសាគតិ ភយាគតិ និងមោហាគតិ ដូចដែលចៅក្រម ព្រះរាជអាជ្ញាទាំងអស់បានធ្វើសច្ចាប្រណិធាន នៅមុនពេលខ្លួនចូលកាន់តំណែង។

ទី៣. ចៅក្រម ព្រះរាជអាជ្ញា ក៏ដូចជាមន្ត្រីតុលាការទាំងអស់ ត្រូវចូលរួមលើកកម្ពស់កិត្តិយស សេចក្តីថ្លៃថ្នូរ និងកិត្យានុភាពនៃអង្គចៅក្រម ដោយត្រូវប្រកាន់ខ្ជាប់ឱ្យបានម៉ឺងម៉ាត់នូវវិន័យ និងក្រមសីលធម៌វិជ្ជាជីវៈរបស់ចៅក្រម និងព្រះរាជអាជ្ញា ទាំងក្នុងពេលបំពេញការងារ ទាំងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ការប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន គឺជាការរួមចំណែកដ៏សំខាន់ក្នុងការលើកកម្ពស់កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃអង្គចៅក្រមខ្លួនឯងហើយវាជាកត្តារួមចំណែកដ៏សំខាន់មិនអាចខ្វះបាន ក្នុងការពង្រឹងជំនឿទុកចិត្តពីសាធារណជនចំពោះវិស័យយុត្តិធម៌។

ទី៤. ចៅក្រម ព្រះរាជអាជ្ញា ក៏ដូចជាមន្ត្រីតុលាការទាំងអស់ ត្រូវចូលរួមប្រកបដោយឆន្ទៈ និងស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការអនុវត្តនូវយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿង នៅតាមសាលាដំបូងរាជធានី-ខេត្ត ដែលបានដាក់ចេញដោយក្រសួងយុត្តិធម៌ កាលពីថ្ងៃទី១៨ ខែឧសភា កន្លងទៅនេះ ដោយអនុវត្តឱ្យបានត្រឹមត្រូវ និងម៉ឺងម៉ាត់តាមអភិក្រម «លឿន ត្រឹមត្រូវ យុត្តិធម៌ និងមិនពុករលួយ»។

ទី៥. ចៅក្រម ព្រះរាជអាជ្ញា ក៏ដូចជាមន្ត្រីតុលាការទាំងអស់ ត្រូវយកចិត្តទុកដាក់ក្នុងការបំពេញការងារដោយត្រូវពង្រឹងសាមគ្គីភាពផ្ទៃក្នុង និងពង្រឹងកិច្ចសហប្រតិបត្តិការល្អជាមួយអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធ ដើម្បីធានានូវដំណើរការល្អនៃស្ថាប័នតុលាការ ក៏ដូចជាប្រសិទ្ធភាពនៃការបម្រើសេវាយុត្តិធម៌ឱ្យបានត្រឹមត្រូវជូនប្រជាពលរដ្ឋ។

ជាមួយគ្នានេះដែរ ប្រព័ន្ធតុលាការនៅកម្ពុជាជាប្រព័ន្ធយុត្តិធម៌មួយដែលតែងតែមានការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំក្រសួងយុត្តិធម៌ ជាពិសេសនោះគឺប្រមុខរាជរដ្ឋាភិបាលដែលលោកតែងតែធ្វើការចង្អុលបង្ហាញដល់ក្រសួងយុត្តិធម៌ឲ្យអនុវត្តយ៉ាងណាឲ្យមានតម្លាភាព សុចរិតភាព ត្រឹមត្រូវក្នុងការអនុវត្តច្បាប់ក្នុងប្រព័ន្ធតុលាការជារឿយៗ ថ្នាក់ដឹកនាំក្រសួងយុត្តិធម៌តែងតែដាក់ចេញនូវយុទ្ធនាការ និងយន្តការដើម្បីអនុវត្តតួយ៉ាងនៅថ្ងៃទី ៩ ខែមករា ឆ្នាំ ២០២៤ ក្រសួងយុត្តិធម៌បានសម្រេចដាក់ចេញ "យុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ"[135] ដើម្បីជួយដោះស្រាយរកយុត្តិធម៌ជូនប្រជាពលរដ្ឋលើកកម្ពស់តម្លាភាព សុចរិតភាព និងភាពត្រឹមត្រូវនៅក្នុងការអនុវត្តច្បាប់ក្នុងប្រព័ន្ធតុលាការ។

---

[135] សន្និសីទសារព័ត៌មានស្ដីពីយុទ្ធនាការពង្រឹង និងលើកកម្ពស់សេវាយុត្តិធម៌ និងគុណភាពនៃយុត្តិធម៌ រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមករា ឆ្នាំ២០២៤

យុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ នេះត្រូវបានដាក់ចេញនៅ ថ្ងៃទី ៩ ខែមករា ឆ្នាំ ២០២៤ និងមានរយៈពេល ៥ ឆ្នាំ គិតចាប់ពីថ្ងៃដាក់ចេញឱ្យដំណើរការ។ក្នុងការប្រកាសដាក់ចេញនូវយុទ្ធនាការ នេះនៅទីស្ដីការក្រសួងយុត្តិធម៌កាលពីថ្ងៃ អង្គារ លោក កើត រិទ្ធ រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌បានលើកឡើងថា យុទ្ធនាការនេះធ្វើឡើងក្នុងគោលបំណងស្វែងរកយុត្តិធម៌ ជូនប្រជាពលរដ្ឋដែលរងគ្រោះពីអំពើអយុត្តិធម៌នានានៅក្នុងសង្គម និងលើកកម្ពស់តម្លាភាពសុចរិតភាព និងភាពត្រឹមត្រូវនៅក្នុងការអនុវត្តច្បាប់ និងចំណាត់ការរឿងក្ដីដោយតុលាការ។

លោក កើត រិទ្ធ បន្តថា យុទ្ធនាការដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការនេះ នឹងផ្ដោតសំខាន់ទៅលើបញ្ហាសំខាន់មួយចំនួនរួមមាន ការពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីលើផ្នែកអភិបាលកិច្ចនៅតាមសាលាជម្រះក្ដីអយ្យការអមសាលាជម្រះក្ដីចំណាត់ការសំណុំរឿងនិង ក្នុងសេចក្ដីសម្រេចរបស់តុលាការ។ ហើយចំណែកយុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការមានគោលបំណង សំខាន់ៗចំនួន ៣ រួមមាន (១) ការបង្កើតច្រក និងយន្តការសម្រាប់ទទួលបណ្ដឹងអំពីភាពមិនប្រក្រតីនៅតាមតុលាការដើម្បីជួយត្រួតពិនិត្យ និងជួយដោះស្រាយរកយុត្តិធម៌ជូនប្រជាពលរដ្ឋពិសេសប្រជាពលរដ្ឋ ក្រីក្រ និងជនងាយរងគ្រោះក្នុងសង្គម (២) ការចូលរួមដោះស្រាយភាពអយុត្តិធម៌ និងភាពមិនប្រក្រតីក្នុង ប្រព័ន្ធតុលាការសំដៅលើកកម្ពស់ភាពយុត្តិធម៌នៅក្នុងចំណាត់ការរឿងក្ដីដោយតុលាការ និង (៣) ការលើកកម្ពស់តម្លាភាពសុចរិតភាពភាពស្អាតស្អំ និងភាពត្រឹមត្រូវនៅក្នុងប្រព័ន្ធតុលាការ ។

មន្ត្រីក្រសួងយុត្តិធម៌រូបនេះក៏បានសង្កត់ធ្ងន់ដែរថា ប្រជាពលរដ្ឋដែលរងគ្រោះដោយអយុត្តិធម៌ដោយការ រំលោភបំពានខុសច្បាប់ក្នុងសង្គម ឬភាពមិនប្រក្រតីតាមតុលាការអាចដាក់ពាក្យបណ្ដឹងដើម្បីមានការ ត្រួតពិនិត្យ និងដោះស្រាយរកយុត្តិធម៌។

ក្រសួងយុត្តិធម៌ នឹងរៀបចំសន្និសីទសារព័ត៌មានប្រកាសដាក់ចេញនូវយុទ្ធនាការចំនួន ២ រួមមាន៖ យុទ្ធនាការជម្រុញ និងពន្លឿនការដោះស្រាយរឿងក្ដីតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យ និងភាពមិនប្រក្រតីនៅតាមតុលាការនៅក្នុងយុទ្ធនាការទាំង២ នេះដែរគឺដើម្បីអនុវត្តវិធានការ គន្លឹះរាជរដ្ឋាភិបាល នីតិកាល ទី ៧ នៃ រដ្ឋសភាក្រោមការដឹកនាំដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ពាក់ព័ន្ធនឹង « ការពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ » ។

យុទ្ធនាការដោះស្រាយសំណុំរឿងកកស្ទះនៅតាមសាលាដំបូងក្រសួងយុត្តិធម៌បានអនុវត្តយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី-ខេត្ត ក្នុងរយៈពេល ២២២ ថ្ងៃនៃការអនុវត្តរបស់ក្រសួងយុត្តិធម៌បានដោះស្រាយសំណុំរឿងព្រហ្មទណ្ឌដែលកកស្ទះជាង ៣៥ ១០០ សំណុំរឿងស្មើនឹង ៨៩ ភាគរយ នៃសំណុំរឿងព្រហ្មទណ្ឌដែលកកស្ទះសរុប ៣៩ ១៥២ សំណុំរឿង និងបាន ជួយកាត់បន្ថយនូវភាពចង្អៀតណែនក្នុងពន្ធនាគារដោយសារតែមានការដោះលែងជនជាប់ឃុំប្រមាណ ២៦ ១០០ នាក់ ។ តាមសេចក្ដីប្រកាសព័ត៌មានរបស់ក្រសួងយុត្តិធម៌ស្ដីពីលទ្ធផលរយៈពេល ២២២ ថ្ងៃ នៃការអនុវត្តយុទ្ធនាការនេះបានឱ្យដឹងថាសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ទូទាំង ប្រទេសបានដោះស្រាយសំណុំរឿងព្រហ្ម

ទណ្ឌដែលកកស្ទះទាំងដំណាក់កាលអយ្យការដំណាក់កាល ស៊ើបសួរ និងដំណាក់កាលជំនុំជម្រះបានជាង ៣៥ ១០០ សំណុំរឿងស្មើនឹង ៨៩ ភាគរយនៃសំណុំរឿង ព្រហ្មទណ្ឌដែលកកស្ទះសរុបចំនួន ៣៩ ១៥២សំណុំរឿង ។ បើតាមសេចក្ដីប្រកាសដដែលតាមរយៈ យុទ្ធនាការនេះសាលាដំបូងរាជធានី-ខេត្តទូទាំងប្រទេសក៏បានដោះស្រាយសំណុំរឿងព្រហ្មទណ្ឌដែល ចូលថ្មីក្នុងឆ្នាំ២០២០ នេះបានចំនួនជាង ៣៦ ៥០០ សំណុំរឿងផងដែរ ។ ការអនុវត្តយុទ្ធនាការនេះបាន ជួយកាត់បន្ថយនូវភាពចង្អៀតណែនក្នុងពន្ធនាគារនៃបុគ្គលជាប់ឃុំប្រមាណ ២៦ ១០០ នាក់ ។ លោក ជិន ម៉ាលីន អ្នកនាំពាក្យក្រសួងយុត្តិធម៌ថ្លែងថា ក្រសួងយុត្តិធម៌បានវាយតម្លៃលទ្ធផលនៃការអនុវត្ត យុទ្ធនាការរយៈពេល ២២២ ថ្ងៃនេះ គឺមានលក្ខណៈវិជ្ជមានគួរឱ្យកត់សម្គាល់ដែលក្នុងរយៈពេលនេះ សាលាដំបូងរាជធានី -ខេត្តអាចដោះស្រាយសំណុំរឿងដែលកកស្ទះបានរហូតដល់ ៨៩ ភាគរយ ។

ម្យ៉ាងវិញទៀតថ្មីនេះ ព្រះមហាក្សត្របានចេញនៅព្រះរាជក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដើម្បីជាយន្តការបន្ថែមឲ្យប្រព័ន្ធដោះស្រាយវិវាទនៅប្រទេសកម្ពុជាសំដៅលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងភាពឆាប់រហ័សនៃការដោះស្រាយវិវាទតាមរយៈការសម្រុះសម្រួលផ្សះផ្សាក្រៅប្រព័ន្ធតុលាការ ក្នុងគោលបំណងជួយកាត់បន្ថយការកកស្ទះសំណុំរឿងនៅតាមសាលាជម្រះក្ដីបង្កើតសេវាដោះស្រាយវិវាទឲ្យកាន់តែកៀកនឹងប្រជាពលរដ្ឋនៅមូលដ្ឋាន និងធានាបាននូវភាពសុខដុមរមនា និងយុត្តិធម៌ក្នុងសង្គមជាតិ ។ ការបង្កើតអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះមានបេសកកម្មដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនូវវិវាទរដ្ឋប្បវេណី វិវាទពាណិជ្ជកម្ម និងវិវាទដទៃទៀត តាមរយៈការសម្រុះសម្រួលផ្សះផ្សាវិវាទ ដោយផ្អែកតាមការព្រមព្រៀងរបស់ភាគីវិវាទ ឬតាមការស្នើសុំរបស់ភាគីវិវាទ ឬដែលភាគីវិវាទយល់ព្រមទទួលយកយន្តការសម្រុះសម្រួលផ្សះផ្សាវិវាទនេះ លើកលែងតែវិវាទដែលមិនអាចជាកម្មវត្ថុនៃការសម្រុះសម្រួលផ្សះផ្សា តាមការកំណត់របស់ច្បាប់ ។

លើកពីនេះទៅទៀត សន្និបាតនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងបូកសរុបលទ្ធផលការងារយុត្តិធម៌ប្រចាំឆ្នាំ និងកំណត់លើកទិសដៅការងារអាទិភាពឆ្នាំ២០២៣។ ជារួម លទ្ធផលការងារយុត្តិធម៌ឆ្នាំ ២០២២ ដែលសម្រេចបានរួមមាន៖ (១)-ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលបម្រើឱ្យវិស័យយុត្តិធម៌ និងការចូលរួមចំណែកយ៉ាងសំខាន់ក្នុងការពិនិត្យ និងផ្ដល់យោបល់លើសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួង-ស្ថាប័នផ្សេងទៀត ជាពិសេស លើជំពូក ឬផ្នែកស្ដីពីទោសបញ្ញត្តិ, (២)-ការជួសជុលអគារទីស្ដីការក្រសួងយុត្តិធម៌ និងការសាងសង់អគារសាលាយុត្តិធម៌ថ្មី ដែលជាកត្តារួមចំណែកដ៏សំខាន់ដល់ការពង្រឹងប្រសិទ្ធភាពការងារ និងប្រសិទ្ធភាពនៃការផ្ដល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ, (៣)-ការបណ្ដុះបណ្ដាល និងពង្រឹងធនធានមនុស្ស, (៤)-ការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្ដល់សេវាយុត្តិធម៌

នៅតាមសាលាជម្រះក្តីឱ្យបានល្អ និងការដោះស្រាយសំណុំរឿងឱ្យបានឆាប់រហ័សជូនប្រជាពលរដ្ឋ និង (៥)-ការចូលរួមចំណែកយ៉ាងសំខាន់របស់វិស័យយុត្តិធម៌ក្នុងការសម្រេចបាននូវបេសកកម្មដ៏ធំរបស់កម្ពុជា គឺការដកកម្ពុជាចេញពីបញ្ជីប្រផេះរបស់ FATF កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣ នេះ ដែលនេះជាបេសកកម្មដ៏ធំមួយក្នុងការពារប្រព័ន្ធហិរញ្ញវត្ថុ និងសេដ្ឋកិច្ចកម្ពុជា ពិសេស ការពង្រឹងតម្លាភាព ជំនឿទុកចិត្ត និងភាពរឹងមាំនៃប្រព័ន្ធហិរញ្ញវត្ថុរបស់កម្ពុជា។

ទន្ទឹមនឹងសមិទ្ធផលធំៗខាងលើនេះ វិស័យយុត្តិធម៌ក៏នៅជួបប្រទះបញ្ហាប្រឈមធំៗមួយចំនួនទៀត ដែលត្រូវរួមគ្នាដោះស្រាយផងដែរ សំដៅលើកកម្ពស់សេវាយុត្តិធម៌នៅកម្ពុជា។ សម្រាប់សន្និបាតនេះ, អង្គសន្និបាតបានលើកយកប្រធានបទចំនួន ២ ដែលជាទិសដៅកែទម្រង់ដ៏សំខាន់ក្នុងវិស័យយុត្តិធម៌ មកពិភាក្សា រួមមាន៖ ប្រធានបទទី១ ពាក់ព័ន្ធនឹងការលើកកម្ពស់ការផ្តល់សេវាយុត្តិធម៌នៅតាមសាលាជម្រះក្តី និងប្រធានបទទី២ ពាក់ព័ន្ធនឹងទិសដៅការងារកែទម្រង់យុត្តិធម៌ខាងផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌ខាងផ្នែករដ្ឋប្បវេណី។

បន្ទាប់ពីអង្គសន្និបាតបានពិភាក្សាគ្នាយ៉ាងផុលផុសរយៈពេលពេញមួយថ្ងៃ, អង្គសន្និបាតបានឯកភាពគ្នាដាក់ចេញនូវទិសដៅការងារអាទិភាពសម្រាប់ឆ្នាំ២០២៣ របស់វិស័យយុត្តិធម៌ ដោយផ្តល់អាទិភាពលើការងារសំខាន់ៗ រួមមាន៖ (១)-ការពិនិត្យ និងវាយតម្លៃអំពីការវិសោធនកម្ម ឬបច្ចុប្បន្នភាពក្រមព្រហ្មទណ្ឌ, ក្រមនីតិវិធីព្រហ្មទណ្ឌ, ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, (២)-ការជំរុញបញ្ចប់ការរៀបចំ និងអនុម័តសេចក្តីព្រាងច្បាប់សំខាន់ៗមួយចំនួនទៀតសម្រាប់វិស័យយុត្តិធម៌ រួមមាន ច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី, ច្បាប់ស្តីពីអាជ្ញាសារ, ច្បាប់ស្តីពីលក្ខន្តិកៈសារការី, ច្បាប់ស្តីពីការគ្រប់គ្រងនិងការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក ជាដើម, (៣)-ការបន្តពង្រឹងសមត្ថភាពធនធានមនុស្ស, ការជំរុញការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា, ការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសេវាបកប្រែក្នុងដំណើរការនីតិវិធីតុលាការ, សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រង និងចាត់ចែងថវិកាសម្រាប់សាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តី និង (៤)-ការធ្វើទំនើបកម្មរដ្ឋបាលតុលាការ។

ទន្ទឹមនេះ ដើម្បីធ្វើឱ្យទិសដៅការងារអាទិភាពឆ្នាំ ២០២៣ របស់វិស័យយុត្តិធម៌នេះ កាន់តែមានភាពច្បាស់លាស់ និងកាន់តែមុតស្រួច, ឯកឧត្តមរដ្ឋមន្ត្រី បានធ្វើការណែនាំ និងដាក់ចេញនូវទិសដៅការងារអាទិភាពមួយចំនួនបន្ថែមទៀត ដូចតទៅ[136]៖

---

[136] ពិធីសន្និបាតបូកសរុបការងារយុត្តិធម៌ឆ្នាំ២០២២ និងលើកទិសដៅការងារអាទិភាពឆ្នាំ២០២៣

ទី១-អង្គភាពចំណុះរបស់ក្រសួងយុត្តិធម៌ ក៏ដូចជា សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ត្រូវយកចិត្តទុកដាក់បន្ថែមទៀតលើការងារប្រមូល និងគ្រប់គ្រងទិន្នន័យសំណុំរឿង ទាំងសំណុំរឿងព្រហ្មទណ្ឌ ទាំងសំណុំរឿងរដ្ឋប្បវេណី ដោយធ្វើការបែងចែកទៅតាមប្រភេទសំណុំរឿងនីមួយៗឱ្យបានច្បាស់លាស់ ដើម្បីដាក់ចេញនូវនយោបាយ និង វិធានការចាំបាច់នានាបានឆាប់រហ័ស និង មានប្រសិទ្ធភាពខ្ពស់ ទាំងលើការដាក់ចេញគោលនយោបាយព្រហ្មទណ្ឌ ទាំងលើការរៀបចំគោលនយោបាយផ្នែករដ្ឋប្បវេណី ដើម្បីអាចឆ្លើយតបបានទៅនឹងស្ថានភាពជាក់ស្តែងរបស់សង្គមជាតិ ។

ទី២-ក្រសួងយុត្តិធម៌ នឹងរៀបចំឱ្យមានគណៈកម្មការចំពោះកិច្ចមួយ ដើម្បីដឹកនាំ និងវាយតម្លៃអំពីការអនុវត្តក្រមទាំង ៤ ក៏ដូចជា ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលមានការពាក់ព័ន្ធ សំដៅពិនិត្យមើលអំពីការលំបាកនានា ក៏ដូចជា ប្រសិទ្ធភាពក្នុងឆ្លើយតបទៅនឹងការវិវត្តនៃស្ថានភាពសង្គមជាក់ស្តែងរបស់កម្ពុជា ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការពិចារណាក្នុងការធ្វើវិសោធនកម្ម នាពេលខាងមុខ។

ទី៣-សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ត្រូវពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងយកចិត្តទុកដាក់បន្ថែមទៀតក្នុងការដោះស្រាយឱ្យបានម៉ឺងម៉ាត់ និងត្រឹមត្រូវ នូវសំណុំរឿងនានា ជាពិសេស ពាក់ព័ន្ធនឹងបទល្មើសដែលមានភាពរសើបក្នុងសង្គមជាតិ ដូចជា សំណុំរឿងពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន, បទល្មើសសម្អាតប្រាក់, បទល្មើសជួញដូរនិងប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ ដើម្បីរួមចំណែកក្នុងការពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់ និងស្ថិរភាពសង្គម។

ទី៤-ការជំរុញការដោះស្រាយសំណុំរឿងឱ្យបានឆាប់រហ័ស និងស្មារតីទទួលខុសត្រូវខ្ពស់ នៅតាមសាលាជម្រះក្តីនៅទូទាំងប្រទេស ដើម្បីចៀសវាងកុំឱ្យស្ថានភាពនៃការកកស្ទះសំណុំរឿងនេះកើតឡើងជាថ្មី។

ទី៥-គ្រប់អង្គភាពចំណុះក្រសួងយុត្តិធម៌ និងសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ត្រូវយកចិត្តទុកដាក់ខ្ពស់លើការពង្រឹងវិន័យការងារ និងក្រមសីលធម៌ តាមរយៈការអនុវត្តឱ្យបានតឹងរឹង និងម៉ឺងម៉ាត់នូវវិធានការវិន័យនានាស្របតាមច្បាប់ស្តីពីលក្ខន្តិកៈនៃមន្ត្រីរាជការស៊ីវិល ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត សំដៅបង្កើនប្រសិទ្ធភាពការងារបន្ថែមទៀត។

ទី៦- ក្រសួងយុត្តិធម៌ នឹងបន្តពង្រឹងការជ្រើសរើស និងការបណ្តុះបណ្តាលមន្ត្រីក្នុងវិស័យយុត្តិធម៌ មុននឹងចាត់បញ្ជូនឱ្យទៅបម្រើការងារតាមអង្គភាពជំនាញក្នុងវិស័យយុត្តិធម៌ ទាំងនៅថ្នាក់កណ្តាល ទាំងនៅតាមអង្គភាពរដ្ឋបាលតុលាការ តាមរយៈការផ្តោតការយកចិត្តទុកដាក់លើការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលនៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។ ទន្ទឹមនេះ, សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ត្រូវបន្តយកចិត្ត

ទុកដាក់ខ្ពស់លើការពង្រឹងសមត្ថភាពធនធានមនុស្សរបស់ខ្លួនផងដែរ តាមរយៈការពង្រឹងលើការសិក្សាស្រាវជ្រាវ ការរៀបចំជាសិក្ខាសាលា វគ្គបណ្តុះបណ្តាល ឬកម្មវិធីចែករំលែកនូវចំណេះដឹង និងបទពិសោធន៍ថ្មីៗដល់មន្ត្រីរាជការដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន។ ម្យ៉ាងទៀត, មន្ត្រីគ្រប់រូបក្នុងវិស័យយុត្តិធម៌ ក៏ត្រូវយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពរបស់ខ្លួនជាប់ជាប្រចាំផងដែរ ដើម្បីអាចសម្របខ្លួនបានទាន់នឹងការវិវត្តយ៉ាងឆាប់រហ័ស ក្នុងវិស័យច្បាប់ និង យុត្តិធម៌។

ទី៧-ទោះបីជាកម្ពុជាត្រូវបានដកចេញពីបញ្ជីប្រផេះរបស់ FATF ក៏ដោយ, សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ត្រូវបន្តយកចិត្តទុកដាក់ពង្រឹងសមត្ថភាពរបស់ក្រុមការងារប្រឆាំងសម្អាតប្រាក់របស់ខ្លួន ក៏ដូចជា បន្តយកចិត្តទុកដាក់ដោះស្រាយសំណុំរឿងពាក់ព័ន្ធនឹងបទល្មើសសម្អាតប្រាក់ឱ្យបានឆាប់រហ័ស និង ត្រឹមត្រូវស្របតាមច្បាប់ និងនីតិវិធីជាធរមាន ដើម្បីចៀសវាងនូវស្ថានភាពដែលកម្ពុជាអាចត្រូវបានដាក់ចូលក្នុងបញ្ជីប្រផេះរបស់ FATF សាជាថ្មីឡើងវិញ និងដើម្បីរួមចំណែកក្នុងការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាឱ្យកាន់តែមានភាពរឹងមាំ និងកាន់តែមានជំនឿទុកចិត្ត។

ទី៨-យន្តការជំនាញដែលមានការពាក់ព័ន្ធ ត្រូវបន្តសហការគ្នាពន្លឿនការរៀបចំឱ្យបានរួចរាល់នូវក្របខណ្ឌគោលនយោបាយ និងក្របខណ្ឌច្បាប់ស្តីពីសន្ធានកម្ម ដើម្បីបង្កើតឱ្យមាននូវយន្តការដោះស្រាយវិវាទតាមរយៈសន្ធានកម្ម និងវិជ្ជាជីវៈសន្ធានការីដែលជាវិជ្ជាជីវៈថ្មីក្នុងវិស័យច្បាប់ ដើម្បីរួមចំណែកក្នុងការបង្វិតសេវាយុត្តិធម៌ឱ្យកាន់តែទៅកៀកនឹងប្រជាពលរដ្ឋ, ជួយឱ្យមានការដោះស្រាយវិវាទដោយឆាប់រហ័ស ដោយអាចរក្សាបាននូវភាពសុខដុមរមនារវាងគូភាគីវិវាទ និងជួយកាត់បន្ថយការកកស្ទះសំណុំរឿងរដ្ឋប្បវេណីនៅតាមសាលាជម្រះក្តី។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក ក្រោយពីបានបកស្រាយប្រធានបទខាងលើរួចមកយើងខ្ញុំទាំងពីរនាក់បានធ្វើការសិក្សាស្រាវជ្រាវយ៉ាងលម្អិតទៅលើប្រធានបទស្តីពី ចៅក្រមស៊ើបសួរនៅកម្ពុជាបច្ចុប្បន្ន អំពីការបើកការស៊ើបសួរ ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ អំណាចក្នុងការចេញលើវិធានការនិរន្តរាយ និងអំពីការបិទការស៊ើបសួររួចមកយើងខ្ញុំទាំងពីរយល់ឃើញថា ដំណាក់កាលចៅក្រមស៊ើបសួរ គឺជាដំណាក់កាលមួយយ៉ាងសំខាន់ ដើម្បីធានានូវអព្យាក្រឹតភាពដែលស្របទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិមានខ្លឹមសារថា ចៅក្រមស៊ើបសួរមិនអាចជាចៅក្រមជំនុំជម្រះបានទេ។ លើសពីនេះទៅទៀតការបើកការស៊ើបសួររបស់គាត់មិនត្រូវធ្វើឡើងតាមទំនើងចិត្តបានទេ គឺកើត ឡើងដោយមានការទទួលពាក្យបណ្តឹងជាមុនសិនដោយមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ព្រមទាំងមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ បន្ទាប់ពីនីតិវិធីបើកការស៊ើបសួរហើយទាក់ទងនឹង វិធានការស្រាវជ្រាវដែលជាផ្នែកដ៏សំខាន់សម្រាប់ដំណើរការស៊ើបសួរនេះកាន់តែមានភាពយុត្តិធម៌ ប្រកបដោយ តម្លាភាព ក្នុងនោះត្រូវគោរពតាមវិធានការរួមមាន ត្រូវមានការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការ ត្រួតពិនិត្យ ការសួរចម្លើយជនត្រូវចោទ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ការចុះទៅកន្លែងកើតហេតុការស្តាប់ចម្លើយសាក្សី ការឆែកឆេរនិងការចាប់យកវត្ថុតាង ការធ្វើកោសលវិច័យ ការស្តាប់ទូរស័ព្ទ ។ ហើយរាល់នីតិវិធីនេះព្រះរាជអាជ្ញាដែលជាម្ចាស់បណ្តឹងអាជ្ញាក៏អាចមានការចូលរួមបានដែរ។

ក្រៅពីវិធានការស្រាវជ្រាវចៅក្រមស៊ើបសួរក៏នៅមានអំណាចក្នុងដាក់ឱ្យជនត្រូវចោទនូវវិធាននិរន្តរាយមួយ ចំនួនដែលចៅក្រមស៊ើបសួរតែងតែប្រើប្រាស់ក្នុងការអនុវត្តបេសកកម្មរបស់ខ្លួនរួមមាន ដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន និងដីកាបង្គាប់ឱ្យឃុំខ្លួន។ ដំណាក់កាលចុងក្រោយនៃការស៊ើបសួរបានបញ្ចប់សព្វគ្រប់ហើយ គឺត្រូវបិទការស៊ើបសួរ តាមរយៈដីកាដំណោះស្រាយចំនួនពីរប្រភេទរួមមាន ដីកាបញ្ជូនទៅជំនុំជម្រះ និងដីកាលើកលែងការចោទប្រកាន់។ បន្ទាប់មកចៅក្រមស៊ើបសួរត្រូវរៀបចំរបាយការណ៍មួយហៅថា របាយការណ៍ជូនរឿងទៅជំនុំជម្រះ″ កាលបើក្នុងដីកានោះត្រូវបញ្ជូនទៅជំនុំជម្រះមិនថាតែមួយផ្នែក ឬទាំងអស់នោះទេ។ ចំពោះការលើកលែងការចោទប្រកាន់ក៏ដោយមិនថាមួយតែមួយផ្នែក ឬទាំងអស់ត្រូវមានសម្អាងហេតុដែរ។ ក្រោយបានរបាយការណ៍ព្រមទាំងសំណុំរឿងទាំងអស់ត្រូវដាក់ជូនទៅប្រធានតុលាការដើម្បីចាត់ការតាមច្បាប់។ ប្រសិនបើតុលាការយល់ឃើញថា សំណុំរឿងមូលសព្វគ្រប់ហើយប្រធាននោះនឹងចាត់តាំងចៅក្រមម្នាក់ទទួលបន្ទុកធ្វើការជំនុំជម្រះលើរឿងក្តីនោះ។

សរុបសេចក្តីមក ដំណាក់កាលចៅក្រមស៊ើបសួរដែលមានចៅក្រមស៊ើបសួរជាអ្នកដឹកនាំ គឺមានអត្ថប្រយោជន៍យ៉ាងខ្លាំងនៅក្នុងវិស័យយុត្តិធម៌ ដោយបានធានានូវប្រជាពលរដ្ឋ និងសង្គមទាំងមូលឱ្យទទួលបាននូវសុខសន្តិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយ ។ ហេតុនេះហើយ ដើម្បីចូលរួមក្នុងការរីកចម្រើនតៅលើវិស័យយុត្តិធម៌នេះ គប្បីត្រូវចូលរួមគោរពច្បាប់ ដើម្បីឱ្យសង្គមទាំងមូលមានការអភិវឌ្ឍន៍រីកចម្រើន ។

# អនុសាសន៍

# អនុសាសន៍

